# “ការស្វែងយល់ពីស្ថានភាពបំណុល និង ការទទួលបានសេវាសុខភាពក្នុងចំណោមប្រជាជននៅតំបន់ជនបទក្នុងប្រទេសកម្ពុជា”

## របាយការណ៍ស្រាវជ្រាវ

**រៀបរៀងដោយៈ ស៊ឹម សុជាតា**
**សម្រាប់សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ**

**ខែ កក្កដា ឆ្នាំ ២០១៤**






**អ្នកសរសេរឯកសារស្រាវជ្រាវ៖ ស៊ឹម សុជាតា**

**បោះពុម្ពផ្សាយដោយ៖** សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ

**ដោយកិច្ចសហប្រតិបត្តិការជាមួយ៖** សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ ក្រុមតន្ត្រីយុវវ័យនាំសារ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) សមាគមកសិករឯករាជ្យដើម្បីការអភិវឌ្ឍន៍សហគមន៍ និងបណ្តាញភ្នំគុក។

ខ្លឹមសារនៃរបាយការណ៍នេះអាចត្រូវបានផលិតឡើងវិញ និងដកស្រង់ដោយសេរីក្នុងលក្ខខណ្ឌដែលប្រភពដើមត្រូវបានបញ្ជាក់។ សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ (SAC) រីករាយក្នុងការទទួលយកឯកសារដែលមានការដកស្រង់ព័ត៌មានពីរបាយការណ៍នេះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ កញ្ញា ច្រឹក សុភា តាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែល) chreksophea@gmail.com ឬ តាមរយៈលេខទូរស័ព្ទ ៨៥៥ (0) ៩២ ២៩៣ ២៥៧ ឬ កញ្ញា លី ពិសី តាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែល) forcechange@gmail.com ឬតាមរយៈទូរស័ព្ទលេខ ៨៥៥ (0) ១២ ៦៩៧ ៦៩១ ។

**អាសយដ្ឋាន៖** ការិយាល័យ សម្ព័ន្ធបងប្អូនស្រី ៖ ផ្ទះលេខ ៣-៤ ផ្លូវលេខ ៣៣៩ សង្កាត់បឹងកក់ I ខ័ណ្ឌទូលគោក រាជធានីភ្នំពេញ

## សេចក្តីសង្ខេប

ការសិក្សាស្រាវជ្រាវនេះបានធ្វើការផ្តោតជាសំខាន់ទៅលើកម្រិតបំណុលក្នុងចំណោមគ្រួសារចំនួន ១៣៣ គ្រួសាររស់នៅក្នុងភូមិ ចំនួន ៦ ក្នុងខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង តាមរយៈកម្រងសំណួរស្ទង់មតិ។ បន្ថែមពីលើនេះទៀត ការសម្ភាសន៍ស៊ីជម្រៅត្រូវបានធ្វើឡើងជាមួយនឹងគ្រួសារដែលបានចូលរួមក្នុងការស្ទង់មតិ ចំនួន ២២ គ្រួសារ ហើយគ្រួសារទាំងនោះបានអោយដឹងថាពួកគាត់កំពុងជាប់បំណុលនាពេលបច្ចុប្បន្ននេះ ហើយពួកគាត់ធ្លាប់ខ្ចីប្រាក់ដើម្បីចំណាយលើការព្យាបាលជម្ងឺ។ ការពិភាក្សាជាមួយភាគីពាក់ព័ន្ធសំខាន់ៗទាក់ទងនឹងទស្សនៈរបស់ពួកគាត់ក្នុងការទទួលបានសេវាសុខភាព បំណុលគ្រួសារ និងស្ថានភាពដាំដុះស្រូវក៏ត្រូវធ្វើឡើងផងដែរ។

៧៥ភាគរយនៃអ្នកចូលរួមផ្តល់ការសម្ភាសន៍មានកម្មសិទ្ធិលើដីស្រែដែលមានទំហំតូចជាង ឬ ស្មើមួយហិចតា។ អ្នកចូលរួមផ្តល់ការសម្ភាសន៍ បានអោយដឹងថា ពួកគេបានចំណាយកាន់តែច្រើនឡើងៗទៅលើការធ្វើកសិកម្មដើម្បីផលិតស្រូវ។ ៩៩ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍បានដាំដុះដំណាំស្រូវកាលពីឆ្នាំមុន ។ មានតែ ៩២ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍តែប៉ុណ្ណោះ បានឲ្យដឹងថា ទិន្នផលស្រូវរបស់ពួកគាត់ គឺគ្រប់គ្រាន់សម្រាប់បរិភោគក្នុងគ្រួសារបានមួយឆ្នាំពេញ។ ៧៩ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍បានឲ្យដឹងថា ការចំណាយលើជី និងបរិមាណជីដែលប្រើមានការកើនឡើងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ។ ប្រហែលជា៣៦ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍បានផ្តល់ចម្លើយថា ថ្លៃជីមានការកើនឡើងក្នុងចន្លោះពី ២.៧៥ ដុល្លា ដល់៥ដុល្លា ក្នុងមួយបាវ (៥០គីឡូក្រាម)។ អតុល្យភាពរវាង ចំណាយ និង ទិន្នផល(ស្រូវ) ត្រូវបានបញ្ជាក់យ៉ាងច្បាស់ ហើយកសិករបានរាយការណ៍ថាពួកគាត់ត្រូវលក់ស្រូវដើម្បីសងថ្លៃជីគីមី និងសងទៅលើការចំណាយលើសម្ភារៈកសិកម្មផ្សេងៗទៀត ។ មានការរាយការណ៍ថា ស្រូវត្រូវបានលក់ទៅឲ្យទាំងឈ្មួញជនជាតិខ្មែរ ។ មិនមានការកំណត់តម្លៃអប្បរមាលើតម្លៃស្រូវនោះទេ។

៧៦ភាគរយនៃអ្នកចូលរួមផ្តល់ការសម្ភាសន៍ ពេលបច្ចុប្បន្ននេះកំពុងតែជំពាក់បំណុល ។ ចំនួនបំណុលជាមធ្យមគឺ មានតម្លៃ ៧៧៥.៨៥ ដុល្លា ហើយចំនួនបំណុលដែលខ្ពស់ជាងគេ មានតម្លៃ ១០,១៨៧ ដុល្លា និងទាបបំផុត មានតម្លៃ ១.២៥ ដុល្លា ។ ៥៧ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍ ជំពាក់បំណុលតិចជាង ២៥០ ដុល្លា។ យ៉ាងណាមិញ ច្រើនជា ៥៦ភាគរយនៃគ្រួសារក្នុងការស្ទង់មតិ ធ្លាប់ខ្ចីប្រាក់ដើម្បីព្យាបាលជម្ងឺនៅរយៈពេលពីរឆ្នាំចុងក្រោយនេះ។ ក្នុងការសិក្សានេះ កម្ចីដែលគ្រួសារខ្ចីពីធនាគារក្នុងស្រុក និងស្ថាប័នមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី ជាទូទៅមានអត្រាការប្រាក់ចាប់ពី ២៤ភាគរយ ដល់ ៣៦ភាគរយក្នុងមួយឆ្នាំ ចំណែកឯកម្ចីពីអ្នកផ្តល់កម្ចីឯកជន

វិញ មានអត្រាការប្រាក់ចាប់ពី ៣៦ភាគរយ ដល់៦០ភាគរយក្នុងមួយឆ្នាំ។ បច្ចុប្បនេះ មិនមានបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងអត្រាការប្រាក់ដែលកំណត់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុនោះទេ។

ការចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ជាយន្តការពេញនិយម និងសំខាន់មួយសម្រាប់ដោះស្រាយបញ្ហាបំណុលក្នុងចំណោមគ្រួសារនៅតំបន់ជនបទ។ ប្រាក់បញ្ញើរបានមកពីការងាររោងចក្រកាត់ដេរ សំណង់ ការស៊ីឈ្នួលដាំដុះនៅក្នុងចំការធំៗ ទាំងក្នុង និងខាងក្រៅប្រទេសកម្ពុជាដើរតួ ជាយន្តការដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាបំណុល។ ប្រាក់បញ្ញើរត្រូវបានប្រើប្រាស់ទៅលើ ការផលិតស្រូវ ការទទួលទានប្រចាំថ្ងៃនៅក្នុងគ្រួសារ សងបំណុល ព្យាបាលជម្ងឺ ការអប់រំ និងការផ្គត់ផ្គង់លើតម្រូវការសផ្សេងៗទៀតនៅក្នុងគ្រួសារ។ យោងទៅតាមអ្វីដែលបានលើកឡើង មានបញ្ហាផ្សេងៗគ្នាមួយចំនួន ៖ក. ការជំឡើងនូវប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករនៅមិនទាន់ឆ្លើយតបទៅនឹងកម្រិតនៃការទាមទាររបស់កម្មករនៅឡើយ ខ. អ្នកចំណាកស្រុកទាំងស្របច្បាប់ និងមិនស្របច្បាប់បានត្រលប់ពីប្រទេសថៃយ៉ាងគំហុកដោយសារអស្ថេរភាពនយោបាយក្នុងប្រទេសនេះ គ. កម្មករនៅក្នុងចំការធំៗ ធ្វើការដោយទទួលបានការការពារសិទ្ធិតិចតួច ឬ គ្មានតែម្តង។ ពលករចំណាកស្រុក និងប្រាក់បញ្ញើររបស់ពួកគាត់គឺជាប្រភពធនធានយ៉ាងសំខាន់ក្នុងការរួមចំនែកផ្នែកសេដ្ឋកិច្ច គ្រទ្រដល់ការនៅរបស់គ្រួសារ និងជាយន្តការដោះស្រាយបញ្ហាក្នុងអំឡុងពេលមានវិបត្តិ (រួមមានកសិកម្ម និងបញ្ហាសុខភាព) ឬ ប្រើសម្រាប់ដោះស្រាយទូទាត់សងបំណុលឲ្យទាន់ពេលវេលា។ ដូចនេះ វិបត្តិ ឬក៏ ការផ្លាស់ប្តូរផ្សេងៗដែលកើតឡើងទៅលើសុវត្ថិភាពការងាររបស់ពួកគាត់ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងលើការរស់រានរបស់ពួកគាត់ ព្រមទាំងអ្នកដែលពឹងផ្អែកលើប្រាក់បញ្ញើរទាំងស្រុងរបស់ពួកគាត់ផងដែរ។

# មាតិកា


**សេចក្តីសង្ខេប** ..... 3

**អារម្ភកថា** ..... 7

**អក្សរកាត់** ..... 7

**សេចក្តីផ្តើម** ..... 9

**ផ្នែកទី ១៖ សាវតា និងការដកស្រង់ពីរបាយការណ៍ដែលមាន** ..... 10

**១.១ សុខភាព និងភាពក្រក្រ ក្នុងប្រទេសកម្ពុជា** ..... 10

**១.២ ការចំណាយលើសេវាសុខភាព និងបំណុលគ្រួសារ** ..... 12

**ផ្នែកទី ២៖ វិធីសាស្ត្រស្រាវជ្រាវ** ..... 16

**២.១ ដំណើរការរៀបចំផែនការ និងវិធីសាស្ត្រ** ..... 16

**២.២ ឧបករណ៍ប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ** ..... 17

**២.៣ គំរូ** ..... 18

**២.៤ ការប្រមូលទិន្នន័យ** ..... 19

**២.៥ ការការពារអត្តសញ្ញាណនៃអ្នកចូលរួមក្នុងការសិក្សា** ..... 19

**ផ្នែកទី ៣៖ របកគំហើញសំខាន់ៗ** ..... 20

**៣.១ ចរិតលក្ខណៈសង្គមសេដ្ឋកិច្ចរបស់គ្រួសារដែលបានធ្វើការស្ទង់មតិ** ..... 20

**៣.២ ការផលិតស្រូវ** ..... 24

**ក. ការប្រមូលផលស្រូវ** .....

**ខ. ការចំណាយថ្លៃដើមនៃផលិតកម្មស្រូវ និង ទិន្នផលស្រូវដែលទទួលបាន** .....

**គ. ការគាំទ្រពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដល់កសិករក្នុងការផលិតស្រូវ**

**៣.៣ បំណុលគ្រួសារ** ..... 35

**ក. គម្រោងសន្សំប្រាក់ដែលបង្កើតដោយអង្គការមិនមែនរដ្ឋាភិបាល**

**ខ. ការប្រើប្រាស់ប្រាក់កម្ចីសម្រាប់ព្យាបាលជម្ងឺ**

**គ. ការប្រើប្រាស់សេវាព្យាសុខភាព**

**៣.៤ ផលប៉ះពាល់ពីបំណុល និងយន្តការដោះស្រាយបញ្ហារបស់គ្រួសារ** ... 51

**ផ្នែកទី ៤៖ ការពិភាក្សា និងសេចក្តីបញ្ចប់** ... 61

**ឯកសារយោង** ... 65

**ចង្កោមឧបសម្ព័ន្ធ** ... 70

## អារម្ភកថា

ការសិក្សាស្រាវជ្រាវអាចធ្វើទៅបានដោយសារមានកិច្ចសហការពីគ្រួសារដែលបានចូលរួមក្នុងការស្ទង់មតិ។ ក្រុមសិក្សាស្រាវជ្រាវសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ពេលវេលា និងការប្តេជ្ញាចិត្តរបស់ពួកគាត់ក្នុងការផ្តល់ព័ត៌មានអំពីគ្រួសារ ជាពិសេសព័ត៌មានផ្ទាល់របស់បុគ្គលដូចជាបំណុល និងបញ្ហាសុខភាព។ អ្នកសរសេរអត្ថបទស្រាវជ្រាវនេះ សូមសំដែងអំណរគុណចំពោះការគាំទ្រដែលបានផ្តល់ជូនដោយសមាជិកក្រុមស្រាវជ្រាវ បុគ្គលិករបស់អង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ (COFAP) និង អង្គការសកម្មភាពដើម្បីសហគមន៍ និងបរិស្ថាន (AEC) សមាជិកបណ្តាញភ្នំគុកក្នុងខេត្តកំពង់ឆ្នាំង និងសមាគមកសិករឯករាជ្យដើម្បីការអភិវឌ្ឍន៍សហគមន៍ (IFACD) ក្នុងខេត្តព្រៃវែង។ សូមថ្លែងអំណរគុណចំពោះការគាំទ្រ និងការសម្របសម្រួលយ៉ាងពេញទំហឹងក្នុងដំណើរការស្រាវជ្រាវទាំងមូល។ យើងខ្ញុំសូមកោតសរសើរនូវការគាំទ្រដែលបានផ្តល់ជូនដោយលោក **ជា សុភ័ក្រ** នៃបណ្តាញកសិករ និងធម្មជាតិដែលបានធ្វើការសម្របសម្រួលការសាកល្បងនៃកម្រងសំណួរនៅក្នុងខេត្តកំពង់ស្ពឺ។

សូមអរគុណផងដែរចំពោះសមាជិកនៃសម្ព័ន្ធបងប្អូនស្រី (Us) និងអ្នកស្ម័គ្រចិត្តរបស់សម្ព័ន្ធទាំងមូល ដែលបានរួមចំណែកក្នុងការចំណាយពេលវេលា ផ្តល់មតិយោបល់ និងកិច្ចខំប្រឹងប្រែងក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ។ សូមអរគុណចំពោះការសម្របសម្រួល និងការគាំទ្រយ៉ាងពេញទំហឹងក្នុងដំណើរការស្រាវជ្រាវទាំងមូល។ សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ (SAC) ក៏ធ្វើការសំដែងអំណរគុណចំពោះម្ចាស់ជំនួយសម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនឿទុកចិត្តដែលបានផ្តល់ជូនយើងខ្ញុំ ប្រសិនបើមិនមានការគាំទ្រនេះទេ ការសិក្សាស្រាវជ្រាវក៏មិនអាចធ្វើទៅបានដែរ ។

## អក្សរកាត់

| | |
|---|---|
| AEC | សកម្មភាពដើម្បីសហគមន៍ និងបរិស្ថាន |
| CC | ក្រុមប្រឹក្សាឃុំ |
| CCWC | ក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រី និងកុមារ |
| CMA | សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា |
| COFAP | អង្គការ សហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ |
| DoAFF | ការិយាល័យ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុក |
| HC | មណ្ឌលសុខភាព |
| HEF | មូលនិធិសមធម៌សុខភាព |

| | |
|---|---|
| IFACD | សមាគមន៍កសិករឯករាជ្យដើម្បីការអភិវឌ្ឍន៍សហគមន៍ |
| MB | ក្រុមតន្ត្រីយុវវ័យនាំសារ |
| MFIs | ស្ថាប័នមីក្រូហិរញ្ញវត្ថុ |
| MoH | ក្រសួងសុខាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| OD | ស្រុកប្រតិបត្តិ |
| OOP | ការចំណាយ ពីហោប៉ៅ |
| FH | មន្ទីរពេទ្យបង្អែក |
| SAC | សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ |
| WAC | កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ |
| WNU | បណ្តាញការងារស្ត្រីរួបរួមគ្នា |

**កំណត់ចំណាំះ**

- (n) ចំនួន-តំណាងឲ្យចំនួនគ្រួសារផ្តល់បទសម្ភាសន៍ក្នុងការស្ទង់មតិ។
- អត្រាប្តូរប្រាក់ដែលបានប្រើប្រាស់ក្នុងរបាយការណ៍នេះគឺ ១ ដុល្លារ = ៩០០០រៀល
- គោយន្តះ គ្រឿងចក្រកសិកម្មដែលបានប្រើប្រាស់ក្នុងការភ្ជួរ ទុកដាក់ និងដឹកជញ្ជូនទំនិញ។
- គោយន្តត្រូវបានប្រើប្រាស់ជាទូទៅនៅតំបន់ជនបទដែលមានស្ថានភាពផ្លូវពិបាក។

# សេចក្តីផ្តើម

សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ បានសហការជាមួយសមាគមកសិករក្នុងស្រុក បណ្តាញសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឈ្មោះថា សកម្មភាពដើម្បីសហគមន៍ និងបរិស្ថាន (AEC) ក្រុមតន្ត្រីយុវវ័យនាំសារ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) សមាគមកសិករឯករាជ្យដើម្បីការអភិវឌ្ឍន៍ សហគមន៍ (IFACD) បណ្តាញភ្នំគុក ក្រោមការដឹកនាំរួមរបស់អ្នកស្រាវជ្រាវឯករាជ្យ បានធ្វើការចងក្រងនូវរបាយការណ៍ស្រាវជ្រាវនេះឡើង។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងក្នុងការស្វែងយល់ពីកម្រិតបំណុលដោយសារការចំណាយលើការព្យាបាលជម្ងឺក្នុងចំណោមក្រុមគ្រួសារដែលបានធ្វើការស្ទង់មតិ ក្នុងសហគមន៍ជនបទក្នុងខេត្តព្រៃវែង និងខេត្តកំពង់ឆ្នាំង និងស្វែងយល់អំពីការប្រឈមដែលក្រុមគ្រួសារដែលជាប់បំណុលកំពុងជួបប្រទះ និងស្វែងយល់ពីយន្តការដោះស្រាយបញ្ហារបស់ពួកគាត់ជាពិសេសពាក់ព័ន្ធជាមួយនឹងការថែទាំសុខភាព និងផលិតកម្មកសិកម្ម។ ការសិក្សាស្រាវជ្រាវនេះក៏ធ្វើការស្វែងយល់អំពីតួនាទី និងគោលនយោបាយគ្រប់គ្រងការប្រតិបត្តិការណ៍ការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធានាគារពាណិជ្ជក្នុងប្រទេសកម្ពុជាផងដែរ។

ការសិក្សាស្រាវជ្រាវក្រោមចំណងជើង "ការស្វែងយល់ពីស្ថានភាពបំណុល និង ការទទួលបានសេវាសុខភាពក្នុងចំណោមប្រជាជននៅតំបន់ជនបទក្នុងប្រទេសកម្ពុជា " ត្រូវបានចងក្រងឡើងជាឯកសារសម្រាប់លើកកម្ពស់ការយល់ដឹងទៅដល់សមាគមកសិករ បណ្តាញសហគមន៍ និងអ្នកដែលធ្វើការតស៊ូមតិជុំវិញការទទួលបានសេវាសុខភាពជាសកល និងមានគុណភាព បង្ហាញពីបញ្ហាបំណុលនៅជនបទ និង ការទទួលបានទីផ្សារដែលប្រកបដោយភាពយុត្តិធម៌សម្រាប់កសិករខ្នាតតូច។ របាយការណ៍នេះក៏ត្រូវបានរំពឹងទុកថា ជាឧបករណ៍ក្នុងការបង្កើតជាកិច្ចពិភាក្សារវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធផ្សេងៗ។

របាយការណ៍នេះត្រូវបានរៀបចំឡើងជាបួនផ្នែក។ ផ្នែកទីមួយគឺជាការមើលទៅលើការសិក្សាស្រាវជ្រាវដែលមានស្រាប់ស្តីពីការចំណាយលើការព្យាបាលជម្ងឺ និងស្ថានភាពបំណុលក្នុងប្រទេសកម្ពុជា។ ផ្នែកទីពីរ ធ្វើការពន្យល់ពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការសិក្សានេះ។ ផ្នែកទីបី គ្របដណ្តប់លើរបកគំហើញៗនៅក្នុងការសិក្សានេះ ដែលចែកចេញជាប្រាំផ្នែក៖ ចរិតលក្ខណៈសង្គមសេដ្ឋកិច្ចរបស់ក្រុមគ្រួសារ, ផលិតកម្មស្រូវ, បំណុលគ្រួសារ, ផលប៉ះពាល់នៃបំណុល និងយន្តការដំណោះស្រាយរបស់ក្រុមគ្រួសារ។ ផ្នែកចុងក្រោយបង្ហាញពីការពិភាក្សា និងសេចក្តីបញ្ចប់នៃការសិក្សាស្រាវជ្រាវនេះ។

# ផ្នែកទី ១៖ សាវតា និងការដកស្រង់ពីរបាយការណ៍ដែលមាន

## ១.១ សុខភាព និង ភាពក្រីក្រ ក្នុងប្រទេសកម្ពុជា

ក្នុងរបាយការណ៍សន្ទស្សន៍នៃការអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ ២០១៣ ប្រទេសកម្ពុជាបានជាប់ ចំណាត់ថ្នាក់ទី១៣៨ ក្នុងចំណោមប្រទេសចំនួន ១៨៧ និងដែនដីដែលមានការទទួលស្គាល់ដោយអង្គការសហប្រជាជាតិ(អង្គការសហប្រជាជាតិស្តីពីកម្មវិធីអភិវឌ្ឍន៍ (UNDP) ២០១៣)។ សេដ្ឋកិច្ចបានកើនឡើងគឺ ៧.២ ភាគរយ ក្នុងឆ្នាំ ២០១៣ បើប្រៀបធៀបទៅឆ្នាំ ២០១០ គឺមានកម្រិតត្រឹមតែ ៦ភាគរយ (ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ២០១៤)។ យ៉ាងណាមិញ ភាពក្រីក្រនៅតែជាបញ្ហាលេចធ្លោ ជាពិសេសនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់ធនាគារពិភពលោកចង្អុលបង្ហាញថាប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រខ្លាំងបានធ្លាក់ចុះពី ៥០.១ភាគរយក្នុងឆ្នាំ ២០០៧ មកត្រឹម ២២.១ ភាគរយក្នុងឆ្នាំ ២០១០ (ធនាគារពិភពលោក ២០១៤) ហើយអត្រានេះបានធ្លាក់ចុះបន្ថែមទៀតរហូតដល់ ១៩.៨ភាគរយ ក្នុងឆ្នាំ ២០១៣ (UNDP២០១៤)។ យ៉ាងណាមិញ នៅក្នុងទសវត្សចុងក្រោយនេះ មានការកើនឡើងនូវគំលាតទ្រព្យសម្បត្តិ និងប្រាក់ចំណូលរវាងតំបន់ទីក្រុង និងតំបន់ជនបទ ដែលបង្កឲ្យមានអតុល្យភាពសេដ្ឋកិច្ចក្នុងចំណោមប្រជាជនក្នុងប្រទេសកម្ពុជា។ ប្រមាណជា ៨០ភាគរយ នៃប្រជាជនសរុប (១៤.៨ លាននាក់) នៅតំបន់ជនបទពឹងផ្អែកយ៉ាងខ្លាំងទៅលើកសិកម្មជាលក្ខណៈគ្រួសារ ឬសម្រាប់ហូប និងការប្រមូលផលស្រូវ (វិទ្យាស្ថានស្ថិតិជាតិ ២០០៩)។

នៅមុនឆ្នាំ១៩៩៦ ការទទួលបានសេវាសុខភាពដោយមិនគិតថ្លៃត្រូវបានផ្តល់ជូនប្រជាជនកម្ពុជាជាផ្លូវការ ។ រដ្ឋាភិបាលបានផ្តល់ការឧបត្ថម្ភធនលើការផ្តល់សេវាសុខភាព ហើយប្រជាពលរដ្ឋអាចទទួលបាននូវសេវាកម្មដោយឥតបង់ថ្លៃ ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ ។ ប៉ុន្តែ ការផ្តល់សេវាកម្មគឺនៅមានកម្រិត ហើយការបង់លុយក្រោមតុបានក្លាយជារឿងពេញនិយមនាពេលនោះ។ ក្នុងពាក់កណ្តាលឆ្នាំ ១៩៩០ កំណែទម្រង់លើវិស័យសុខាភិបាលត្រូវបានផ្តួចផ្តើមឡើង ក្នុងគោលបំណងពង្រីកការគ្របដណ្តប់ហេដ្ឋារចនាសម្ព័ន្ធសុខភាព អភិវឌ្ឍការគ្រប់គ្រង និងស្វែងរកវិធីសាស្ត្រក្នុងការផ្តល់ហិរញ្ញប្បទានដល់សេវាថែទាំសុខភាព និងសេវាកម្មដែលមានគុណភាព។ ក្នុងឆ្នាំ ១៩៩៦ គោលការណ៍ហិរញ្ញប្បទានសុខាភិបាលត្រូវបានអនុម័ត ហើយសិទ្ធិក្នុងការយកកម្រៃពីអ្នកប្រើប្រាស់នៅស្ថាប័នសុខភាពសាធារណៈត្រូវបានអនុញ្ញាត (ក្រសួងសុខាភិបាលឆ្នាំ ១៩៩៦)។ ប្រព័ន្ធបង់ថ្លៃលើការប្រើប្រាស់សេវាសុខភាពដោយអ្នកប្រើប្រាស់ ឬដោយប្រជាជន ត្រូវបានណែនាំដោយធនាគារពិភពលោក ដែលជាផ្នែកមួយនៃលក្ខខណ្ឌនៃកម្ចីដែលមានភ្ជាប់ជាមួយ នៅក្នុងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSP) ដែលពីមុនគឺជា កម្មវិធីផែនការ

ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ (SAP) ដែលបានអនុវត្តនៅក្នុងប្រទេសក្រីក្រក្នុងទ្វីបអាហ្វ្រិក ក្នុងសតវត្សឆ្នាំ ១៩៨០ ឬ ក្នុងប្រទេសកម្ពុជាក្នុងចុងសតវត្សឆ្នាំ ១៩៩០។ នៅប្រទេសកម្ពុជា នៅ ២០០៨ កម្មវិធីបង់ថ្លៃសេវានៃអ្នកប្រើប្រាស់ត្រូវបានអនុវត្តនៅតាមស្ទើរតែគ្រប់ស្ថាប័នសុខភាពរដ្ឋាភិបាលទាំងអស់ (ក្រសួងសុខាភិបាល ២០០៩)។ ការសិក្សាមួយចំនួនដែលផ្តោតលើផលប៉ះពាល់អវិជ្ជមាននៃប្រព័ន្ធបង់ថ្លៃលើការប្រើសេវាមកលើគុណភាព និងការប្រើប្រាស់សេវាកម្ម ចង្អុលបង្ហាញថាមានចង្កោមប្រជាជនក្រីក្រមានលទ្ធភាពក្នុងការទទួលបានសេវាសុខភាព (Akashi, Yamada et al.២០០៤, Jacob និង Price ២០០៤, Annar, Wilkinson et al. ២០០៦) ហើយការចំណាយថវិការនៅតែជាឧបសគ្គមួយក្នុងចំណោមឧបសគ្គចម្បងៗដែលរារាំងប្រជាជនក្រីក្រក្នុងការទទួលបានសេវាសុខភាព (Annear, Wilkinson et al. ២០០៦) ។

នៅកម្រិតថ្នាក់ជាតិ ការចំណាយលើការព្យាបាលជម្ងឺសរុបសម្រាប់ឆ្នាំ ២០១២ មានចំនួន ៧៦៣ លានដុល្លារដែលតំណាងឲ្យ ៥ភាគរយ នៃផលិតផលក្នុងស្រុកសរុប ឬប្រហែលជា ៥២ ដុល្លារក្នុងមួយឯកតាក្នុងមួយឆ្នាំ (ក្រសួងសុខាភិបាល ២០១២)។ ក្នុងចំណោមនេះ ការចំណាយលុយហោប៉ៅ(OOP) មានចំនួន ៦១ ភាគរយ ឬប្រហែលជា៣១.៧២ដុល្លារ សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ។ ការចំណាយដោយរដ្ឋាភិបាលមានចំនួន១៥ភាគរយ (ឬស្មើនឹង៧.៨ ដុល្លារ) ទៅលើមនុស្សម្នាក់ក្នុងមួយឆ្នាំ។ ការចំណាយលុយហោប៉ៅក្នុងប្រទេសកម្ពុជាស្ថិតក្នុងការចំណាយដែលខ្ពស់បំផុតក្នុងទ្វីបអាស៊ី ហើយវាជាការចំណាយធ្ងន់ធ្ងរលើការព្យាបាលជម្ងឺ។ បន្ទុកនៃការចំណាយលើការថែទាំសុខភាពរបស់គ្រួសារគឺធ្ងន់ធ្ងរខ្លាំង។ ការសិក្សាស្រាវជ្រាវរបស់ Oxfam មួយក្នុងឆ្នាំ ២០០០ បានបង្ហាញថា ថ្លៃចំណាយព្យាបាលជម្ងឺ ជាកត្តាមួយដែលនាំឲ្យមានការបាត់បង់ដីធ្លីក្នុងប្រទេសកម្ពុជា (Biddulph ២០០០) ។ ការសិក្សាស្រាវជ្រាវមួយទៀតដែល បានធ្វើឡើងដោយកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) បានរកឃើញថា ជាមធ្យមប្រហែលជា២០ភាគរយនៃកម្ចីរបស់គ្រួសារត្រូវបានចំណាយទៅលើការព្យាបាលជម្ងឺ (UNDP 2004) ។ ការចំណាយលើការព្យាបាលជម្ងឺគឺជាធាតុដ៏សំខាន់ក្នុងការពន្យល់ពីភាពក្រីក្រនៅកម្រិតគ្រួសារក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រក្នុងប្រទេសកម្ពុជា។ ហើយវាដើរតួជាឬសគល់ និងជាលទ្ធផលនៃភាពក្រីក្រ។

ចាប់តាំងពីឆ្នាំ ២០០០មក ដោយមានការផ្តួចផ្តើមដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គម្រោងឧបត្ថម្ភធនមួយដែលមានឈ្មោះថាមូលនិធិសមធម៌សុខភាព (HEF) ត្រូវបានអនុវត្តជាគម្រោងសាកល្បងសម្រាប់ប្រជាជនក្រីក្របំផុតដើម្បីឲ្យពួកគាត់ទទួលបានសេវាសុខភាពនៅតាមមន្ទីរពេទ្យរដ្ឋ។ មូលនិធិសមធម៌សុខភាព ជាការចំណាយដោយជនទីបីទៅលើសេវាថែទាំសុខភាព

និងថ្លៃចំណាយដែលពាក់ព័ន្ធ (អាហារ ការធ្វើដំណើរ)ដែលក្រុមគ្រួសារក្រីក្របានប្រើប្រាស់ក្នុងអំឡុងពេលព្យាបាល។ មូលនិធិសមធម៌សុខភាព ត្រូវបានអនុវត្ត និងពង្រីកនៅតាមសុខភាព និងមន្ទីរពេទ្យបង្អែកក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបែងចែកថវិការរដ្ឋសម្រាប់គាំទ្រដល់គម្រោងមូលនិធិសមធម៌សុខភាពនៅតាមមន្ទីរពេទ្យរដ្ឋ។ ត្រឹមឆ្នាំ ២០១២ មូលនិធិសមធម៌សុខភាព បានគ្រប់ដណ្តប់មន្ទីរពេទ្យបង្អែកចំនួន ៥៦ (ក្នុងចំណោមមន្ទីរពេទ្យបង្អែកទាំង៨៦) និង មណ្ឌលសុខភាពចំនួន៣១៣ (ក្នុងចំណោម១០២៤មណ្ឌល) និង ផ្តល់លទ្ធភាពក្នុងការទទួលបានសេវាសុខភាពទៅអោយប្រជាពលរដ្ឋក្រីក្រដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រចំនួន៧៨ភាគរយ (ក្រសួងសុខាភិបាល ២០១២)។

## ១.២ ការចំណាយលើសេវាសុខភាព និង បំណុលគ្រួសារ

ការវិភាគមួយទៅលើយុទ្ធសាស្រ្តដោះស្រាយជាហិរញ្ញវត្ថុរបស់គ្រួសារជុំវិញការចំណាយលើសេវាសុខភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មានរាប់បញ្ចូលនូវការសន្សំ ការកាត់បន្ថយការប្រើប្រាស់ ការខ្ចីពីសាច់ញាតិ និងមិត្តភ័ក្រ ការលក់ទ្រព្យសម្បត្តិ និងការទទួលបានកម្ចី (Sauerborn, Adams et al. ១៩៩៦) ។ ការត្រួតពិនិត្យលើយុទ្ធសាស្រ្តដំណោះស្រាយគ្រួសារ ជុំវិញការចំណាយលើសេវាសុខភាព បង្ហាញពីភាពពាក់ព័ន្ធគ្នារវាងការចំណាយនៃការព្យាបាលជម្ងឺ និងកម្ចី៖ គ្រួសារទំនងស្វែងរកកម្ចីសម្រាប់ចំណាយលើថ្លៃសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ (Leive និង Xu ២០០៨) ។ អលទ្ធភាពដោយសារការមិនមានសាច់ប្រាក់ក្នុងដៃសម្រាប់ចំណាយលើការព្យាបាលរបស់គ្រួសារក្រីក្រ ធ្វើអោយពួកគាត់សម្រេចចិត្តមិនទទួលយកការព្យាបាល (Khun និង Manderson ២០០៨) ។

គំរូនៃយុទ្ធសាស្រ្តដោះស្រាយក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ ក្នុងន័យម្យ៉ាងដោយផ្អែកលើចរិតលក្ខណៈ និង ថ្លៃចំណាយព្យាបាលដែលត្រូវការចាំបាច់ ។ ការស្ទង់មតិសុខភាពប្រជាសាស្រ្តកម្ពុជា (CDHS) ក្នុងឆ្នាំ ២០០០ បានបង្ហាញថាប្រជាជនកម្ពុជាលក់ធនធានដែលមានផលិតភាពដូចជាដីធ្លី ឬសត្វពាហនៈ ប្រើប្រាស់ប្រាក់សន្សំ ឬ ខ្ចីប្រាក់ដើម្បីចំណាយលើការព្យាបាលជម្ងឺ (NIS ២០០០) ។ ប៉ុន្តែ វាទាមទារឲ្យមានការអង្កេតអោយបានជិតដល់ទៅលើយុទ្ធសាស្រ្តដោះស្រាយទាំងអស់នេះ នៅក្នុងបរិបទនៃការស្វែងយល់ពីភាពក្រីក្រ ពីព្រោះបើយោងទៅតាមការសិក្សាស្រាវជ្រាវមួយដោយ VanDamme et al. (២០០៤) សូម្បីតែការចំណាយមធ្យមលើសេវាសុខភាព ក៏អាចបណ្តាលឲ្យមានការជំពាក់បំណុល និងធ្វើឲ្យមានភាពក្រីក្រក្នុងគ្រួសារ ។ ពួកគេបានរកឃើញថា ៦២ភាគរយ នៃប្រជាជនដែលបានខ្ចីលុយក្នុងការបង់ថ្លៃព្យាបាលជម្ងឺគ្រុនឈាមរបស់កូនៗរបស់ពួកគាត់ គឺនៅតែបន្តសងបំណុលក្នុងរយៈពេលមួយឆ្នាំក្រោយពីការព្យាបាល (VanDamme, Leemput et al. ២០០៤) ។ ចំនួនសាច់ប្រាក់ដែលអាចខ្ចីបាននៅតាមជនបទគឺនៅ

មានកម្រិត ហើយការខ្ចីឥណទានសម្រាប់ពប្រជាជនក្រីក្រ គឺនៅមានបញ្ហានៅឡើយ (Kassie ២០០០) ។ ឥណទានទទួលបានជាចំបងតាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ឬអ្នកផ្តល់កម្ចីឯកជន ដែលអត្រាការប្រាក់ប្រចាំខែអាចខ្ពស់រហូតដល់ ១០ ភាគរយ ប្រសិនខ្ចីពីអ្នកផ្តល់កម្ចីឯកជន (VanDamme, Meessen et al. ២០០៣) ។ នេះបណ្តាលឲ្យគ្រួសារមួយចំនួនមិនអាចសងប្រាក់ដើម និងការប្រាក់នៃកម្ចីបាន ដែលពួកគាត់ត្រូវលក់ទ្រព្យសម្បត្តិមានផលិតភាពរបស់ខ្លួននៅពេលមានគ្រោះថ្នាក់សុខភាព (Khun និង Manderson ២០០៨) ។

ការជ្រើសរើសក្នុងការលក់ទ្រព្យសម្បត្តិដែលមានផលិតភាពរបស់ខ្លួនដូចជាដីធ្លី ឬសត្វពាហនៈក្នុងការបង់ថ្លៃចំណាយព្យាបាលជម្ងឺ ឬ សងបំណុលដែលបានប្រើប្រាស់ក្នុងការព្យាបាលជម្ងឺជារឿងពេញនិយម ។ ការពិត ការចំណាយធ្ងន់ធ្ងរលើការព្យាបាលជម្ងឺ ជាកត្តាចម្បងមួយដែលនាំអោយមានការជាប់បំណុលក្នុងចំណោមគ្រួសារនៅតំបន់ជនបទនៅប្រទេសកម្ពុជា (Kassie ២០០០) ។ គ្រោះថ្នាក់លើសុខភាពដែលបណ្តាលមកពីជម្ងឺ ដូចជាជម្ងឺគ្រុនឈាម (ជាជម្ងឺពេញនិយម និង រាលដាលនៅតំបន់ជនបទ) អាចជាបន្ទុកដ៏ធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុដល់គ្រួសារ។ ការរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវមួយចំនួនអំពីការព្យាបាលជម្ងឺគ្រុណឈាម បង្ហាញថា គ្រួសារបានបង្ខំចិត្តខ្ចីប្រាក់ដើម្បីចំណាយលើថ្លៃព្យាបាល (VanDamme, Leemput et al. ២០០៤, Khun និងManderson ២០០៧, Khun និង Manderson ២០០៨, Huy, Huy, et al. ២០០៩, Julienbeaute និង Sirendavong ២០១០) ។ ចំណាយទៅលើការព្យាបាលជម្ងឺគ្រុណឈាមតែមួយគត់ មានតម្លៃស្មើនឹង៧៨ភាគរយនៃការចំណាយសរុប និងមានតម្លៃស្មើនឹង៦៣ភាគរយនៃចំណាយដោយផ្ទាល់ទៅលើថ្នាំវេជ្ជសាស្ត្រ) ដែលចំណាយពីហោប៉ៅរបស់គ្រួសារ (OOP) គឺមានចន្លោះពី ៦៥ភាគរយទៅ ៨០ភាគរយនៃចំណាយដោយផ្ទាល់ទៅលើការព្យាបាលជម្ងឺគ្រុនឈាម ក្នុងចន្លោះឆ្នាំ ២០០៦-២០០៨ (Julien beaute និង Sirendavong 2010) ។ ខណៈពេលដែលគ្រួសារក្រីក្រប្រឈមនឹងតម្រូវការក្នុងការខ្ចីប្រាក់កាន់តែញឹកញាប់ជាងមុន (Huy, Huy et al. ២០០៩) លទ្ធភាពក្នុងការខ្ចីឥណទាន និង កម្ចីរបស់ពួកគាត់នៅមានកម្រិត ហើយនេះធ្វើអោយពួកគាត់មានអាកប្បកិរិយាក្នុងការរងចាំមើលពីស្ថានភាពជំងឺជាជាងទៅរកការព្យាបាល (Khun និង Manderson ២០០៧ Khun និង Manderson ២០០៨) ។ ថ្លៃចំណាយដោយផ្ទាល់ទៅលើថ្នាំវេជ្ជសាស្ត្រ គឺជាមូលហេតុចំបងដែលធ្វើអោយស្ត្រីបដិសេធមិនទៅប្រើសេវានៅមន្ទីរពេទ្យ ។ ថ្លៃចំណាយព្យាបាលគឺច្រើនជាងចំណាយមួយភាគបួននៃការចំណាយប្រចាំខែរបស់គ្រួសារ (Matsuoka, Aiga et al. ២០១០) ។

ទំនាក់ទំនងរវាងបំណុលដោយសារការព្យាបាលជម្ងឺ និងភាពគ្មានដីធ្លី គឺជាសញ្ញាណនៃភាពងាយរងគ្រោះរបស់គ្រួសារនៅតាមជនបទ និង ជាកត្តាដ៏សំខាន់ធ្វើអោយពួកគេធ្លាក់ចូលទៅ

ក្នុងភាពក្រីក្រកាន់តែខ្លាំង ។ ការស្ទង់មតិមួយអំពីផលប៉ះពាល់សេដ្ឋកិច្ចដោយសារគ្រោះថ្នាក់លើ
សុខភាពក្នុងភូមិចំនួន២ បានបង្ហាញថាបរាជ័យនៃទិន្នផល (ស្រូវ) មិនបានបណ្តាលអោយមានការ
ខូចខាតផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរដល់គ្រួសារនៅតំបន់ជនបទក្នុងប្រទេសកម្ពុជាដូចទៅនិងការចំណាយ
ដោយសារ គ្រោះថ្នាក់លើសុខភាពនោះទេ (Kenjiro ២០០៥) ។ ការចំណាយលើការព្យាបាលជម្ងឺ
រួមចំនែកដល់ការសម្រេចចិត្តរបស់គ្រួសារក្នុងការលក់ទ្រព្យសម្បត្តិ (NIPH និង NIS) ។ ៦០ភាគ
រយនៃគ្រួសារដែលគ្មានដីដែលបានសម្ភាសន៍ បានរាយការណ៍ឲ្យដឹងថា ពួកគាត់បានប្រើប្រាស់ដី
ផ្ទាល់ខ្លួនរបស់គាត់ និងបន្ទាប់មកបានលក់ដីនោះដើម្បីបង់ថ្លៃចំណាយលើការព្យាបាលជម្ងឺ
(Biddulph ២០០៤) ។ នៅក្នុងការសិក្សាមួយ បង្ហាញថា ថ្លៃចំណាយលើការថែទាំវេជ្ជសាស្ត្រ ជា
មូលហេតុចំបងមួយធ្វើអោយមានសកម្មភាពខ្ចីលុយចំនួន៣៦% ក្នុងចំណោមគ្រួសារចំនួន២៤០
នាក់ដែលចូលរួមក្នុងការសិក្សា (WAC ២០០៤)។ បំណុលគ្រួសារដើរតួជាកត្តាដែលជម្រុញអោយ
គ្រួសារលក់ទ្រព្យសម្បត្តិ ដែលមានផលិតភាពរបស់ខ្លួន រួមមានដីធ្លី និងសត្វពាហនៈដើម្បីបង់ថ្លៃ
ព្យាបាលជម្ងឺ (Kenfiro ២០០៥, Khun និង Manderson ២០០៨ )។

ការស្ទង់មតិគ្រួសារជាមូលដ្ឋានក្នុងទ្រង់ទ្រាយធំមួយ ត្រូវបានធ្វើឡើងក្នុងចំណោមគ្រួសារ
ចំនួន ៥៣២៣ ក្នុងប្រទេសកម្ពុជាតាមរយៈក្រុមហ៊ុនប្រឹក្សាយោបល់ និងស្រាវជ្រាវដំរី ក្នុងឆ្នាំ
២០១១។ ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់នូវគំរូបរិមាណតឹងរឹងមួយក្នុងការអង្កេតមើលលើ
បំណុលដែលពាក់ព័ន្ធនឹងការព្យាបាលជម្ងឺរបស់គ្រួសារ និងគ្រោះថ្នាក់សុខភាពក្នុងចំណោមប្រធាន
បទផ្សេងៗទៀត។ របកគំហើញបញ្ជាក់ឲ្យកាន់តែច្បាស់ពីភស្តុតាងពីការសិក្សាមុនៗ ពាក់ព័ន្ធនឹង
ភាពធ្ងន់ធ្ងរនៃបំណុលគ្រួសារ។ ៧៣ភាគរយនៃក្រុមគ្រួសារដែលបានធ្វើការសម្ភាសន៍ធ្លាប់បានជួប
ប្រទះនូវគ្រោះថ្នាក់លើសុខភាពម្តងក្នុងរយៈពេល ១២ ខែមុននេះ ៦៥ភាគរយមិនមានប្រាក់សន្សំ
គ្រប់គ្រាន់ និងច្រើនជាងពាក់កណ្តាលនៃក្រុមគ្រួសារ ដែលបានធ្វើការសម្ភាសន៍ពេលបច្ចុប្បន្ននេះ
កំពុងតែជំពាក់បំណុល។ ៨៦ភាគរយនៃកម្ចីដែលបានខ្ចីគឺប្រើដើម្បីចំណាយលើការព្យាបាល។
យុទ្ធសាស្ត្រដែលបានប្រើប្រាស់ក្នុងការបង់ការចំណាយលើការព្យាបាល រួមមានការប្រើប្រាស់
សាច់ប្រាក់ដែលមាន (៨២ភាគរយ) ខ្ចីប្រាក់ (២៦ភាគរយ) និងលក់ទ្រព្យសម្បត្តិ ។ តាមរបាយ
ការណ៍ ចំណាយលើការព្យាបាលជម្ងឺ គឺជាកត្តាដែលជម្រុញអោយមានការខ្ចីជាលើកទី មួយ ទីពីរ
និងទីបី (Domrei Research &Consulting ២០១១) ។ បន្ថែមពីលើនេះទៀត ការវាយតម្លៃលើផល
ប៉ះពាល់នៃទឹកជំនន់ឆ្នាំ២០១១ក្នុងចំណោមក្រុមគ្រួសារចំនួន៣៩០ បានរកឃើញថាបំណុលគឺជា
បញ្ហាលេចធ្លោ និង ចម្បងសម្រាប់សហគមន៍ក្រីក្រ។ មុនពេលទឹកជំនន់ក្នុងឆ្នាំ ២០១១ ៦៣ភាគ
រយនៃគ្រួសារត្រូវបានឲ្យដឹងថាជាប់បំណុលដែលមានស្រាប់ ។ ក្នុងចំណោមក្រុមគ្រួសារដែលបាន
ធ្វើការសម្ភាសន៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុគឺជាប្រភពផ្តល់កម្ចីទីមួយ ។ ជាលទ្ធផល ប្រហែលជា ៤៨

ភាគរយនៃក្រុមគ្រួសារដែលបានឲ្យដឹង គឺពួកគាត់បានទទួលកម្ចីថ្មីដែលជាលទ្ធផលនៃទឹកជំនន់ក្នុងឆ្នាំ ២០១១ ភាគច្រើនខ្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។ កម្ចីថ្មីទាំងនេះត្រូវបានរាយការណ៍ឲ្យដឹងថាត្រូវបានប្រើប្រាស់ក្នុងការវិនិយោគលើវិស័យកសិកម្ម អាហារ និងដើម្បីសងបំណុលដែលមានស្រាប់ (CARE ២០១២) ។ ភស្តុតាងពីការសិក្សាទាំងនេះ បញ្ជាក់ពីភាពងាយនឹងរងគ្រោះ ដែលគ្រួសារងាយនិងធ្លាក់ទៅក្នុងបំណុលយ៉ាងងាយស្រួលនៅពេលមានវិបត្តិកើតឡើង ដូចជា វិបត្តិសុខភាព ទិន្នផលស្រូវទាប ឬមហន្តរាយធម្មជាតិណាមួយកើតឡើង ។ ក្នុងការសិក្សាស្រាវជ្រាវនេះ យើងមានគោលបំណងក្នុងការអង្កេតឲ្យកាន់តែស៊ីជម្រៅអំពី ថាតើការព្យាបាលថៃទាំសុខភាព និង ការវិនិយោគលើវិស័យកសិកម្ម រួមចំណែកយ៉ាងដូចម្តេចទៅលើស្ថានភាពបំណុលក្នុងចំណោមគ្រួសារនៅតំបន់ជនបទ។

## ផ្នែកទី ២៖ វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចបាននូវកម្មវត្ថុទាំងអស់នេះ មានការប្រើប្រាស់ទាំងវិធីសាស្ត្រគុណភាព និង វិធីសាស្ត្រ បរិមាណ។ វិធីសាស្ត្រលម្អិតដែលបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបាន បញ្ជាក់ក្នុងផ្នែកខាងក្រោម។

### ២.១ ដំណើរការរៀបចំផែនការ និងវិធីសាស្ត្រ

ក. **ក្រុមសិក្សាស្រាវជ្រាវ៖** អ្នកសិក្សាស្រាវជ្រាវមួយក្រុមត្រូវបានបង្កើតឡើងដែលរួមមាន សមាជិកចំនួន ១០ រូប តំណាងឲ្យស្ថាប័នចំនួនប្រាំ៖ សេវាកម្មច្បាប់សម្រាប់សហគមន៍/ បណ្តាញការងារស្ត្រីរួបរួមគ្នា(WNU) ក្រុមជន្ត្រីយុវវ័យនាំសារ បណ្តាញភ្នំគុក [1] សមាគមកសិករឯករាជ្យដើម្បីការអភិវឌ្ឍន៍សហគមន៍(IFACD)ក្នុងខេត្តព្រៃវែង សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ(SAC) ជំនួយការស្រាវជ្រាវមួយរូប និងអ្នកស្រាវជ្រាវមួយរូប។ សមាជិកភាគច្រើនមានបទពិសោធន៍ និងជំនាញក្នុងការធ្វើការនៅតាមសហគមន៍ ដែលនេះរួមចំនែកយ៉ាងសំខាន់ដល់ការយល់ដឹងយ៉ាងលម្អិតពីស្ថានភាពគ្រួសារតាមជនបទ។ ការសិក្សាស្រាវជ្រាវនេះ ក៏បានគិតគូរពីដំណើរការដែលសម្រួលដល់ការកសាងទំនុកចិត្ត និងការកសាងចំនេះដឹងដល់ក្រុមសិក្សាស្រាវជ្រាវ ហើយតាមរយៈមូលដ្ឋាននេះ ពួកគាត់អាចរួមចំនែកយ៉ាងសកម្មក្នុងដំណើរការ និងការវិភាគនៃរបកគំហើញ។

ខ. **ទីតាំងនៃការសិក្សាស្រាវជ្រាវ៖** យោងទៅតាមកិច្ចសហការការងារដែលមាន សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ បានជ្រើសរើសខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែងជាទីតាំងសិក្សាស្រាវជ្រាវ។ ក្នុងខេត្តកំពង់ឆ្នាំង សកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរបានសហការជាមួយនឹង AEC និងបណ្តាញភ្នំគុក និង នៅក្នុងខេត្តព្រៃវែង COFAP និង IFACD បានជួយសម្រួលដល់ការប្រមូលទិន្នន័យនូវមូលដ្ឋាន។ តារាង ១ បញ្ជាក់ពិស្តារពីទីតាំងភូមិចំនួនប្រាំមួយដែលទិន្នន័យត្រូវបានប្រមូល។

[1] បណ្តាញភ្នំគុកជាបណ្តាញមូលដ្ឋានដែលផ្តោតសំខាន់លើការតស៊ូមតិសហគមន៍ស្តីពីសិទ្ធិដីធ្លី ព្រៃឈើ និងការទាញយកធនធានធម្មជាតិ។ បណ្តាញនេះបំពេញការងារលើបញ្ហាទាំងនេះក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ដែលជាទីតាំងរបស់បណ្តាញភ្នំគុក (តាមន័យត្រង់គឺភ្នំគុក)

*តារាង ១៖ ទីតាំងភូមិដែលធ្វើការសិក្សាស្រាវជ្រាវ*

| ខេត្ត | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|
| កំពង់ឆ្នាំង | បរិបូរណ៍ | ពេជ្យសង្វារ | តាំងត្រពាំង |
| | | ត្រពាំងចាន់ | សន្លាង |
| ព្រៃវែង | បាភ្នំ | បឹងព្រះ | អង្គក្រុង |
| | | បឹងព្រះ | តាជ័យ |
| | ស្វាយអន្ទរ | ដំរីពួន | បន្ទាយស្រែ |
| | | ដំរីពួន | ត្រពាំងព្រីង |
| **សរុប** | ៣ | ៤ | ៦ |

**គ.** **វគ្គបណ្តុះបណ្តាលអំពីការសិក្សាស្រាវជ្រាវ៖** ក្រុមសិក្សាស្រាវជ្រាវបានទទួលវគ្គបណ្តុះបណ្តាលរយៈពេលមួយថ្ងៃអំពីទិដ្ឋភាពទូទៅនៃការស្រាវជ្រាវ និងឧបករណ៍សំខាន់ៗដែលបានប្រើប្រាស់ក្នុងការបណ្តុះបណ្តាល។ កម្រងសំនួរត្រូវបានពិភាក្សាយ៉ាងម៉ត់ចត់ដើម្បីស្វែងយល់ពីហេតុផលនៃសំណួរនីមួយៗ។ បន្ទាប់ពីការបណ្តុះបណ្តាលកម្រងសំណួរត្រូវបានសាកល្បងនៅមូលដ្ឋានក្នុងចំណោមគ្រួសារចំនួន ដប់ (១០) នៅក្នុងភូមិចំនួនពីរនៃខេត្តកំពង់ស្ពឺ។ បន្ទាប់ពីការសួរសាកល្បង មានការកែប្រែបន្តិចបន្តួចទៅលើកម្រងសំណួរ។

## ២.២ ឧបករណ៍ប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងក្នុងពីរដំណាក់កាល ។ ក្នុងដំណាក់កាលទី ១ កម្រងសំណួរ ជាមួយនឹងសំណួរដែលបានតាក់តែងឡើងចំនួន ប៉ែតសិប (៨០) ត្រូវបានរៀបចំឡើង (សូមពិនិត្យ ឧបសម្ព័ន្ធ I ) ។ សំណួរត្រូវបានដាក់លេខកូដ ហើយមានរៀបចំសំណួរជ្រើសរើស និងចម្លើយខ្លី ។ ដើម្បីជៀសវាងការសួរសំណួរដដែលដូចនឹងសំណួរដែលបានសួរ និង មានចម្លើយរួចហើយនៅក្នុងការសិក្សាស្រាវជ្រាវមុនៗ ការបង្កើតកម្រងសំណួរនេះ ក៏បានមើលទៅលើសំណួរមួយចំនួនដែលបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវពីមុនៗ ដូចជាសំនួរដែលបានប្រើក្នុងការស្ទង់មតិមូលដ្ឋានរបស់ក្រុមហ៊ុនប្រឹក្សាដំរី[2]ជាដើម ។ នៅក្នុងដំណាក់កាលទី២ ទិន្នន័យបែបគុណភាពនឹងត្រូវបានប្រមូលតាមរយៈការសម្ភាសន៍បែបស៊ីជំរៅជាមួយនឹងអ្នកភូមិ និងអ្នកពាក់ពន្ធ័មួយចំនួន ។ សំណួរនាំមុខត្រូវបានបង្កើតឡើងបន្ទាប់ពីសិក្ខាសាលារយៈពេលមួយថ្ងៃនៃបទបង្ហាញពីលទ្ធផលបឋមនៃដំណាក់កាលទី I ។ ក្រុមស្រាវជ្រាវបានវិភាគ និងបង្កើតសំណួររួមគ្នាដើម្បីរិះរកនូវ

[2] ក្រុមហ៊ុនប្រឹក្សាយោបល់ និងស្រាវជ្រាវ ឆ្នាំ ២០១១។ ការសិក្សាស្រាវជ្រាវមូលដ្ឋាន SKY។

និទ្ទាការនៃចម្លើយ។ សូមពិនិត្យមើលឧបសម្ព័ន្ធ II ដែលមាននូវសំណួរនាំមុខដែលបានប្រើប្រាស់ក្នុងការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធ និងអ្នកភូមិ។

## ២.៣ គំរូ

ក្នុងដំណាក់កាលទី I ការសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវបច្ចេកទេសក្នុងការជ្រើសរើសគម្រូផ្អែកលើវត្ថុបំណងក្នុងការប្រមូលទិន្នន័យ ។ ក្នុងភូមិនីមួយៗ ដំណើរការជ្រើសរើសត្រូវបានអនុវត្តដូចខាងក្រោមៈ

*ដំណាក់ទី I៖ ការវាយតម្លៃឆាប់រហ័ស*

ក. អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីប្រជាជនសរុបក្នុងភូមិនីមួយៗពីប្រធានភូមិ។

ខ. ប្រហែលជា ១០ភាគរយ នៃគ្រួសារក្នុងភូមិត្រូវបានជ្រើសរើសដើម្បីធ្វើការវាយតម្លៃរហ័ស។

គ. គ្រួសារត្រូវបានជ្រើសរើសដោយផ្អែកលើភាពងាយស្រួលៈ ពួកគាត់មានពេលទំនេរ និងព្រមព្រៀងជួបដើម្បីផ្តល់បទសម្ភាសន៍។

*ដំណាក់កាល II៖ ការសម្ភាសន៍ស៊ីជម្រៅ៖* ប្រើតារាងប្រសព្វក្នុងប្រព័ន្ធវិភាគទិន្នន័យ SPSS ធ្វើការកំណត់គ្រួសារដើម្បីធ្វើការសម្ភាសន៍។ យ៉ាងហោចណាស់ គ្រួសារចំនួន បីគ្រួសារ ត្រូវបានជ្រើសរើសពីភូមិនីមួយៗប្រសិនបើពួកគាត់ ៖ ក) ពេលបច្ចុប្បន្នកំពុងជាប់បំណុល ; ខ) ធ្លាប់ជាប់បំណុលដោយសារការខ្ចីសម្រាប់សងថ្លៃព្យាបាលជម្ងឺ។

គ្រួសារសរុបចំនួន ១៣៣ គ្រួសារត្រូវបានធ្វើការស្ទង់មតិក្នុងដំណាក់កាលទី I ។ គ្រួសារចំនួន ២២ គ្រួសារដែលបានចូលរួមក្នុងដំណាក់កាលទី I ត្រូវបានធ្វើការសម្ភាសន៍ស៊ីជម្រៅនៅក្នុងដំណាក់កាលទី II ។ បន្ថែមពីលើនេះទៀត ក្រុមសិក្សាស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន (ថ្នាក់ដឹកនាំភូមិ មេឃុំ ក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រី និងកុមារ) មន្ត្រីការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទក្នុងស្រុកនីមួយៗ មន្ត្រីសុខាភិបាល តំណាងធនាគារ/ស្ថាប័នមីក្រូហិរញ្ញវត្ថុ អ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ និងក្រុមសន្សំ និងអ្នកផ្តល់ព័ត៌មានក្នុងតំបន់ ។ សូមពិនិត្យឧបសម្ព័ន្ធ III តារាងនៃភាគីពាក់ព័ន្ធ។

## ២.៤ ការប្រមូលទិន្នន័យ

- ការប្រមូលទិន្នន័យបន្ទាប់បន្សំ៖ ការពិនិត្យស្វែងរកឯកសារត្រូវបានធ្វើឡើងដើម្បីធ្វើការប្រមូលព័ត៌មានដែលមានស្រាប់អំពីការចំណាយលើការព្យាបាលជម្ងឺ និងបំណុលនៅជនប

ទ។ ការពិនិត្យលើការសិក្សាដែលមានស្រាប់ ជួយដល់ដំណើរការបង្កើតសំណួរសិក្សាស្រាវជ្រាវ។

- ការប្រមូលទិន្នន័យបឋមៈ ដំណាក់កាលទី I នៃការវាយតម្លៃរហ័សត្រូវបានធ្វើឡើងក្នុងខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែងក្នុងខែ កុម្ភៈ ឆ្នាំ ២០១៤។ ដំណាក់កាលទី II នៃការធ្វើការសម្ភាសន៍ស៊ីជម្រៅ (ជាមួយគ្រួសារ & ភាគីពាក់ព័ន្ធ) ត្រូវបានធ្វើឡើងក្នុងខេត្តកំពង់ឆ្នាំងនៅចុងខែមេសា និងនៅក្នុងខេត្តព្រៃវែងនៅដើមខែ ឧសភា ឆ្នាំ ២០១៤។

***តារាងលេខ ២៖ ចំនួនគ្រួសារតាមភូមិ***

| ខេត្ត | ភូមិ | ការស្ទង់មតិគ្រួសារ | បទសម្ភាសន៍ស៊ីជម្រៅលើគ្រួសារ |
|---|---|---|---|
| កំពង់ឆ្នាំង | តាំងត្រពាំង | ១៧ | ២ |
| | សន្លាង | ៣០ | ៣ |
| ព្រៃវែង | អង្គក្រុង | ២៨ | ៤ |
| | តាជ័យ | ២៨ | ៥ |
| | បន្ទាយស្រែ | ១៩ | ៣ |
| | ត្រពាំងព្រីង | ១១ | ៥ |
| **សរុប** | **៦** | **១៣៣** | **២២** |

- ការគណនាទិន្នន័យៈ ទិន្នន័យដែលទទួលបានតាមរយៈកម្រងសំណួរត្រូវបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យដែលប្រើកម្មវិធី SPSS ។ មាន អថេរ ចំនួន ៣១១ ត្រូវបានបង្កើតឡើងដើម្បីផ្ទុកព័ត៌មាន។ ទិន្ន័យទាំងអស់ក្នុងកម្រងសំណួរត្រូវបានបញ្ចូល សម្អាត និងវិភាគតាមលក្ខណៈស្ថិតិ។ ជំនួយការសិក្សាស្រាវជ្រាវជាអ្នកទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យដោយមានការត្រួតពិនិត្យផ្ទាល់ពីអ្នកសិក្សាស្រាវជ្រាវ ។ ទិន្នន័យពីការសម្ភាសន៍ស៊ីជម្រៅត្រូវបានវាយបញ្ចូលដោយផ្អែកលើការសម្ភាសន៍បុគ្គលផ្ទាល់។

## ២.៥ ការការពារអត្តសញ្ញាណនៃអ្នកចូលរួមក្នុងការសិក្សា

អ្នកចូលរួមក្នុងការសិក្សាទាំងអស់ បានផ្តល់ការព្រមព្រៀងដោយផ្ទាល់មាត់លើការវាយតម្លៃឆាប់រហ័សតាមរយៈកម្រងសំណួរ និង ការព្រមព្រៀងជាលាយលក្ខអក្សរលើការសម្ភាសន៍ស៊ីជម្រៅ។ ឈ្មោះរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំងអស់ដែលត្រូវបានប្រើប្រាស់ក្នុងរបាយការណ៍នេះ ត្រូវបានបង្កើតឡើងដើម្បីការពារអត្តសញ្ញាណពិតប្រាកដរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំងអស់ ។ សូមពិនិត្យមើលឧបសម្ព័ន្ធ IV លើឯកសារព្រមព្រៀង។

# ផ្នែកទី ៣៖ របកគំហើញសំខាន់ៗ

ផ្នែកនេះនឹងធ្វើការរាយការណ៍ពីរបកគំហើញសំខាន់ៗដែលបានមកពីការវាយតម្លៃឆាប់រហ័ស និងការសម្ភាសន៍ស៊ីជម្រៅជាមួយនឹងអ្នកភូមិ ។ ផ្នែកនេះត្រូវបានចែកចេញជាផ្នែករងចំនួនបួន៖ ចរិតលក្ខណៈសង្គមសេដ្ឋកិច្ចនៃគ្រួសារដែលបានស្ទង់មតិ ទិន្នផលស្រូវ ការជាប់បំណុលរបស់គ្រួសារ និងផលប៉ះពាល់នៃបំណុល និងយន្តការដោះស្រាយរបស់គ្រួសារ។

## ៣.១ ចរិតលក្ខណៈ សង្គមសេដ្ឋកិច្ចរបស់គ្រួសារដែលបានធ្វើការស្ទង់មតិ

### ក. ចរិតលក្ខណៈរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានសម្ភាសន៍គ្រួសារសរុបចំនួន ១៣៣ គ្រួសារតាមរយៈការស្ទង់មតិគ្រួសារ ។ គ្រួសារចំនួន ២២ ដែលជាផ្នែកនៃការសម្ភាសន៍ត្រូវបានធ្វើការសម្ភាសន៍ស៊ីជម្រៅ ។ ក្នុងចំណោម ១៣៣ គ្រួសារ អ្នកចូលរួមចំនួន ១០៦រូប គឺជាស្ត្រី និង ២៧រូបជាបុរស។ ក្នុងរូបភាពទី ១ បានបែងចែកអ្នកចូលរួមផ្តល់បទសម្ភាសន៍ទៅតាមអាយុ ។ អាយុជាមធ្យមនៃអ្នកចូលរួមផ្តល់សម្ភាសន៍គឺ ៤៦.៩ ឆ្នាំ អ្នកចូលរួមផ្តល់សម្ភាសន៍ដែលក្មេងបំផុតគឺមានអាយុ ១៧ ឆ្នាំ និងចំណាស់បំផុតគឺ ៨៥ ឆ្នាំ។ អ្នកចូលរួមផ្តល់បទសម្ភាសន៍ក្នុងចន្លោះអាយុ ៣៥-៥០ និង អាយុច្រើនជាង ៥០ ឆ្នាំ តំណាងឲ្យសមាមាត្រខ្ពស់ជាងគេនៃអ្នកចូលរួមក្នុងការសិក្សានេះ គឺ ចំនួន ៣៥ភាគរយ និង ៣៨ភាគរយ។

*រូបភាពទី១៖ អាយុរបស់អ្នកចូលរួមផ្តល់សម្ភាសន៍*



៦២ភាគរយ (n=៨៣) នៃអ្នកចូលរួមផ្តល់បទសម្ភាសន៍ដែលបានស្ទង់មតិ មានសមាជិកគ្រួសារចន្លោះពី ៥ ដល់ ១០ នាក់ក្នុងគ្រួសាររបស់ពួកគេ ។ គួរឲ្យកត់សម្គាល់ មានតែគ្រួសារមួយតែប៉ុណ្ណោះដែលមានសមាជិកច្រើនជាង ១០រូប ។ តារាងលេខ ៣ បង្ហាញលម្អិតពីភាគរយនៃប្រជាជនដែលបានធ្វើការស្ទង់មតិទៅតាមចំនួនសមាជិកគ្រួសារ។

*រូបភាពលេខ ៣៖ ចំនួនសរុបនៃសមាជិកគ្រួសារ*

| សមាជិកគ្រួសារ | # គ្រួសារ | ភាគរយ |
|---|---|---|
| < ៥ នាក់ | ៤៩ | ៣៦,៨ |
| ៥ – ១០ នាក់ | ៨៣ | ៦២,៤ |
| > ១០ នាក់ | ១ | ០,៨ |
| **សរុប** | **១៣៣** | **១០០** |

## ខ. កម្មសិទ្ធិលើផ្ទះសម្បែង និងដីធ្លី

៩៧ភាគរយ នៃគ្រួសារដែលបានធ្វើការស្ទង់មតិ (n=១២៩) មានដីលំនៅដ្ឋានក្នុងភូមិដែលពួកគាត់មានផ្ទះនៅលើដីនោះ ហើយ៣ភាគរយ (n=៤) គឺមិនមាន។ របកគំហើញបង្ហាញថា ចំពោះគ្រួសារដែលបច្ចុប្បន្នមិនមានដីលំនៅដ្ឋាន ពួកគាត់រស់នៅជាមួយសាច់ញាតិ ឬកូនៗ ។ មានចំនួន ៥ភាគរយនៃគ្រួសារ (n=៧) មានដីលំនៅដ្ឋានពីរកន្លែង ហើយមានគ្រួសារចំនួនមួយតែប៉ុណ្ណោះដែលមានដីលំនៅដ្ឋានបីកន្លែង។

*រូបភាពទី ២៖ កម្មសិទ្ធិដីលំនៅដ្ឋាន*




*រូបភាពទី ៣៖ ប្រភេទផ្ទះរបស់អ្នកចូលរួមផ្តល់សម្ភាសន៍*



រូបភាពទី ៣ បានបែងចែកផ្ទះរបស់អ្នកចូលរួមផ្តល់សម្ភាសន៍ទៅតាមប្រភេទ។ ដូចដែលបន្ទាត់បានបង្ហាញ ផ្ទះដែលមានដំបូលស័ង្កសី និងជញ្ជាំងស្លឹកមាន ២៩.៣ ភាគរយ (n=៣៩) ផ្ទះដែលមានដំបូលក្បឿង និងជញ្ជាំងឈើមាន ២២ភាគរយ (n=២៩) ហើយផ្ទះដែលមានដំបូលក្បឿងនឹងជញ្ជាំងស៊ីម៉ង់មាន ១៦ភាគរយ (n=២១) នៃគ្រួសារដែលបានធ្វើការស្ទង់មតិ។ យោងទៅតាមការអង្កេតទូទៅ មានផ្ទះជាច្រើនដែលទើបតែបានសង់ថ្មីៗក្នុងភូមិ ជាពិសេសក្នុងខេត្តព្រៃវែង។ យ៉ាងណាមិញ មានសមាជិកគ្រួសារមួយចំនួនតូចកំពុងរស់នៅក្នុងផ្ទះទាំងនោះលើកលែងតែជនចាស់ជរា និងកុមារ ចំនែកយុវវ័យភាគច្រើនបានចំណាកស្រុកទៅកាន់ទីក្រុងភ្នំពេញ តំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ឬប្រទេសថៃដើម្បីប្រកបការងារ។

## គ. ប្រភពនៃចំណូលគ្រួសារ

៩៦ភាគរយ (n=១២៧) នៃគ្រួសារដែលបានធ្វើការស្ទង់មតិ ប្រកបរបរធ្វើស្រែដែលជាប្រភពចម្បងនៃប្រាក់ចំណូល ។ គ្រួសារផ្សេងៗទៀត មិនធ្វើស្រែទេ ដោយសារមិនមានដីស្រែ ឬមានដីស្រែតិច។ ក្រៅពីការប្រកបរបរធ្វើស្រែ ការចិញ្ចឹមសត្វ ការចំណាកស្រុកទៅរកការងារតាមរដូវកាល ដូចជាការងារសំណង់ ការងាររោងចក្រ ឬ ទៅធ្វើការងារក្នុងចំការដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជា នៅតាមបណ្តោយព្រំដែនប្រទេសថៃ ឬក្នុងប្រទេសថៃ ចាត់ទុកថាជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលបន្ថែមរបស់គ្រួសារ។ ពាក់ព័ន្ធជាមួយនឹងការចិញ្ចឹមសត្វ ដូចដែលបានបង្ហាញក្នុងរូបភាពទី ៤, ៨៤ភាគរយ (n=១១២) នៃគ្រួសារដែលបានធ្វើការស្ទង់មតិ ប្រកបរបរចិញ្ចឹមមាន់ ៤៥ភាគរយចិញ្ចឹមគោ/មេគោ ចំនែកការចិញ្ចឹម ទា ជ្រូក ក្របី គឺមានចំនួន ៣០ភាគរយ ឬតិចជាងនេះ។

*រូបភាពទី ៤៖ ការចិញ្ចឹមសត្វពាហនៈក្នុងគ្រួសារដែលបានស្ទង់មតិ*



## ឃ. ទ្រព្យសម្បត្តិ និងការសន្សំរបស់គ្រួសារ

*រូបភាពទី ៥៖ ទ្រព្យសម្បត្តិគ្រួសារ*




រូបភាពទី ៥ សង្ខេបពីតារាងទ្រព្យសម្បត្តិរបស់គ្រួសារដែលបានស្ទង់មតិ នៅពេលធ្វើការវាយតម្លៃ។ ទ្រព្យសម្បត្តិជាទូទៅដែលជាកម្មសិទ្ធិរបស់គ្រួសារភាគច្រើន រួមមានកង់ (៨៣ភាគរយ) ទូរស័ព្ទដៃ(៨០ភាគរយ) អាគុយ (៦៩ភាគរយ) ម៉ូតូ(៥០ភាគរយ) ទូរទសន៍(៤៩ភាគរយ) ។ ទ្រព្យសម្បត្តិផ្សេងទៀតមានដូចជាវិទ្យុ គោក្របី ទូក គោយន្ត ឬម៉ាស៊ីនប៊ូមទឹក គឺជាកម្មសិទ្ធិរបស់គ្រួសារមានចំនួនតិចជាង ៤០ភាគរយនៃគ្រួសារដែលបានធ្វើការស្ទង់មតិ។

ចំពោះការសន្សំរបស់គ្រួសារសម្រាប់ជាយន្តការមួយក្នុងការដោះស្រាយហេតុការណ៍ចៃដន្យ គ្រួសារចំនួនប្រហែលជាមួយភាគបី (៣៦ភាគរយ n=៤៨) នៃអ្នកចូលរួមផ្តល់ការសម្ភាសន៍បានឲ្យដឹងថាពួកគេមានការសន្សំខ្លះ ។ អ្នកចូលរួមផ្តល់សម្ភាសន៍មួយចំនួន ជាពិសេសអ្នកដែលមកពីភូមិក្នុងខេត្តកំពង់ឆ្នាំងបានចូលរួមក្នុងក្រុមសន្សំសហគមន៍ដែលសន្សំប្រាក់តិចតួចប្រចាំខែ ឬប្រចាំត្រីមាស ។ ចំនួននៃប្រាក់សន្សំខុសៗគ្នា ដែលក្នុងនោះចំនួនតិចបំផុតគឺ៤០០០ រៀល (១USD) និងច្រើនបំផុតគឺ ៤០០០ ០០០ រៀល (១០០០ ដុល្លារ) ។ អ្នកស្រាវជ្រាវមានការលំបាកក្នុងការទទួលបាននូវចំនួនពិតប្រាកដនៃការសន្សំដែលគ្រួសារនីមួយៗមានដោយសារហេតុផលព័ត៌មានឯកជន។ យើងបានស្វែងយល់បន្ថែមទៀត ថាតើគ្រួសារដែលបានស្ទង់មតិអាចផ្តល់កម្ចីដល់ក្រុមគ្រួសារដែលត្រូវការថវិការដែរឬទេ នៅពេលដែលពួកគាត់មានការសន្សំ ។ មានអ្នកចូលរួមផ្តល់សម្ភាសន៍ចំនួនត្រឹមតែ ៧.៥ ភាគរយ (n=១០) ប៉ុណ្ណោះឆ្លើយថាពួកគេអាចផ្តល់កម្ចីបន្តិចបន្តួចប្រសិនបើគ្រួសារទាំងនោះមកខ្ចី។

អ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងការសិក្សានេះ ភាគច្រើនជាកសិករធ្វើស្រែដែលពឹងផ្អែកលើប្រាក់ចំណូលពីការប្រមែប្រមូលផលស្រូវ និងប្រាក់បញ្ញើរដែលបានមកពីពលករចំណាកស្រុក ដើម្បីជួយទ្រទ្រង់ការចំណាយប្រចាំថ្ងៃ និងការចំណាយក្នុងហេតុការផ្សេងៗដែលគ្រួសារជួបប្រទះ ។ មួយភាគតូចនៃគ្រួសារក្នុងចំណោមប្រជាជនដែលបានធ្វើការសិក្សា ប្រកបរបរអាជីវកម្មធុនតូច ដូចជាហាងគ្រឿងទេស ប្រមូលទិញនឹងលក់អុស កម្មករស៊ីឈ្នួល ឬអ្នកលក់ចំណីអារហារនៅក្នុងភូមិ។

## ៣.២ ការផលិតស្រូវ

យោងទៅតាមលទ្ធផលនៃការស្ទង់មតិ សូមពិនិត្យមើលរូបភាពទី ៦, ៩៣ភាគរយ នៃអ្នកចូលរួមផ្តល់សម្ភាសន៍ ពេលបច្ចុប្បន្នមានដីស្រែ និង ៦.៨ ភាគរយ មិនមានដីស្រែទេ ។ ៥៩ភាគរយ នៃអ្នកចូលរួមផ្តល់សម្ភាសន៍ដែលមានដីស្រែ គឺដីស្រែទាំងនោះមានទំហំចន្លោះពីកន្លះទៅមួយហិចតា។ ប្រហែលជា ១៦ភាគរយ នៃអ្នកចូលរួមផ្តល់សម្ភាសន៍មានដីស្រែដែលតូចជាងកន្លះហិចតា។ មានគ្រួសារតែចំនួនបួនប៉ុណ្ណោះក្នុងការស្ទង់មតិដែលមានដីស្រែធំជាងពីរហិចតា ។ ដោយភាគច្រើននៃគ្រួសារមានដីស្រែតិច វាមានភាពប៉ះពាល់ខ្លាំងមកលើលទ្ធភាពរបស់គ្រួសារក្នុងការទទួលបានស្រូវគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារ ហើយបញ្ហានេះនិងត្រូវលើកយកមកពិភាក្សានាពេលក្រោយ។

*រូបភាពទី ៦៖ កម្មសិទ្ធិដីស្រែ*




៩៤ ភាគរយនៃគ្រួសារដែលបានធ្វើការស្ទង់មតិ បានដាំដុះស្រូវក្នុងរដូវធ្វើស្រែចុងក្រោយនេះ ហើយតួលេខនេះស្របគ្នានឹងចំនួនគ្រួសារដែលពេលបច្ចុប្បន្នមានកម្មសិទ្ធិដីស្រែ ។ ៣៤.៦ភាគរយ (n=៤៦) នៃអ្នកចូលរួមផ្តល់សម្ភាសន៍ដែលបានដាំដុះស្រូវក្នុងរដូវធ្វើស្រែចុងក្រោយនេះ បានឲ្យដឹងថាពួកគាត់រក្សាទិន្នផលស្រូវទាំងអស់សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ។ ប៉ុន្តែ គ្រួសារ៦០ភាគរយ (n=៨០) ទៀតបានឲ្យដឹងថាពួកគាត់បានទុកស្រូវមួយចំនួន

សម្រាប់ចិញ្ចឹមគ្រួសារ និងមួយចំនួន សម្រាប់លក់។ ចំពោះអ្នកចូលរួមផ្តល់សម្ភាសន៍ដែលបានលក់ស្រូវរបស់ពួកគាត់ក្នុងរដូវធ្វើស្រែចុងក្រោយនេះ តម្លៃដែលពួកគាត់បានទទួលគឺចន្លោះពី ៧០០រៀល ដល់ ១៥០០ រៀលក្នុងមួយគីឡូ ទៅតាមប្រភេទស្រូវ ។ គួរឲ្យកត់សម្គាល់ តម្លៃពូជស្រូវក្នុងស្រុក គឺជាទូទៅថោកជាងប្រភេទស្រូវដែលបានផ្សព្វផ្សាយដោយរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងនាំចេញដូចជាស្រូវផ្ការំដួលជាដើម។

**ប្រអប់ I: ប្រភេទស្រូវទាំង ១០ប្រភេទដែលបានផ្សព្វផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា**

រយៈពេលខ្លី: សែនពិដោរ ជលសារ និង អ៊ីអែ ៦៦

រយៈពលល្មម: ផ្ការំដួល ផ្ការមៀត ផ្កាចាន់សែនសរ ផ្ការំដេង

រយៈពេលវែងៈរាំងជ័យ ខា៤ និងខា៦

ប្រភពៈ (ចាន់ ២០១១)

យោងទៅតាមទស្សនៈរបស់រដ្ឋាភិបាល ដោយផ្តោតសំខាន់ទៅលើការនាំចេញស្រូវ និងអង្ករ រាជរដ្ឋាភិបាលបានធ្វើការកំណត់ និងផ្សព្វផ្សាយតារាងនៃប្រភេទស្រូវចំនួន ១០ប្រភេទ ដែលខ្លួនបានលើកទឹកចិត្តកសិករក្នុងការដាំដុះ។ ប្រភេទស្រូវទាំងនេះមានប្រជាប្រិយភាពលើទីផ្សារអន្តរជាតិ និងអាចប្រមូលផលបានក្នុងរយៈពេលពីបីខែ ទៅប្រាំមួយខែ ។ (សូមពិនិត្យមើលប្រអប់ទី ១ លើប្រភេទស្រូវដែលបានផ្សព្វផ្សាយដោយរដ្ឋាភិបាលកម្ពុជា) ។ តាមរយៈការសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ បានអោយដឹងថា ប្រភេទស្រូវទាំងនេះត្រូវបានផ្សព្វផ្សាយឲ្យកសិករធ្វើការដាំដុះ ។ ប៉ុន្តែដោយសារតែថវិការសម្រាប់ធ្វើការផ្សព្វផ្សាយអំពីកសិកម្មរបស់ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុកនៅមានកម្រិត (នឹងមានការពិភាក្សាក្នុងផ្នែកបន្ទាប់) ធ្វើអោយទំហំនៃការផ្សព្វផ្សាយទៅដល់កសិករ នៅមិនទាន់បានទូលំទូលាយនៅឡើយ ។ កសិករមួយចំនួនដែលបានផ្តល់បទសម្ភាសន៍ក្នុងការសិក្សាស្រាវជ្រាវ បានរំលឹកពីប្រភេទស្រូវមួយចំនួនដូចជារំដួល ឬខា៤ ខា៦ដែលពួកគាត់បានធ្វើការផ្លាស់ប្តូរទៅវិញទៅមកក្នុងការដាំដុះញឹកញាប់ ខណៈដែលកសិករមួយចំនួនទៀតមិនទាន់បានយល់ដឹងពីប្រភេទស្រូវទាំងនេះនៅឡើយ។ ការបាត់បង់ពូជស្រូវប្រពៃណីដោយសារតែពូជថ្មី តាមការលើកឡើងក្នុងអំឡុងពេលសម្ភាសន៍ជាមួយបុគ្គលិកការិយាល័យកសិកម្មស្រុក ក្នុងនោះមានការលើកឡើងថាពូជស្រូវប្រពៃណីគឺចាញ់អាកាសធាតុ និងមានទិន្នផលទាប។ រដ្ឋាភិបាលកម្ពុជាលើទឹកចិត្តកសិករឲ្យធ្វើការដាំដុះប្រភេទស្រូវជាង

១០មុខ ជាមួយនឹងបច្ចេកទេសដែលបានធ្វើការផ្សព្វផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### គ. ការប្រមូលផលស្រូវ

មានត្រឹមតែ ៤២ភាគរយ (n=៥៦) នៃអ្នកចូលរួមផ្តល់ការសម្ភាសន៍តែប៉ុណ្ណោះបានឲ្យដឹងថា ផលស្រូវដែលខ្លួនបានប្រមូល គឺគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារបានពេញមួយឆ្នាំ ។ ៥៣ភាគរយ (n=៧០) បានឲ្យដឹងថាមិនគ្រប់គ្រាន់នោះទេ ។ ក្នុងចំណោមគ្រួសារដែលប្រាប់ថាផលស្រូវមិនគ្រប់គ្រាន់ ១៨ភាគរយ (n=២៤) នៃពួកគាត់បានបញ្ជាក់ថា ពួកគាត់មានស្រូវសម្រាប់ហូបបានរយៈពេលប្រាំមួយខែ ។ ១៦.៦ភាគរយ បានឲ្យដឹងថាមានស្រូវសម្រាប់ហូបបានរយៈពេល ពី ៧ ដល់ ៩ខែ ។ ពួគាត់ប្រាប់ថា នៅពេលអស់ស្រូវ ពួកគាត់ពឹងផ្អែកទៅលើប្រាក់ចំណូលពីការងារស៊ីឈ្នួលលើវាលស្រែ ឬការងារសំណង់ ឬប្រាក់បញ្ញើរពីសមាជិកគ្រួសារដើម្បីទិញអង្ករបរិភោគ។

> *ពួកយើងមានស្រែកន្លះហិចតាសម្រាប់ធ្វើការដាំដុះស្រូវវស្សា ។ ក្នុងឆ្នាំ ២០១៣ ពួកយើងបានស្រូវប្រហែលជា ៥០ ទៅ ៦០ថាំង គឺប្រហែលជា ១១០០ kg ។ ខ្ញុំបានសម្រេចចិត្តក្នុងការទុកស្រូវទាំងអស់ដើម្បីប្រើប្រាស់ក្នុងគ្រួសារ ។ យ៉ាងណាមិញ ចំនួននេះមិនទាន់គ្រប់គ្រាន់រហូតដល់ការប្រមូលផលលើកក្រោយនោះទេ។ មានការខ្វះខាតស្រូវប្រហែលជា ២ ទៅ ៣ខែក្នុងគ្រួសាររបស់ខ្ញុំ ហើយខ្ញុំពឹងផ្អែកលើប្រាក់បញ្ញើររបស់កូនស្រីពីការងាររោងចក្ររបស់នាងដើម្បីទិញអង្ករ និងចំណីអាហារ។ នាងតែងតែផ្ញើរប្រាក់ ៥០ដុល្លារជារៀងរាល់ខែប្រសិនបើនាងមិនឈឺថ្កាត់ ។* បទសម្ភាសន៍ជាមួយសុខា ថ្ងៃ ៨ ខែឧសភា ឆ្នាំ ២០១៤ ក្នុងខេត្តព្រៃវែង។

ទោះបីជាការរក្សាទុកទិន្នផលស្រូវសម្រាប់ទ្រទ្រង់ជីវភាពអោយបានគ្រប់គ្រាន់គឺជារឿងសំខាន់ក៏ដោយ ក៏ស្ថានភាពរបស់គ្រួសារនីមួយៗមិនជានិច្ចជាកាលអាចអោយពួកគេធ្វើដូចនេះបាននោះទេ ។ ចំនួនគ្រួសារជាច្រើននាក់ដែលមាននៅក្នុងការអង្កេត និងនៅក្នុងការសម្ភាសន៍ស៊ីជម្រៅបានឲ្យដឹងថា ពួកគាត់បានបង្ខំចិត្តលក់ទិន្នផលស្រូវមួយចំនួនដើម្បីទូទាត់ការចំណាយលើការដាំដុះ ដូចជាជីគីមី ថ្លៃសេវាគ្រឿងចក្រក្នុងការប្រមូលផល ឬថ្លៃពលកម្ម។ នេះបើតាមការរាយការណ៍មកពីគ្រួសារចំនួន ៣៦ភាគរយ (n=៤៨) នៃអ្នកចូលរួមផ្តល់សម្ភាសន៍អំពីការប្រើប្រាស់ថវិកាពីការលក់ស្រូវ (សូមពិនិត្យមើលរូបភាពទី ៧) ។ ៣៣ភាគរយ (n=៤៤) នៃអ្នកចូលរួមបានឲ្យដឹងថា ពួកគាត់បានចំណាយថវិកាលើចំណីអាហារ/ការចំណាយប្រចាំថ្ងៃ ហើយ៨ភាគរយទៀតបាននិយាយថាពួកគាត់ប្រើប្រាស់ថវិកាក្នុងការសងបំណុល ។ ការទិញជីគីមីដោយជំពាក់ ធ្វើអោយតម្លៃជីខ្ពស់ជាងពី ៥ ទៅ ១០ដុល្លារក្នុងមួយបាវ នេះបើធ្វើការប្រៀបធៀបទៅនឹងការទិញដោយ

សាច់ប្រាក់ ។ ការស្រាវជ្រាវអង្កេតឃើញថាអ្នកចូលរួមផ្តល់សម្ភាសន៍នៅក្នុងភូមិនៃខេត្តកំពង់ឆ្នាំង មាននិន្នាការក្នុងការទុកទិន្នផលស្រូវសម្រាប់ប្រើប្រាស់ក្នុងគ្រួសារជាជាងលក់ បើប្រៀបធៀបជាមួយនឹងគ្រួសារក្នុងខេត្តព្រៃវែង ។ ការស្រាវជ្រាវក៏បានអោយដឹងផងដែរថា មានឈ្មួញពីរប្រភេទដែលប្រមូលទិញទិន្នផលស្រូវនៅក្នុងភូមិចំនួន៤ និងនៅក្នុងភូមិជិតៗនោះនៅក្នុងខេត្តព្រៃវែង។ ប្រភេទទីមួយ គឺឈ្មួញជនជាតិវៀតណាមដែលមានឈ្មួញកណ្តាលជាជនជាតិខ្មែរជាអ្នកជួយប្រមូលទិញ ។ ជាធម្មតា ឈ្មួញជនជាតិវៀតណាមមកប្រមូលទិញក្នុងអំឡុងរដូវប្រមូលផល ដើម្បីពិនិត្យគុណភាពទិន្នផលស្រូវ (ទំហំគ្រាប់ និងសំណើម) មុនពេលសម្រេចចិត្តទិញ។

" *ពួកយើងជាកសិករ ដូចនេះពេលដែលឈ្មួញនិយាយថាតម្លៃ (តម្លៃស្រូវ) ៧០០ ឬ ៨០០ រៀល (ក្នុងមួយគីឡូ) ពួកយើងនឹងលក់ ពីព្រោះពួកយើងមិនដឹងពីកន្លែងដែលពួកយើងអាចទាមទាតម្លៃខ្ពស់ជាងនេះនោះទេ ហើយក៏មិនដឹងថាអាចតថ្លៃជាមួយនរណានោះទេ? ទោះបីជាពួកយើងមិនចង់លក់ក្នុងតម្លៃនេះ ពួកយើងបង្ខំចិត្តលក់ពីព្រោះពួកយើងបានធ្វើការសន្យាជាមួយអ្នកលក់ (ជី)ថាយើងនឹងសងប្រាក់ថ្លៃជីដល់ពួកគាត់"* សំដីរបស់ប្តីអ្នកបងស៊ីនួន ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ នៅខេត្តព្រៃវែង។

***រូបភាពទី ៧៖ ការប្រើប្រាស់ថវិកាពីការលក់ស្រូវបន្ទាប់ពីរដូវច្រូតកាត់***




ឈ្មួញជនជាតិវៀតណាម ជាទូទៅផ្តល់តម្លៃខ្ពស់ជាងតម្លៃដែលបានផ្តល់ដោយឈ្មួញជនជាតិខ្មែរ ។ ឈ្មួញជនជាតិខ្មែរដែលជួយប្រមូលទិញស្រូវ ទទួលបានកម្រៃជើងសារទៅតាមគីឡូស្រូវនីមួយៗដែលបានទិញដោយជនជាតិវៀតណាម ដូចដែលបានបង្ហាញដោយអ្នកផ្តល់ព័ត៌មានខាងក្រោម ។ ផ្ទុយពីឈ្មួញជនជាតិវៀតណាម ឈ្មួញជនជាតិខ្មែរទិញស្រូវពីកសិករក្នុងស្រុកភូមិក្នុងតម្លៃទាបជាង ទោះបីជាប្រភេទស្រូវតែមួយក៏ដោយ។ ដូចនេះ កសិករចូលចិត្តលក់ស្រូវឲ្យឈ្មួញ

ជនជាតិវៀតណាមប្រសិនជាអាច។ នេះជាការបញ្ជាក់ដោយកសិករដែលធ្លាប់លក់ស្រូវក្នុងរដូវដាំដុះចុងក្រោយនេះ។

*"ឆ្នាំនេះ ខ្ញុំសង្កេតឃើញថាកសិករដាំដុះស្រូវច្រើនជាងឆ្នាំមុនពីព្រោះមានឈ្មួញពីតំបន់ដទៃមកទិញស្រូវដែលដាំដុះក្នុងសហគមន៍ ។ ពួកគាត់បាននិយាយថាស្រូវក្នុងសហគមន៍នេះមានរស់ជាតិឆ្ងាញ់ ។ យ៉ាងណាមិញ ជាធម្មតាពួកយើងមានឈ្មួញកណ្តាលដែលមកទិញស្រូវដោយផ្ទាល់ពីកសិករ ។ ថៅកែ (ជនជាតិវៀតណាម) ទុកប្រាក់ឲ្យឈ្មួញកណ្តាលដើម្បីទិញស្រូវ ពួកគេយកចំនេញពីការទិញដូរនេះ ។ ជាឧទាហរណ៍ ប្រសិនបើឈ្មួញកណ្តាលទិញស្រូវ៨៣០រៀល/គីឡូ ពួកគេនឹងលក់ឲ្យឈ្មួញជនជាតិវៀតណាម ៨៥០រៀល/គីឡូ ។ ជារឿយៗ ឈ្មួញក្នុងស្រុកទិញទិន្នផលស្រូវក្នុងតម្លៃទាបជាងឈ្មួញជនជាតិវៀតណាមដើម្បីកិន និងលក់ក្នុងស្រុក។ "* (បទសម្ភាសន៍ជាមួយប្រធានភូមិ ខេត្តព្រៃវែង ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤)។

## ខ. ការចំណាយលើថ្លៃដើមនៃផលិតកម្មស្រូវ និង ទិន្នផលស្រូវដែលទទួលបាន

ក្នុងផ្នែកនេះ បង្ហាញពីរបកគំហើញអំពីធាតុចូលសម្រាប់ផលិតកម្មស្រូវដោយផ្តោតសំខាន់ទៅលើការប្រើប្រាស់ជីគីមី គ្រាប់ពូជ និងថ្លៃចំណាយដទៃទៀតដែលពាក់ព័ន្ធជាមួយនឹងការជួលកម្លាំងពលកម្ម/គ្រឿងចក្រដើម្បីធ្វើការងារលើវាលស្រែ ។ បញ្ហានេះនឹងត្រូវបានពិភាក្សាដើម្បីធ្វើការប្រៀបធៀបជាមួយនឹងទិន្នផលស្រូវដែលប្រមូលបានក្នុងរដូវប្រមូលផល ។ នៅក្នុងភូមិដែលធ្វើការស្ទង់មតិ ភាគច្រើននៃអ្នកចូលរួមផ្តល់សម្ភាសន៍បានឲ្យដឹងថាពួកគាត់បានប្រើប្រាស់ជីគីមីនៅឆ្នាំចុងក្រោយនៃការដាំដុះរបស់ពួកគាត់ ។ ដូចដែលបានបង្ហាញក្នុងរូបភាពទី ៨, ៨៩ភាគរយ (n= ១១៣) នៃអ្នកចូលរួមបានបញ្ជាក់ថាពួកគាត់បានប្រើប្រាស់ជីគីមីនៅឆ្នាំចុងក្រោយដែលគាត់ដាំដុះ ។ ការស្ទង់មតិមិនអាចកំណត់បានជាក់លាក់ពីបរិមាណជីដែលបានប្រើប្រាស់ក្នុងដីស្រែនីមួយៗដែលកសិករបានចែករំលែកក្នុងពេលសម្ភាសន៍នោះទេ ពីព្រោះកសិករពឹងផ្អែកលើការចងចាំក្នុងការផ្តល់ព័ត៌មានអំពីបរិមាណជី ។ តែទោះជាយ៉ាងណាក៏ដោយ ទិន្នន័យបានបង្ហាញថានិន្នាការនៃការប្រើបរិមាណជី និងតម្លៃជីគីមីមានការកើនឡើងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះនៅក្នុងភូមិដែលបានធ្វើការស្ទង់មតិ ដូចទៅតាមការរាយការណ៍ដោយ ៧៥ភាគរយ នៃអ្នកចូលរួមផ្តល់សម្ភាសន៍ (សូមពិនិត្យខាងក្រោម) ។ យោងទៅតាមអ្នកចូលរួមផ្តល់បទសម្ភាសន៍ ឯកតាលម្អិតនៃតម្លៃដែលបានកើនឡើង (សូមពិនិត្យតារាងក្នុងឧបសម្ព័ន្ធ V) បង្ហាញថាតម្លៃបានកើនឡើងចន្លោះ ១១ ០០០ ទៅ ២០០០០រៀល (២.៧៥ ដល់ ៥ដុល្លារ) ក្នុងមួយបាវ (ដែលមាន ៥០គីឡូ) នេះតាមការអះអាងដោយអ្នកចូលរួមផ្តល់សម្ភាសន៍ចំនួន៣៦ភាគរយ ខណៈពេលដែលឯកតា កើនឡើងចំនួន ៥.២៥ ដុល្លារ -ច្រើនជាង ១០ ដុល្លារ គួរអោយកត់សំគាត់ផងដែរ។

***រូបភាពទី ៨៖ ការប្រើប្រាស់ជីគីមីក្នុងការដាំដុះស្រូវ***




*"ពេលបច្ចុប្បន្នប្រសិនបើពួកយើងមិនប្រើប្រាស់ជីគីមីនោះទេ ពួកយើងមិនអាចតាមទាន់អ្នកដទៃនោះទេពីព្រោះគ្រប់គ្នាកំពុងប្រើប្រាស់ជីគីមី ។ កសិករមិនបញ្ឈប់ការប្រើប្រាស់ជីធម្មជាតិនោះទេ ប៉ុន្តែពួកគាត់ត្រូវតែប្រើប្រាស់ជីគីមីផងដែរ ។ ដូចនេះ ទោះបីជាពួកគាត់មិនមានលុយ ពួកគាត់នឹងទិញតាមរយៈឥណទានពីឈ្មួញចិនកាត់ខ្មែរ ។ យ៉ាងណាក៏ដោយ ដោយសារតែមិនមានទឹកគ្រប់គ្រាន់ ទោះបីជាកសិករប្រើប្រាស់ជីច្រើន ទិន្នផលក៏មិនបានគាប់ប្រសើរដែរ។"* បទសម្ភាសន៍ជាមួយប្រធានភូមិ ក្នុងខេត្តព្រៃវែង ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៤។




ប្រភេទថ្នាំសម្លាប់សត្វល្អិតដែលបានដាក់លក់នៅទីផ្សារក្នុងទីប្រជុំជនពន្លៃក្នុងស្រុកបរិបូរណ៍
***រូបភាពដោយ៖ ស៊ីម សុជាតា/ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤***

*រូបភាពទី ៩៖ ទិន្នាការនៃការចំណាយថ្លៃជីគីមីក្នុងកើនឡើងនៃរយៈពេល៥ឆ្នាំចុងក្រោយ*




*តារាងទី ៤៖ តារាងបញ្ជាក់លម្អិតពីការចំណាយថ្លៃជីគីមី*

| ចំនួននៃការកើនឡើង | ភាពញឹកញាប់ | ភាគរយ |
|---|---|---|
| < 10,000R (USD 2.5) | 9 | 6.8 |
| 11,000 – 20,000 R (USD 2.75 – 5) | 48 | 36.1 |
| 21,000 – 30, 000R (USD 5.25 – 7.5) | 14 | 10.5 |
| 31,000 – 40,000R (USD | 16 | 12 |
| > 40,000 (> USD10) | 14 | 10.5 |
| អត់ដឹង/MD | 32 | 24.1 |
| **សរុប** | 133 | 100 |

*“....ពេលបច្ចុប្បន្ននេះ ខ្ញុំប្រើជីគីមី ៨ បាវលើដីស្រែ (២ ហិចតា) ប្រៀបធៀបទៅប្រាំពីរឆ្នាំមុនគឺ៥បាវតែប៉ុណ្ណោះ ។ ខ្ញុំប្រើបរិមាណជីគីមីតិចជាង ពីព្រោះខ្ញុំដាក់ជីអាចម៍គោខ្លះ ។ ថ្លៃជីបានកើនឡើងយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាឧទាហរណ៍ ជីគីមីមួយបាវធ្លាប់តែមានតម្លៃ ៧០០០០ រៀលទៅ ៩០០០០រៀល ពេលបច្ចុប្បន្ននេះ ១១០០០០ ទៅ ១៣០០០០ រៀល ដែលនេះជាតម្លៃទិញបានប្រសិនជាយកលុយសុទ្ធទៅទិញ ។ ប្រសិនបើទិញដោយជំពាក់ ការប្រាក់គឺ ៤ភាគរយក្នុងមួយខែនៃថ្លៃជីសរុប”* បទសម្ភាសន៍ជាមួយស្ត្រី ថ្ងៃទី ៩ ខែឧសភាឆ្នាំ ២០១៤ ខេត្តព្រៃវែង។

គួរឲ្យកត់សម្គាល់ អ្នកចូលរួមផ្តល់បទសម្ភាសន៍ បានអង្កេតឃើញថាតម្លៃរបស់ជីគីមីឆ្នាំនេះហាក់បីដូចជានៅដដែលដូចឆ្នាំមុនចំពោះប្រភេទជីមួយចំនួន។ យ៉ាងណាមិញ ពួកគាត់បានបញ្ជាក់ថាតម្លៃបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ។ នៅពេលដែលការស្រាវជ្រាវធ្វើការស្វែងយល់ពីវិធីដែលកសិករទិញជីគីមីសម្រាប់ការដាំដុះស្រូវរបស់ខ្លួន ឃើញថា វាមានភាពខុសៗគ្នា ។ ដូចតារាងលេខ ៥ បានបង្ហាញ មានតែមួយភាគបីនៃអ្នកចូលរួមសម្ភាសន៍ប៉ុណ្ណោះ (៣៧.៦ភាគរយ) បានឲ្យដឹងថាពួកគាត់បានទិញជីគីមីដោយបង់ប្រាក់ដែលមានក្នុងដៃ ។ ប្រហែលជាពាក់កណ្តាលនៃអ្នកចូលរួមផ្តល់សម្ភាសន៍ (៤៤.៤ភាគរយ) បានឲ្យដឹងថាពួកគាត់ទិញដោយជំពាក់ ហើយសងវិញនៅក្រោយពេលប្រមូលផល ។ ជម្រើសចុងក្រោយ កសិករ ត្រូវតែបង្ខំចិត្ត

លក់ស្រូវដើម្បីសងបំណុលដែលបានជំពាក់លើការចំណាយក្នុងការដាំដុះ ។ ការលក់ដោយបង្ខំនេះមានន័យថា កសិករនឹងទទួលយកនូវតម្លៃស្រូវដែលឈ្មួញផ្តល់អោយដោយសារពួកគាត់មិនមានជម្រើសផ្សេងនោះទេ ។

*តារាងលេខ ៥៖ មធ្យោបាយនៃការទិញជីគីមីក្នុងរដូវធ្វើស្រែ*

| **មធ្យោបាយនៃការទិញ** | **បាទ** (ភាគរយ) | **ទេ** (ភាគរយ) | MD |
|---|---|---|---|
| ជំពាក់ និងសងបន្ទាប់ពីប្រមូលផល | 59 *(44.4ភាគរយ)* | 65 *(48.9ភាគរយ)* | 9 *(6.8ភាគរយ)* |
| បង់ប្រាក់ភ្លាមៗ | 50 *(37.6ភាគរយ)* | 73 *(54.9ភាគរយ)* | 10 *(7.5ភាគ* |
| បង់ខ្លះ និងជំពាក់ខ្លះ | 12 *(9ភាគរយ)* | 112 *(84.2ភាគរយ)* | 9 *(6.8ភាគរយ)* |
| ខ្ចីលុយទិញ | --- | 124 *(93.2ភាគរយ)* | 9 *(6.8ភាគរយ)* |

ជីគីមីទាំងបីប្រភេទដែលជាទូទៅបានបញ្ជាក់ដោយកសិករក្នុងការសិក្សាស្រាវជ្រាវ

*រូបភាពដោយក្រុមស្រាវជ្រាវ ខែមិនា ឆ្នាំ ២០១៤*




បន្តការសម្ភាសន៍ពីមួយទៅមួយ ក្រុមសិក្សាស្រាវជ្រាវបន្តស្តាប់លឺនូវកសិករត្អូញត្អែរពីការកើនឡើងនូវថ្លៃដើមកសិកម្ម ជាពិសេសគឺតម្លៃជីគីមី ថ្លៃជួលកម្លាំងពលកម្ម ឬគ្រឿងចក្រដើម្បីភ្ជួររាស់ ប្រមូលផល ឬការបែងចែកគ្រាប់ស្រូវ និងថ្លៃពាក់ព័ន្ធផ្សេងៗទៀតដូចជាការដឹកជញ្ជូនស្រូវពីវាលស្រែមកផ្ទះពួកគាត់ ។ ក្នុងកំឡុងពេលចុះសម្ភាសន៍ ក្រុមស្រាវជ្រាវបានឆ្លៀតឱកាសប្រមូលយកទិន្នន័យលម្អិតអំពីការចំណាយទៅលើឯកតាធាតុចូលសម្រាប់ផលិតកម្មស្រូវ និង ទិន្នផលស្រូវដែលពួកគាត់ប្រមូលបាន ហើយធ្វើការគណនាទូទាត់រវាងថ្លៃចំណាយជាមួយនឹងផលស្រូវដែលទទួលបានជាមួយនឹងពួកគាត់ ។ លទ្ធផល គឺថាការចំណាយតែងតែច្រើនជាងផលដែលទទួលបានជាពិសេសក្នុងអំឡុងពេលដែលតម្លៃស្រូវមិនត្រូវបានធ្វើការធានាដោយរដ្ឋក្នុងពេលរដូវប្រមូលផល

។ យ៉ាងណាមិញ កសិករបានឲ្យដឹងថាពួកគាត់បន្តការងារជាប្រពៃណីរបស់ខ្លួនដែលពួកគាត់បានធ្វើជាច្រើនជំនាន់មកហើយដោយសារហេតុផលដ៏សាមញ្ញមួយគឺថា៖ “ *ក្នុងនាមជាកសិករ អ្នកត្រូវតែដាំដុះស្រូវ មិនខ្វល់ថាទទួលបានលទ្ធផលយ៉ាងណានោះទេ។*” ប្រអប់ទី II ផ្តល់នូវឧទាហរណ៍មួយនៃការគណនាឯកតាតម្លៃការចំណាយ និងផលទទួលបានពីការដាំដុះស្រូវ ។ ពាក្យសំដីខាងក្រោមជាមតិយោបល់ពីប្រធានភូមិក្នុងការសិក្សាស្រាវជ្រាវនេះ។

| **ប្រអប់ II ៖ ការចំណាយលើការធ្វើស្រូវស្ងួត (២០១៣) សម្រាប់ការធ្វើស្រូវរដូវវស្សាលើដីស្រែកន្លះហិចតា** | |
|---|---|
| ឯកតានៃការចំណាយ | ចំនួន(ជារៀល) |
| ជីគីមី-ពីរបាវ (អាមេរិក ១៥០ ០០០រៀល URE -១៣០០០០រៀល) | ២៨០ ០០០រៀល |
| | ៦០០ ០០០រៀល |
| ថ្លៃពលកម្មក្នុងការសាបព្រួស<br>(ការចំណាយគឺទាប នៅពេល)- មួយថ្ងៃគឺ១២០០០រៀល/មួយនាក់/មួយថ្ងៃ+ អាហារពីរពេលថ្លៃដឹកជញ្ជូនរបស់គ្រួសារទៅស្រែ-លើគោយន្តជាមួយពូ ២០ លើក * ៤៣០០រ | ៨៦០០០រៀល |
| | ២៥០ ០០០រៀល |
| ជួលម៉ាស៊ីនប្រមូលផល*** | ៣៩០ ០០០រៀល |
| ថ្លៃចំណាយថ្លៃសាំងប៊ូមទឹកចូលស្រែ= ៣ ស៊ីទែន (៣០លីត្រ*១៣០០០០) | ៣០០ ០០០រៀល |
| | ២ ១០៦ ០០០ រៀល |
| ថ្លៃថ្នាំសំលាប់សត្វល្អិត នឹងការបាញ់ថ្នាំសំលាប់ស្មៅ | |
| ថ្លៃទុនចំណាយសរុបដែលបានចំណាយ៖ | ១ ៤០០ ០០០ រៀល |
| បរិមានទិន្នផលស្រូវសរុបដែលបានលក់ (២តោន) | |
| និងស្រូវ ៥០០គីឡូក្រាមទុកជាគ្រាប់ពូជ និងការប្រើប្រាស់ | |
| ***ថ្លៃចំណាយគឺ ៣៥០ ០០០ ក្នុងមួយហិចតា) ពីព្រោះម្ចាស់គ្រឿងចក្រត្រូវបានសុំឲ្យស្នាក់នៅក្នុងខ្ទមក្នុងអំឡុងពេលប្រមូលផល។ ម្ចាស់គឺមកពីខេត្តបាត់ដំបង។ | |

| | |
|---|---|
| (បទសម្ភាសន៍ជាមួយស៊ីណា ខេត្តកំពង់ឆ្នាំង ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤) | |

" មិនមានតុល្យភាពរវាងតម្លៃនៃការលក់ស្រូវបន្ទាប់ពីរដូវប្រមូលផល និងការចំណាយដែលពួកយើងបានចំណាយនោះទេ។ ខ្ញុំកត់សម្គាល់ឃើញថាកសិករមួយចំនួនបញ្ឈប់ការដាំដុះស្រូវ និងធ្វើចំណាកស្រុកដើម្បីស្វែងរកការងារក្នុងទីក្រុងភ្នំពេញ ឬកន្លែងផ្សេង។ មូលហេតុ ពីព្រោះការដាំដុះស្រូវធ្វើឲ្យពួកគាត់ជំពាក់បំណុលជាច្រើន ពួកគាត់ត្រូវទិញជី និងថ្នាំសម្លាប់សត្វល្អិត និងជួលគ្រឿងចក្រដើម្បីធ្វើការភ្ជួរ និងរាស់។ ថ្លៃភ្ជួរ គឺ ១៨០០០០រៀល ក្នុងមួយហិចតា និងការប្រមូលផលក្នុងស្រែមួយហិចតាត្រូវចំណាយពី ៣០០ ០០០ ទៅ ៣៥០ ០០០រៀល។ ប៉ុន្តែតម្លៃស្រូវគឺត្រឹមតែពី ៧០០រៀល/គីឡូដល់ ៩៣០រៀល/គីឡូ ទៅតាមប្រភេទស្រូវផ្សេងៗគ្នា។" បទសម្ភាសន៍ជាមួយប្រធានភូមិ ខេត្តព្រៃវែង ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៤។

## គ. ការគាំទ្រពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលចំពោះកសិករក្នុងការផលិតស្រូវ

*ឯកសារគោលនយោបាយលើការលើកកម្ពស់ការផលិត និងការនាំចេញស្រូវ* បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការសម្រេចបាននូវការនាំចេញស្រូវអង្ករឲ្យបានមួយលានតោនក្នុងឆ្នាំ ២០១៥ (ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១០) ។ ឯកសារគោលនយោបាយនេះបានចង្អុលបង្ហាញពីការគាំទ្រមួយចំនួនដែលបានផ្តល់ជូនដោយរដ្ឋាភិបាលថ្នាក់ជាតិដល់កសិករ/អ្នកផលិតអង្ករ និងឈ្មួញអង្ករក្នុងការសម្រេចបាននូវការផលិតនេះ ។ នេះរួមបញ្ចូលនូវការគាំទ្រ/ឧបត្ថម្ភធនហិរញ្ញវត្ថុចំនួន ៧ លានដុល្លារអាមេរិកតាមរយៈធនាគារជាតិកម្ពុជាដល់ធនាគារអភិវឌ្ឍន៍ជនបទ (RDB) មូលនិធិទ្រទ្រង់ការអភិវឌ្ឍន៍វិស័យកសិកម្ម (ADSF) ចំនួន១៨លានដុល្លារ និងផ្តល់ការទ្រទ្រង់ដល់សមាគមរោងម៉ាស៊ីនកិនស្រូវនៅចុងឆ្នាំ ២០១០/ដើមឆ្នាំ ២០១១ (ទីស្តីការគណៈរដ្ឋមន្ត្រី ២០១០) ។ ដោយសារតែការស្រាវជ្រាវនេះមិនមានគោលបំណងក្នុងការវាយតម្លៃពីគុណភាពនៃការគាំទ្រជាក់ស្តែងរបស់រដ្ឋាភិបាលដល់អ្នកផលិតស្រូវអង្ករដូចទៅនឹងវត្ថុបំណងផ្សេងទៀត ការសិក្សាស្ទង់មតិនេះ បានដាក់នូវសំណួរមួយចំនួនដើម្បីស្វែងយល់ពីប្រភេទនៃការគាំទ្រដែលកសិករខ្នាតតូចទទួលបានពីស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន និងភ្នាក់ងារអភិវឌ្ឍន៍ ។

អ្នកចូលរួមផ្តល់ការសម្ភាសន៍ក្នុងខេត្តទាំងពីរហាក់បីដូចជាមានការយល់ដឹងតិចតួចពីការគាំទ្រ/ការបណ្តុះបណ្តាលដែលផ្តល់ដោយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត និងស្រុក) ។ មានតែ

អ្នកចូលរួមផ្តល់ការសម្ភាសន៍មួយរូបតែប៉ុណ្ណោះ ដែលអះអាងថាការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុក (DoAFF) បានផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់កសិករ ។ ដោយផ្អែកលើបទសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗមកពីការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុក ដោយសារតែកង្វះខាតធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ធ្វើអោយមានសកម្មភាពតិចតួចតែប៉ុណ្ណោះនៅក្នុងវគ្គបណ្តុះបណ្តាល ឬនៅក្នុងកម្មវិធីលើកកំពស់ការយល់ដឹងដល់សហគមន៍ដែលធ្វើឡើងដោយការិយាល័យថ្នាក់ស្រុក ។ ជាឧទាហរណ៍ គឺមានមន្ត្រីតែមួយរូបប៉ុណ្ណោះដែលធ្វើការនៅការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុក ក្នុងស្រុកបរិបូរណ៍ ធ្វើការទទួលខុសត្រូវលើសកម្មភាពបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង។ នៅក្នុងស្រុកចំនួនពីរដែលបានធ្វើការសម្ភាសន៍ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្នាក់ស្រុក បានចង្អុលបង្ហាញថាពួកគេពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្មវិធីរបស់ភ្នាក់ងារអភិវឌ្ឍន៍ដែលធ្វើការងារជាក់លាក់ទៅលើកម្មវិធីកសិកម្ម ។

នៅក្នុងស្រុកបាភ្នំ គម្រោងPADEE ដែលបានគាំទ្រដោយរដ្ឋាភិបាលកម្ពុជាតាមរយៈកម្ចីពី IFAD ធ្វើការរួមគ្នាជាមួយនឹងអង្គការនៃក្រុមកសិករនៅតាមភូមិ និងឃុំ។ ក្រុមទាំងនេះបង្កើតក្រុមសន្សំ មានបណ្តុះបណ្តាលជាក់លាក់ខាងផ្នែកកសិកម្ម និង មានផែនការសកម្មភាព ហើយការគាំទ្រដើមទុនសម្រាប់លើកកម្ពស់ជីវភាពត្រូវបានផ្តល់អោយសម្រាប់រយៈពេលបីឆ្នាំ។ (បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មាន ខេត្តព្រៃវែងថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០១៨)។

ក្នុងភូមិចំនួនប្រាំមួយដែលធ្វើការស្ទង់មតិ អ្នកចូលរួមផ្តល់បទសម្ភាសន៍បានឲ្យដឹងថា ពួកគាត់ដឹងពីការគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យនេះ ។ របកគំឃើញនេះបានបង្ហាញថាអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យនេះបានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់សហគមន៍ ដូចជាបច្ចេកទេសដាំដុះស្រូវបែបប្រពលវប្បកម្ម (SRI) ការដាំបន្លែ ការចិញ្ចឹមសត្វពាហនៈ នឹងការចិញ្ចឹមមាន់ទា ដែលនេះត្រូវបានចង្អុលបង្ហាញដោយ ៣២ភាគរយ (n=៥២) នៃអ្នកចូលរួមផ្តល់បទសម្ភាសន៍ ។ ការគាំទ្រដទៃទៀតរួមមានការផ្តល់គ្រាប់ពូជ (២៧ភាគរយ) ការផ្តល់ឥណទានដោយអត្រាការប្រាក់ទាប (២ភាគរយក្នុងមួយខែ) ឬមិនមានការប្រាក់ និង ធនាគារស្រូវសហគមន៍ (១១.៣ភាគរយ)។

*រូបភាពទី ៩៖ ការទ្រទ្រង់ពីអង្គការសង្គមដល់កសិករ*




វត្តមាននៃអង្គការមិនមែនរដ្ឋាភិបាលផ្នែកវិស័យអភិវឌ្ឍន៍ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ពីព្រោះពេលដែលអង្គការទាំងនោះមានកម្មវិធីពាក់ព័ន្ធនឹងវិស័យកសិកម្ម ពួកគាត់តែងតែបានធ្វើការសហការជារឿយៗជាមួយមន្ត្រីនៃការិយាល័យកសិកម្ម វត្តប្រមាញ់ និងនេសាទ ឬ អង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដែលមានជំនាញផ្នែកកសិកម្ម ។ ពួកគេលើកកម្ពស់ការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសដល់អ្នកផលិតស្រូវ ។ ក្នុងភូមិមួយចំនួនដែលបានធ្វើការស្ទង់មតិ មានដីស្រែ សួនបន្លែ និងការចិញ្ចឹមមាន់ជាគំរូក្នុងការលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ។

## ៣.៣ បំណុលគ្រួសារ

យោងទៅតាមលទ្ធផលនៃការស្ទង់មតិ នៅពេលធ្វើការវាយតម្លៃ ៧៦ភាគរយ (n=១០១) នៃអ្នកចូលរួមផ្តល់បទសម្ភាសន៍បានជាប់បំណុល ។ បរិមាណបំណុលជាមធ្យមគឺ ៣ ១០៣ ៩១៣.៥០ រៀល (៧៧៥.៨៥ដុល្លារ) ។ ទោះបីជាបំណុលមធ្យមមានតួលេខខ្ពស់ បរិមាណបំណុលដែលទាបបំផុត ក៏គួរអោយកត់សំគាល់ផងដែរ គឺវាតម្លៃត្រឹម ៥០០០រៀល (១.២៥ ដុល្លារ) ខណៈដែលបំណុលដែលខ្ពស់បំផុតគឺ ៤០ ៧៥០ ០០០រៀល (១០១៨៧.៥ ដុល្លារ) ។ រូបភាពទី ១០ បង្ហាញថាក្នុងចំណោមគ្រួសារដែលជាប់បំណុល ចំនួនម្ចាស់ឥណទាន/អ្នកផ្តល់កម្ចី ដែលពួកគាត់ជំពាក់មានចាប់ពីមួយ ដល់ប្រាំបីស្ថាប័ន/នាក់ ។ ភាគច្រើននៃពួកគេ ៥៤ភាគរយ នៃគ្រួសារដែលជំពាក់បំណុល បានជំពាក់ម្ចាស់ឥណទាន/អ្នកខ្ចីមួយនាក់ ហើយ១៨ភាគរយបានជំពាក់ម្ចាស់ឥណទាន/អ្នកខ្ចីពីរនាក់ ។ អ្វីដែលគួរឲ្យកត់សម្គាល់ផងដែរនោះ ប្រហែលជា ១៣ភាគរយ (n=១៧) នៃគ្រួសារដែលបានធ្វើការស្ទង់មតិបានជំពាក់ម្ចាស់ឥណទាន/អ្នកផ្តល់កម្ចីចាប់ពី ៣ទៅ៥នាក់ សម្រាប់បំណុលបច្ចុប្បន្នរបស់ពួកគេ ។ មានគ្រួសារតែមួយប៉ុណ្ណោះដែលពេលបច្ចុប្បន្នជំពាក់អ្នកផ្តល់កម្ចី

ប្រាំបីម្ចាស់ផ្សេងៗគ្នា ដែលក្នុងនោះ ប្រាំស្ថាប័នគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារ និងបីទៀតជាអ្នកផ្តល់កម្ចីក្នុងតំបន់។

*រូបភាពទី ១០៖ កម្រិតបំណុល និងចំនួនម្ចាស់ឥណទាន/អ្នកផ្តល់កម្ចី*




តារាងលេខ ៦ បង្ហាញពីបរិមាណបំណុល ក្នុងចំណោមគ្រួសារដែលបានធ្វើការស្ទង់មតិ ។ ៥៧ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍បានឲ្យដឹងថាមានបំណុលតិចជាង ១លានរៀល (<២៥០ដុល្លារ) ។ ប្រហែលជា ១០ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍ជំពាក់បំណុលចន្លោះពីមួយ ទៅពីរលានរៀល (២៥០ទៅ ៥០០ដុល្លារ) ខណៈពេលដែល ១២ភាគរយ ជាប់បំណុលតិចជាងប្រាំមួយលានរៀល (<១៥០០ដុល្លារ) ។ ពាក់ព័ន្ធជាមួយនឹងម្ចាស់ឥណទាន/អ្នកផ្តល់កម្ចី របកគំហើញបញ្ជាក់ថា ៣២.៣ភាគរយ នៃកម្ចីគឺបានមកពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ២៣.៣ ភាគរយបានមកពីអ្នកឲ្យលុយខ្ចី ១៧.៣ភាគរយបានមកពីសាច់ញាតិ និងប្រហែលជា ១០ភាគរយ គឺជាឥណទានពីធនាគារអេស៊ីលីដា ។ គ្រួសារដែលចូលរួមការស្ទង់មតិ ទទួលកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដូចជា អម្រិត អេអ៊ឹមខេ វីសិនហ្វាន់ CBIRD ប្រាសាក់ ធនាគារភូមិ និងក្រេឌីត (សូមពិនិត្យមើលឧបសម្ព័ន្ធ v តារាងនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមខេត្ត) ។ ក្រៅពីអ្នកផ្តល់ឥណទានក្នុងប្រព័ន្ធនេះ ក៏មានអ្នកផ្តល់ឥណទានក្រៅប្រព័ន្ធមួយចំនួនផងដែរដែលមានដំណើរការក្នុងសហគមន៍ គម្រោងសន្សំ និងមូលនិធិអភិវឌ្ឍន៍របស់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកឲ្យលុយខ្ចីក្នុងសហគមន៍។

### *តារាងលេខ ៦៖ ទំហំនៃបំណុលក្នុងមួយគ្រួសារ*

| ទំហំនៃបំណុល | **# គ្រួសារ** | ភាគរយ |
|---|---|---|
| 0 – 1,000,000R *(0 – 250 $)* | 76 | 57.1 |
| > 1,000,000 – 2,000,000 R *(> 250 – 500 $)* | 14 | 10.5 |
| > 2,000,000 – 3,000,000R *(> 500 – 750 $)* | 7 | 5.3 |
| >3,000,000 – 4,000,000R *(>750 – 1,000$)* | 11 | 8.3 |
| > 4,000,000 – 6,000,000R *(>1,000 – 1,500$)* | 9 | 6.8 |
| > 6,000,000R (>1500 $) | 16 | 12 |

ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់នូវប្រាក់កម្ចី រូបភាព ១១ តាមរយៈអ្នកផ្តល់សម្ភាសន៍ បានបង្ហាញថា ភាគច្រើននៃកម្ចីត្រូវបានប្រើប្រាស់ ទៅលើការព្យាបាលជម្ងឺ (៤០ភាគរយ) បន្ទាប់មកគឺការសាងសង់ផ្ទះ (១៤.៣ភាគរយ) ទិញចំណីអាហារ(១១.៣ភាគរយ) និងការចំណាយលើទុនកសិកម្មដាំដុះ (១០.៥ភាគរយ) ។ ប្រហែលជា១០ភាគរយ (n=១៣) នៃគ្រួសារដែលបានផ្តល់បទសម្ភាសន៍បានឲ្យដឹងថា ពួកគាត់ប្រើប្រាស់កម្ចីក្នុងការសងបំណុលដែលមានស្រាប់ ។ ក្នុងចំណោមចំនុចទាំង ១០ ដែលអ្នកចូលរួមផ្តល់បទសម្ភាសន៍បានប្រើប្រាស់កម្ចីសម្រាប់ចាយទៅលើ គឺមានតែចំនុចពីរតែប៉ុណ្ណោះ មានដូចជាការបង្កើតរបរថ្មី និងទិញដីស្រែថ្មី ដែលជាការប្រើប្រាស់កម្ចីសម្រាប់ផលិតកម្ម។ ការប្រើប្រាស់កម្ចីដទៃទៀត គឺក្នុងគោលបំណងសំខាន់ក្នុងការរស់រាន/មិនមែនសម្រាប់ផលិតកម្ម (ទិញចំណីអាហារ នឹងការព្យាបាលជម្ងឺ) និងទិញទ្រព្យសម្បត្តិថេរ ។ របកគំហើញនេះបង្ហាញពីចំនុចសំខាន់ដែលត្រូវពិចារណាជាពិសេស ដោយសារតែការចំណាយទៅលើការព្យាបាលជម្ងឺវាជាចំណាយដ៏ខ្ពស់ និងសំខាន់បំផុតដែលជម្រុញឲ្យគ្រួសារខ្ចីបំណុល ។ នេះធ្វើការបញ្ជាក់ពីទិន្នន័យថ្នាក់ជាតិដែលការចំណាយចេញពីហោប៉ៅផ្ទាល់របស់ប្រជាជនដើម្បីទទួលបាននូវសេវាថែទាំសុខភាព ក្លាយជាបន្ទុករបស់ប្រជាពលរដ្ឋ ហើយវានឹងក្លាយជារនាំងដែលធ្វើអោយប្រជាជនមិនអាចទទួលបានសេវាសុខភាពនៅពេលដែលពួកគាត់មិនលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ ។ លើសពីនេះទៀត សម្រាប់ការប្រើប្រាស់កម្ចីដែលមិនមានផលិតភាពទាំងនេះ វាជារឿងដែលគួរអោយគួរពិចារណាផងដែរចំពោះលទ្ធភាពរបស់អ្នកខ្ចីក្នុងការសងបំណុលនិងអត្រាការប្រាក់ទៅអោយម្ចាស់ឥណទានវិញ ។

*រូបភាពទី ១១៖ ការប្រើប្រាស់កម្ចីដោយគ្រួសារដែលបានធ្វើការស្ទង់មតិ*




### *ប្រភេទនៃកម្ចីដែលបានប្រើប្រាស់ដោយគ្រួសារដែលបានធ្វើការស្ទង់មតិ*

របកគំហើញពីការសិក្សាស្រាវជ្រាវនេះ បង្ហាញថាមានប្រភេទកម្ចីចំនួនបីប្រភេទដែលគ្រួសារក្នុងការសិក្សាស្រាវជ្រាវនេះប្រើប្រាស់ ។ មានដូចតទៅ ក.កម្ចីផ្តល់ជូនដោយស្ថាប័នដែលបានចុះបញ្ជីស្របច្បាប់ដូចជាធនាគារក្នុងស្រុក (អេស៊ីលីដា) និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ខ. កម្ចីផ្តល់ជូនដោយប្រភពក្រៅប្រព័ន្ធដូចជាអ្នកឲ្យប្រាក់ខ្ចីក្នុងសហគមន៍ ឬម្ចាស់ឥណទានដែលមិនបានចុះបញ្ជីស្របច្បាប់ គ. កម្ចីពីគម្រោងសន្សំ/កម្មវិធីអង្គការមិនមែនរដ្ឋាភិបាល ។ មានប្រភេទកម្ចីផ្សេងទៀតដូចជាកម្ចីពីសាច់ញាតិ/ក្រុមគ្រួសារ ដែលជាទូទៅមិនគិតការប្រាក់ ហើយបម្រើគោលបំណងជាការទ្រទ្រង់ផ្នែកសង្គមដល់គ្រួសារដែលត្រូវការ ។

## ក. ម្ចាស់ឥណទានផ្តល់កម្ចីក្នុងប្រព័ន្ធ

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) បង្ហាញថារហូតដល់ឆ្នាំ២០១៣នេះ មានស្ថាប័នមីក្រូហិរញ្ញវត្ថុដែលចុះបញ្ជីចំនួន ៣៧ និងប្រតិបត្តករផ្តល់ឥណទានជនបទអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥ ដែលបច្ចុប្បន្នជាសមាជិករបស់CMA ។ ស្ថាប័នទាំងនេះប្រតិបត្តិការទូទាំងប្រទេសកម្ពុជា (CMA ឆ្នាំ ២០១៤)។ គ្រប់ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ដែលមានប្រតិបត្តិការក្នុងទីតាំងសិក្សាស្រាវជ្រាវគឺជាសមាជិករបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ។ មានប្រភេទកម្ចីចំនួនពីរ ដែលគ្រួសារចូលរួមក្នុងការផ្តល់បទសម្ភាសន៍តែងតែធ្វើការខ្ចីពីស្ថាប័នកម្ចី មានដូចជា៖ កម្ចីជាបុគ្គល (ដែលទាមទារវត្ថុបញ្ចាំ) និងកម្ចីជាក្រុម (ដែលមិនទាមទារវត្ថុបញ្ចាំ)។ ការអង្កេតយ៉ាងឆាប់រហ័សមួយទៅលើគេហទំព័ររបស់អេស៊ីលីដា ប្រាសាក់ អម្រិត អេអឹមខេ វីសិនហ្វាន់ បង្ហាញថាអត្រាការប្រាក់

ប្រចាំខែនៃកម្ចីបុគ្គល ឬកម្ចីជាក្រុម កម្ចីសម្រាប់អាជីវកម្មខ្នាតតូច និងកម្ចីកសិកម្ម គឺចន្លោះពី ២ទៅ ៣ភាគរយក្នុងមួយខែ (លើកលែងតែវីសិនហ្វាន់ដែលយក ១.៧៥ភាគរយប្រចាំខែសម្រាប់កម្ចីកសិកម្ម) ដែលនេះគឺស្មើនឹង ពី ២៤ទៅ ៣៦ភាគរយ ក្នុងមួយឆ្នាំ។ យ៉ាងណាមិញ កម្ចីដែលមានទំហំធំជាងនេះ មានអត្រាការប្រាក់ទាបជាងនេះ ប៉ុន្តែវាទាមទារអោយគ្រួសារមានវត្ថុបញ្ចាំដែលមានតម្លៃខ្ពស់ ។ សម្រាប់គោលបំណងការវិនិយោគលើអាជីវកម្ម និងកសិកម្ម ការស្វែងរកប្រាក់ចំណេញ ឬទិន្នផលស្រូវវិញ គេត្រូវតែធ្វើវាអោយបានទិន្នផលខ្ពស់ដើម្បីឲ្យគ្រួសារមួយអាចទប់ទល់នឹងការប្រាក់ដែលខ្ពស់នេះបាន ។ ប្រអប់លេខ III បង្ហាញពីអត្រាការប្រាក់ផ្សេងៗគ្នានៃបរិមាណកម្ចីជាបុគ្គលដ៏ច្រើនដែលអ្នកចូលរួមផ្តល់សម្ភាសន៍មួយរូបបានទទួលពីប្រភពហិរញ្ញវត្ថុផ្សេងៗគ្នាចំនួនប្រាំ ។ ដូចដែលករណីនៃគ្រួសារមួយនេះបានបង្ហាញ គ្រួសារក្នុងភូមិដែលបានចូលរួមធ្វើការស្ទង់មតិ គឺទទួលកម្ចីថ្មីដើម្បីចំណាយលើថ្លៃព្យាបាល ទិញទ្រព្យសម្បត្តិអសកម្ម ឬសងបំណុលដទៃទៀត។

| ប្រអប់លេខ II៖ កម្ចីចម្រុះជាយន្តការមួយក្នុងការសងបំណុលអោយទាន់ពេលកំណត់ |
| --- |
| គ្រួសារនេះមានសមាជិកចំនួន ប្រាំពីរនាក់ កូនស្រីពីរនាក់កំពុងបម្រើការងារក្នុងរោងចក្រកាត់ដេរ និងកូនបីនាក់ទៀតកំពុងរៀនសូត្រ។ ពួកគាត់មានដីស្រែពីរហិចតាដែលពួកគាត់ធ្វើការដាំដុះស្រូវ។ ពេលបច្ចុប្បន្ននេះ គ្រួសារជំពាក់បំណុល ម្ភៃលានរៀល (៥០០០ ដុល្លារ) ។ បំណុលគឺជំពាក់ម្ចាស់បំណុលចំនួនប្រាំផ្សេងៗគ្នា៖ ស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួនបី (អម្រិត អេអឹមឃេ និង CBIRD) និងធនាគារអេស៊ីលីដា និងពីសមាគមឥណទានគ្រូបង្រៀន។<br><br>*" គ្រាន់តែក្នុងឆ្នាំ ២០១៣មួយប៉ុណ្ណោះ ខ្ញុំបានទទួលកម្ចីចំនួនបី៖ កម្ចីទីមួយគឺមានចំនួន ៣០០០ ដុល្លារពីធនាគារអេស៊ីលីដា ដែលមានអត្រាការប្រាក់ ១.៧ភាគរយក្នុងមួយខែ ដែលក្នុងនោះខ្ញុំបានដាក់ប្លង់ដីភូមិជាវត្ថុបញ្ចាំ ។ កម្ចីទីពីរពីអម្រិត ដែលមានចំនួន ៣ ០០០ ០០០ រៀល (៧៥០ដុល្លារ) ដែលក្នុងនោះខ្ញុំបានដាក់ប្លង់ដីស្រែជាវត្ថុបញ្ចាំ ។ កម្ចីទីបីពីCBIRD ដែលមានចំនួន ១ ៥០០ ០០០ រៀល (៣៧៥ដុល្លារ)"*<br><br>កម្ចីដែលបានបញ្ជាក់ខាងលើត្រូវបានឲ្យដឹងថាត្រូវបានប្រើប្រាស់ក្នុងគោលបំណងព្យាបាលជម្ងឺ(ឆ្លងទន្លេ) សង់ផ្ទះ សង់ថ្លៃទុនចំណាយលើការដាំដុះស្រូវ និងសងបំណុលដែលមានស្រាប់។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ គ្រួសារនេះបានឲ្យដឹងថា កូនរបស់គាត់ពីរនាក់មានជម្ងឺគ្រុនចាញ់នៅពេលតែមួយដែលបង្ករជាបន្ទុកដ៏ធ្ងន់ធ្ងរទៅលើថ្លៃចំណាយលើការព្យាបាលចំពោះគ្រួ |

សារ។
(បទសម្ភាសន៍ជាមួយពិសីនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ក្នុងខេត្តព្រៃវែង)

## ខ. ស្ថាប័នផ្តល់កម្ចីក្រៅប្រព័ន្ធ

តាមរយៈការសិក្សាស្រាវជ្រាវ យើញថាមានស្ថាប័នផ្តល់កម្ចីក្រៅប្រព័ន្ធចំនួនពីរប្រភេទ ដែល ប្រតិបត្តិការក្នុងភូមិដែលបានធ្វើការស្ទង់មតិ ។ ប្រភេទទីមួយគឺកម្ចីដែលធ្វើប្រតិបត្តិការដោយផ្អែកលើទំនុកចិត្ត និងការព្រមព្រៀងទៅវិញទៅមករវាងអ្នកផ្តល់កម្ចី និងអ្នកទទួលខ្ចី តាមរយៈបទសម្ភាសន៍នេះ គ្រួសារមួយចំនួនបានឲ្យដឹងថាពួកគាត់ទទួលកម្ចីដោយមិនដាក់វត្ថុបញ្ចាំ ពីព្រោះអ្នកផ្តល់កម្ចីស្គាល់ពួកគាត់យ៉ាងច្បាស់ ។ យ៉ាងណាមិញ អ្នកផ្តល់ព័ត៌មានសំខាន់ៗដែលបានសម្ភាសន៍ បានបញ្ជាក់ថាពេលបច្ចុប្បន្នពួកគាត់ទាមទារឲ្យមានវត្ថុបញ្ចាំ និងកិច្ចព្រមព្រៀងតាមរយៈកិច្ចសន្យាដែលរៀបរៀង និងរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន (មេភូមិ ឬមេឃុំ) (សូមពិនិត្យមើលការដកស្រង់សម្តីខាងក្រោម) ដោយសារធ្លាប់មានការសងយឺត ឬការមិនសង ។ ប្រភេទទីពីរគឺមានការអនុវត្តដែលលក្ខណៈជាប្រព័ន្ធជាងប៉ុន្តែមិនមានការចុះបញ្ជីត្រឹមត្រូវនោះទេ ។ ពួកគេតម្រូវឲ្យមានកិច្ចសន្យាខ្ចីប្រាក់ដែលមានការទទួលស្គាល់ពីអាជ្ញាធរដូចនឹងនីតិវិធីខ្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុផងដែរ ។ ជាឧទាហរណ៍មួយ គឺជាក្រុមដែលមានឈ្មោះថា សមាគមឥណទានគ្រូបង្រៀន ដែលផ្តល់កម្ចីដល់អ្នកទទួលខ្ចីក្នុងស្រុកបាភ្នំ។ កម្ចីរបស់ពួកគាត់អាចតិចបំផុតចាប់ពី ៥០០០០ រៀល (១២,៥ ដុល្លារ) រហូតដល់ធំបំផុតរហូតដល់ ៤០០០ ០០០រៀល (១០០០ ដុល្លារ) និងគិតការប្រាក់ ៣ភាគរយក្នុងមួយខែ។

> " *ចំពោះអតិថិជនរបស់ពួកយើង ប្រសិនបើចំនួនកម្ចីច្រើន (៤០០០ ០០០រៀល) ពួកយើងនឹងស្នើឲ្យមានកិច្ចសន្យា ដែលពួកគាត់ត្រូវផ្តិតមេដៃ និងដាក់វត្ថុបញ្ចាំដូចជាប្លង់ផ្ទះ និងប្លង់ដី ។ គឺវាផ្អែកទៅលើការចរចារ និងទំនុកចិត្តដែលពួកយើងមានលើអ្នកខ្ចី។ ប្រសិនជាពួកយើងមិនមានទំនុកចិត្តនោះទេ ពួកគាត់ត្រូវដាក់វត្ថុបញ្ចាំ ។ កិច្ចសន្យាខ្ចីប្រាក់របស់ពួកយើងត្រូវបានទទួលស្គាល់ដោយអាជ្ញាធរភូមិ និងឃុំ ។"* អ្នកផ្តល់ព័ត៌មានក្នុងសហគមន៍ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ខេត្តព្រៃវែង។

**ខាងឆ្វេង៖** អ្នកផ្តល់កម្ចីក្រៅប្រព័ន្ធក្នុងក្រុងសម្រាប់កម្ចីក្រៅប្រព័ន្ធ។ គឺទាមទារឲ្យមានវត្ថុបញ្ចាំ។
**ខាងស្តាំ៖** ខិតប័ណ្ណផ្សព្វផ្សាយពាណិកជ្ជកម្មនៃកម្ចីថ្មី ផ្តល់ជូនមេភូមិ ។ មិនមានអាសយដ្ឋានរបស់ស្ថាប័ននៅក្នុងខិតប័ណ្ណនោះទេ។

ថតរូបដោយ ស៊ឹម សុជាតា
ខែឧសភា ឆ្នាំ ២០១៤។




យោងទៅតាមអ្នកផ្តល់ព័ត៌មានក្នុងសហគមន៍ អ្នកភូមិជាធម្មតាទទួលកម្ចីពីអ្នកផ្តល់កម្ចីឯកជនក្នុងអត្រាការប្រាក់ប្រចាំខែពី ៣ ទៅ ៥ភាគរយ ដើម្បីយកទៅសងបំណុលដែលបានខ្ចីពីធនាគារក្នុងស្រុក និង/ឬស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកាលបរិច្ឆេទដែលត្រូវសង ។ ការអនុវត្តនេះជារឿងពេញនិយមក្នុងការធានានូវការសងបំណុលអោយទាន់ពេលវេលា និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការខ្ចីលើកក្រោយទៀត។

> " *នៅពេលដល់ពេលត្រូវសងបំណុលដល់អង្គការ* [3] *គ្រួសារដែលជាប់បំណុលមានភាពមមាញឹកក្នុងការខ្ចីប្រាក់ពីប្រភពផ្សេង ហើយពួកគាត់នឹងហ៊ានខ្ចីដោយបង់ការប្រាក់ខ្ពស់ជាងមុន ។ តាមរយៈវិធីសាស្រ្តនេះពួកគាត់អាចក្លាយជាអ្នកខ្ចីដ៏ល្អ និងសងបំណុលទាន់ពេលវេលា និងអាចខ្ចីលើកក្រោយបាន។"* អ្នកផ្តល់ព័ត៌មានក្នុងតំបន់ ថ្ងៃទី ១៧ ខែកុម្ភៈឆ្នាំ ២០១៤។ ខេត្តព្រៃវែង។

ក្នុងបទសម្ភាសន៍បីផ្សេងៗគ្នាជាមួយអ្នកតំណាងពីធនាគារអេស៊ីលីដា និងអម្រិត ពួកគាត់បានបញ្ជាក់ថាអត្រានៃការសងប្រាក់កម្ចីរបស់ពួកគេ គឺមានអត្រាខ្ពស់រហូតដល់ទៅជាង ៩៩ភាគរយក្នុងចំណោមគ្រួសារដែលបានខ្ចីទាំងអស់ក្នុងឆ្នាំ ២០១៣ ។ ជាឧទាហរណ៍ តាមរយៈអ្នកគ្រប់គ្រងសាខារបស់អម្រិតក្នុងខេត្តព្រៃវែង អត្រាសងប្រាក់មានចំនួន ៩៩.៧ភាគរយ ក្នុងឆ្នាំ ២០១៣ ។ ជាការសំខាន់ណាស់ក្នុងការស្តាប់លឺនូវមតិយោបល់ និង ការអង្កេតពីអ្នកផ្តល់ព័ត៌មានក្នុងសហគមន៍អំពីវិធីសាស្រ្តដែលគ្រួសារជាប់បំណុលបានប្រើដើម្បីសងបំណុលដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ/ធនាគារអោយបានទាន់ពេលវេលា ដោយសារតែបទពិសោធន៍នេះមិនមានបញ្ជាក់ក្នុង

[3] អ្នកភូមិហៅស្ថាប័នមីក្រូហិរញ្ញវត្ថុនិង/ឬធនាគារអេស៊ីលីដាថា *អង្គការ។*

របាយការណ៍អំពីប្រត្តិបត្តិការកម្ចីដ៏ជោគជ័យរបស់ស្ថាប័នផ្តល់កម្ចីនោះទេ ។ ចំពោះគ្រួសារមួយចំនួន ការសងបំណុលយឺត ធ្វើអោយពួកគាត់មិនអាចខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុនៅលើកក្រោយទៀត ។ ចំពោះអ្នកដទៃទៀត វាជាបញ្ហាពាក់ព័ន្ធជាមួយនឹងកេរ្តិ៍ឈ្មោះ និងភាពអាម៉ាសនៅពេលដែលអ្នកផ្សេងដឹងថាគ្រួសាររបស់គេមានជាប់បំណុល ។ ចំពោះអ្នកខ្ចីជាច្រើនទៀតក្នុងការសិក្សាស្រាវជ្រាវនេះ មានបញ្ហាទៅលើការគ្រប់គ្រងនូវទ្រព្យសម្បត្តិដែលមានផលិតភាពរបស់គាត់ដូចជាដីធ្លី ផ្ទះសម្បែង ឬសត្វពាហនៈសម្រាប់ការអូសទាញ ។

ចាប់តាំងពីខែកុម្ភៈឆ្នាំ ២០១៤ មក គ្រួសារជាប់បំណុលចំនួន ៧ លានរៀល ។ ពួកគាត់អាចសងទៅឲ្យអ្នកផ្តល់ប្រាក់ខ្ចីឯកជនចំនួន ១លានរៀលនៅក្នុងភូមិ ។ កម្ចីនេះគឺមានពេលកំណត់ដែលមានន័យថា អ្នកខ្ចីត្រូវតែសងទាំងប្រាក់ដើម និងការប្រាក់ឲ្យបានទាន់ពេលវេលា ។ គ្រួសារមិនចង់ឲ្យអ្នកដទៃលឺជាសាធារណៈថាខ្លួនជាប់បំណុល ហើយមិនអាចសងដែលធ្វើឲ្យគ្រួសារខ្មាសគេនោះទេ ។ ដូចនេះពួកគាត់ត្រូវធ្វើអោយប្រាកដថានៅពេលដែលដល់ថ្ងៃត្រូវសង ពួកគាត់ត្រូវមានលុយសងបំណុល ។ ដូចនេះ គាត់ត្រូវស្វែងរកកម្ចីពីប្រភពដទៃ/អ្នកផ្តល់កម្ចី មិនថាក្នុងរយៈពេលពីរបីថ្ងៃ ឬ ក្នុងមួយខែនោះទេ គ្រួសារត្រូវបង់អត្រាការប្រាក់មួយខែពេញគឺ ៣ភាគរយក្នុងមួយខែ...បទសម្ភាសន៍ជាមួយសុផល ថ្ងៃទ ៦ ខែឧសភា ឆ្នាំ ២០១៤ ខេត្តព្រៃវែង។

"ប្តីប្រពន្ធមួយគូមកខ្ចីប្រាក់ពីខ្ញុំ ។ ពួកគាត់បានប្រាប់ខ្ញុំថាប្លង់ដីស្រែរបស់គាត់ពេលបច្ចុប្បន្ននៅអម្រិត ។ ពួកគាត់ចង់ខ្ចីប្រាក់ចំនួន ៨០០ ០០០ រៀលពីខ្ញុំ និងសន្យាសងវិញក្នុងរយៈពេលមួយខែ *បើមិនដូចនេះទេ* ពួកគាត់នឹងលក់*ដី*ស្រែមកឲ្យខ្ញុំ។ ប្រពន្ធគឺជាអ្នកដែលបានខ្ចី *(ដាក់ឈ្មោះរបស់នាងលើបញ្ជីរបស់ខ្ញុំ)* ហើយប្តីជាសាក្សី។ ខ្ញុំបានយល់ព្រមក្នុងការឲ្យលុយគាត់ខ្ចីពីព្រោះខ្ញុំស្គាល់ពួកគាត់យ៉ាងច្បាស់ ដូចនេះពួកគាត់មិនចាំបាច់ដាក់អ្វីជាវត្ថុបញ្ចាំទាំងអស់ ។ មួយខែក្រោយមក ពួកគាត់មិនអាចស្វែងរកប្រាក់សងខ្ញុំវិញបាន ដូចនេះពួកគាត់បាននិយាយថាគាត់នឹងលក់ដីស្រែមកឲ្យខ្ញុំ ។ មានការព្រមព្រៀងក្នុងតម្លៃ ១៦៥០ ០០០ រៀល *( ៤១២.៥ ដុល្លារ)* សម្រាប់ដីស្រែ ១៥ អា ។ ខ្ញុំបានបង់ជូននូវប្រាក់ដែលសេសសល់នៃតម្លៃដីស្រែ និងបានទៅការិយាល័យអម្រិតនៅព្រៃវែងជាមួយប្តី ដើម្បីបង់នឹងទទួលបានប្លង់ដីស្រែ។ ឥឡូវនេះដីស្រែនេះជារបស់ខ្ញុំ។" អ្នកផ្តល់ព័ត៌មានក្នុងសហគមន៍ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៤។

ប្រតិបត្តិការរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងសហគមន៍ គឺពឹងផ្អែកយ៉ាងសំខាន់លើកិច្ចសហប្រតិបត្តិការពីអាជ្ញាធរមូលដ្ឋាននៅគ្រប់មូលដ្ឋានទាំងអស់ ។ ក្នុងសហគមន៍ជាច្រើន អាជ្ញាធរមូលដ្ឋាន (ដូចជាសមាជិករបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬប្រធានភូមិ) ដើរតួនាទីយ៉ាងសំខាន់ក្នុងគណៈកម្មាធិរបស់មីក្រូហិរញ្ញវត្ថុក្នុងការសម្របសម្រួលអោយមានការអនុវត្តដោយរលូននូវការខ្ចី និងការសងត្រលប់វិញ ។ ការងារទាំងនេះរួមមានការទទួលស្គាល់នៃម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិដែលគ្រួសារខ្ចីប្រាក់ដាក់ជាវត្ថុបញ្ចាំ ឬបញ្ជាក់ថាតើពួកគាត់មានជាប់បំណុលជាមួយនឹងភ្នាក់ងារដទៃឬក៏អត់ ។ អ្នកផ្តលព័ត៌មានមួយចំនួន ដែលអាជ្ញាធរមូលដ្ឋានបានបញ្ជាក់ថា ជារឿយៗ បុគ្គលិក/ភ្នាក់ងារឥណទានជម្រាបអាជ្ញាធរមូលដ្ឋានពីប្រតិបត្តិការរបស់ពួកគេ និងស្វែងរកកិច្ចសហការនិងការគាំទ្រ។

មានសំណួរត្រូវបានលើកឡើង សួរជុំវិញកាលើកទឹកចិត្ត និងផលប្រយោជន៍ជាក់ស្តែងដែលអាជ្ញាធរមូលដ្ឋានទទួលបានពីការរួមចំណែក និងកិច្ចសហការនេះ ។ បុគ្គលិកធនាគារអេស៊ីលីដា បានបញ្ជាក់ក្នុងកិច្ចសម្ភាសន៍ដោយត្រង់ៗថា មិនមានផលប្រយោជន៍ណាមួយដែលធានាគារអេស៊ីលីដាបានផ្តល់ជូនដល់អាជ្ញាធរមូលដ្ឋាននោះទេ ។ អម្រិតបានបន្តថាដូចគ្នាផងដែរ។ ខណៈពេលដែលនេះជាតួនាទីរបស់អាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យរាល់សកម្មភាពទាំងអស់ ដែលបានកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ការងារទាំងនេះបានចំណាយពេលយ៉ាងច្រើនរបស់ពួកគាត់ក្នុងការចូលរួមពាក់ព័ន្ធជាមួយប្រតិបត្តិការរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុដោយមិនបានទទួលផលប្រយោជន៍អ្វីទាំងអស់ ។ ហើយនេះធ្វើអោយមានការចោទជាសំណួរឡើង ថាតើវាពិតដែរឬទេ ដែលអាជ្ញាធរមូលដ្ឋានពិតជាមិនបានទទួលការលើកទឹកចិត្តជាហិរញ្ញវត្ថុដើម្បីធ្វើអោយគាត់ចូលរួមក្នុងប្រតិបត្តការរបស់មីក្រូហិរញ្ញវត្ថុនោះ ជាពិសេសដោយដឹងថាក្នុងឃុំមួយអាចមានស្ថាប័នមីក្រូហិរញ្ញវត្ថុច្រើនជាងប្រាំស្ថាប័នធ្វើប្រតិបត្តិការទៅទៀតនោះ ។ អាជ្ញាធរមូលដ្ឋានក៏ត្រូវការឈានជើងចូលដោះស្រាយនៅពេលដែលមានជម្លោះដែលអាចកើតមានឡើងក្នុងប្រតិបត្តិការខ្ចី-សង ដូចដែលបានពន្យល់ក្នុងចំនុចទីពីខាងក្រោម។

" *ខ្ញុំជាហិរញ្ញិករបស់គណៈកម្មាធិការផ្តល់កម្ចីរបស់អម្រិត ទទួលខុសត្រូវលើក្រុមកម្ចីចំនួន ៧ក្រុមក្នុងភូមិចំនួន ៧ ។ តួនាទីរបស់ខ្ញុំគឺធ្វើការធានាថាសមាជិកសងបំណុលទៅអោយស្ថាប័នវិញបានទាន់ពេលវេលា ។ ពេលដែលខ្ញុំទៅប្រជុំ គណៈកម្មាធិការជាលើកដំបូង ខ្ញុំបានគិតថាខ្ញុំត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាឃុំសង្កាត់ ប៉ុន្តែការពិត វាជាការអញ្ជើញពីអម្រិតដើម្បីឲ្យខ្ញុំធ្វើជាសមាជិកក្នុងគណៈកម្មាធិការនេះ។*" បទសម្ភាសន៍ដោយអ្នកផ្តល់ព័ត៌មានសំខាន់ ខេត្តព្រៃវែង ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤។

*" ក្នុងឆ្នាំ ២០១២ ប្រាសាក់បានដកប្រតិបត្តិការរបស់ខ្លួនពីសហគមន៍នេសាទក្នុងឃុំរបស់ខ្ញុំ ។ មានគ្រួសារចំនួន ១២ ដែលបានខ្ចីប្រាក់ពីប្រាសាក់ ។ ពេលដែលបុគ្គលិករបស់ប្រាសាក់មកប្រមូលការសងប្រាក់ដើមនិងការប្រាក់ គ្រួសារមួយចំនួនអាចមានលទ្ធភាពសង តែគ្រួសារមួយចំនួនមិនមានលទ្ធភាព ។ មានពេលមួយគ្រួសារទាំង ១២ ចង់ធ្វើបាតុកម្ម ក្នុងគោលបំណងស្នើដល់ប្រាសាក់ឈប់ដាក់សំពាធក្នុងការសង ហើយពួកគាត់បានគម្រាមថាមិនសងបំណុលទៀតផង ។ ពួកគាត់បានហៅទូរស័ព្ទមកខ្ញុំដើម្បីជម្រាបខ្ញុំ ហើយបានស្នើរធ្វើបាតុកម្ម ។ ប៉ុន្តែខ្ញុំមានការព្រួយបារម្ភ ដូចនេះខ្ញុំឲ្យដំបូន្មានដល់គ្រួសារទាំង ១២ កុំទាន់អាលប្រញាប់ធ្វើដូចនេះ ហើយទុកឲ្យអាជ្ញាធរធ្វើការសម្របសម្រួល...."* បទសម្ភាសន៍ជាមួយ អ្នកផ្ដល់ព័ត៌មានសំខាន់ ខេត្តកំពង់ឆ្នាំង ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៤ ។ (សូមពិនិត្យមើលករណីលម្អិតខាងក្រោមក្នុងប្រអប់ IV នៅចុងបញ្ចប់នៃផ្នែកនេះ)។

ជាការអះអាងដោយច្បាប់មូលដ្ឋានរបស់សេដ្ឋកិច្ចទីផ្សារសេរី មិនមានក្របខណ្ឌច្បាប់ជាក់លាក់ណាមួយតាក់តែងឡើងសម្រាប់គ្រប់គ្រងកម្រិតនៃអត្រាការប្រាក់កម្ចីដែលផ្ដល់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជានោះទេ ។ មាត្រា ១ នៃប្រកាសស្ដីពីសេរីភាវូបនីយកម្មនៃអត្រាការប្រាក់បានចែងថា "ធនាគារ និងស្ថាប័នហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់ចំពោះប្រាក់សន្សំ និងអត្រាការប្រាក់លើប្រាក់កម្ចីទាំងចំពោះរូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេសដោយយោងទៅតាមគោលនយោបាយអត្រាការប្រាក់ និង លទ្ធភាពរបស់ស្ថាប័ននីមួយៗ" (ធនាគារជាតិ ឆ្នាំ ២០០៩) ។ វាជាការទុកអោយទីផ្សារជាអ្នកសម្រេច ហើយគេជឿថាការប្រកួតប្រជែងទាញចុះនូវតម្លៃអត្រាការប្រាក់កម្ចី ។ យ៉ាងណាមិញ ធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុ ត្រូវបង្ហាញនិងផ្ញើរអំពីអត្រាការប្រាក់ជាមធ្យមដែលគេបានកំណត់សម្រាប់ការសន្សំនិងកម្ចី ទៅអោយធនាគារជាតិជារៀងរាល់ខែ ។ ដើម្បីជាផលប្រយោជន៍ដល់អ្នកខ្ចីទាំងអស់ ធនាគារជាតិតម្រូវឲ្យស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ធ្វើការគណនាអត្រាការប្រាក់ដោយផ្អែកទៅលើគោលការណ៍រំលោះចំនួនកម្ចីនៅគ្រាដែលគេចាប់ផ្ដើមធ្វើការសង ។ មន្ត្រីជាន់ខ្ពស់មួយរូបពីធនាគារជាតិកម្ពុជា (NBC) បានអះអាងថា ធនាគារជាតិមានទស្សនៈថា គ្រប់ស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានប្រតិបត្តិការ ត្រូវធានាថាពួកគេអាចជម្រាបដល់អ្នកខ្ចីរបស់ខ្លួនពីព័ត៌មានទាំងអស់ជាពិសេសលើអត្រាការប្រាក់ អំពីថាតើអតិថិជនកំពុងបង់ប្រាក់លើអ្វី តើអ្វីជាការពិន័យចំពោះការបង់ប្រាក់យឺត និងមូលហេតុ ។ ដោយយោងទៅតាមនេះ ធនាគារជាតិសង្ឃឹមថានឹងមាការធានាបានថា មានការការពារដល់អ្នកប្រើប្រាស់ ហើយការងារនេះត្រូវបានអនុវត្តដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

ធនាគារអភិវឌ្ឍន៍ជនបទ (RDB) ដែលត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៨ ដែលមានអាជ្ញាប័ណ្ណក្នុងការធ្វើប្រតិបត្តិការជាធនាគារឯកទេស ទទួលបានមូលនិធិពីថវិការជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា AFD កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី និង កម្ចីពីមូលនិធិអន្តរជាតិដើម្បីការអភិវឌ្ឍន៍វិស័យកសិកម្ម (RDB ឆ្នាំ ២០១៤) ។ ដូចដែលបានរៀបរាប់ខាងលើ ការវិនិយោគដោយការឧបត្ថម្ភធនហិរញ្ញវត្ថុដោយរដ្ឋាភិបាល (៨លានដុល្លារ) សម្រាប់ពង្រីកការនាំចេញស្រូវនិងអង្ករ បានផ្តល់ទៅអោយធនាគារអភិវឌ្ឍន៍ជនបទ ។ ខណៈពេលដែលធនាគារអភិវឌ្ឍន៍ជនបទបានចាប់ដៃគូ[4]ជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងសមាគមកសិករមួយចំនួន បើប្រៀបធៀបទៅនឹងស្ថាប័នពាណិជ្ជកម្មដែលមានរចនាសម្ព័ន្ធត្រឹមត្រូវដូចជាសមាគមរោងម៉ាស៊ីនកិនស្រូវជាដើម ឃើញថាមិនមានការពិចារណាពិសេសណាមួយដល់កសិករខ្នាតតូច ឬបណ្តាញកសិករសហគមន៍ក្នុងការទទួលបានឥណទាន/កម្ចីនោះទេ ។

## ក. គម្រោងសន្សំប្រាក់ដែលបង្កើតដោយអង្គការមិនមែនរដ្ឋាភិបាល

នៅក្នុងស្រុកបរិបូរណ៍ អង្គការ AEC បានសម្របសម្រួលក្រុមសន្សំសហគមន៍នៅក្នុងឃុំចំនួន ២ ។ ក្រុមសន្សំប្រមូលប្រាក់សន្សំ ការប្រាក់ និងការសងប្រាក់ពីសមាជិកក្រុមនិងអ្នកខ្ចីប្រចាំត្រីមាស ។ ជាដំបូង ប្រាក់កម្ចីសម្រាប់សមាជិកគឺយកអត្រា ២ភាគរយក្នុងមួយខែ ។ គំរូសន្សំប្រាក់របស់អង្គការ AEC មានគោលបំណងក្នុងការចងក្រងសហគមន៍ និងប្រើប្រាស់ប្រាក់សន្សំមួយផ្នែកដើម្បីជាប្រភពគាំទ្រសកម្មភាពយុទ្ធនាការ ។ នៅពេលដែលគម្រោងសន្សំប្រាក់ស្ថិតក្នុងដំណាក់កាលឆ្នាំដំបូង អ្នកចូលរួមផ្តល់បទសម្ភាសន៍នៅក្នុងការសិក្សានេះបានរាយការណ៍ថា គេបានប្រើប្រាស់ប្រាក់កម្ចីពីគម្រោងសន្សំប្រាក់នេះ ។ យ៉ាងណាមិញ នៅក្នុងភូមិចំនួន ២ នៅក្នុងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង អង្គការ COFAP ធ្វើការលើមូលនិធិបង្វិលជាមួយនឹងកម្មវិធីផ្សេងទៀតរបស់អង្គការ ។ ប្រាក់កម្ចីត្រូវផ្តល់ទៅឱ្យសមាជិកដោយមិនយកការប្រាក់នៅក្នុងកម្មវិធីជីវភាព ។ វដ្តប្រាក់កម្ចីមានរយៈពេលពី ១០ ទៅ ១២ ខែ ។ ចំនួនប្រាក់កម្ចីអតិបរមាក្នុងមួយគ្រួសារគឺ ១ លានរៀល ។ គម្រោង PADEE នៅក្នុងស្រុកបាភ្នំគាំទ្រគម្រោងសន្សំប្រាក់ដែលបង្កើតដោយកសិករ ហើយប្រាក់កម្ចីបានពីគម្រោងនេះ សមាជិករបស់ខ្លួនអាចយកទៅគាំទ្រសកម្មភាពពាក់ព័ន្ធនឹងកសិកម្មបាន ។

---

[4] យោងតាមព័ត៌មានពីគេហទំព័ររបស់ RDB ដៃគូបច្ចុប្បន្នរបស់ RDB រួមមានអង្គរកសិកម្មរុងរឿង បៃតង សមាគមន៍កសិករ Aid (បន្ទាយមានជ័យ) CBIRD ( អាជីវកម្មកម្ពុជាដែលបានសមាហរណកម្មក្នុងភ្នាក់ងារអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង) ការកសាងសហគ្រិនភាពកម្ពុជា CHC (ស្ថាប័នមីក្រូហិរញ្ញវត្ថុ) EAP មូលនិធិអភិវឌ្ឍន៍សហភាពកម្មករ ហត្ថាកសិករ ឥណទានពលរដ្ឋរុងរឿងអិលធីឌី សមាគមខ្មែរអភិវឌ្ឍន៍ជនបទ (ខេត្តបាត់ដំបង) MAXIMA Mikroheranhvato Co.Ltd សម្ព័ន្ធសមាគមរោងម៉ាស៊ីនកិនស្រូវកម្ពុជា គ្រឹស្តទានពិសិដ្ឋអភិវឌ្ឍន៍សេដ្ឋកិច្ច ខូអិលធីធី សាមិ៉កមីក្រូហិរញ្ញវត្ថុ ការអភិវឌ្ឍន៍សង្គមនៅជនបទ សិលានិធិអិលធីឌី។

## ខ. ការប្រើប្រាស់ប្រាក់កម្ចីសម្រាប់ព្យាបាលជម្ងឺ

ធាតុផ្សំសំខាន់នៅក្នុងការស្ទង់មតិនេះ គឺស៊ើបអង្កេតអំពីចំនួនទឹកប្រាក់កម្ចីដែលអ្នកចូលរួមធ្វើបទសម្ភាសន៍ក្នុងចំណោមប្រជាជនដែលបានស្ទង់មតិយកទៅបង់ថ្លៃព្យាបាលជម្ងឺ ។ របកគំហើញពីការសិក្សាស្រាវជ្រាវនេះបង្ហាញថា គ្រួសារដែលបានធ្វើបទសម្ភាសន៍ចំនួន ៥៦.៤ភាគរយ (n= ៧៥) ធ្លាប់ខ្ចីប្រាក់ដើម្បីយកទៅបង់ថ្លៃព្យាបាលជម្ងឺនៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ ។ ក្នុងចំណោមចំនួនភាគរយនេះ អ្នកចូលរួមផ្តល់បទសម្ភាសន៍ចំនួន ២៣ភាគរយ បានខ្ចីប្រាក់ក្នុងរយៈពេល ៦-១២ ខែចុងក្រោយនេះ ។ អ្នកចូលរួមចំនួន ១៩.៥ភាគរយ បានខ្ចីប្រាក់ក្នុងចន្លោះពី ១៩-២៤ ខែ និង ចំនួន ១៥ភាគរយបានខ្ចីប្រាក់នៅក្នុងរយៈពេល ៦ ខែចុងក្រោយ ។

*ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០១៤ កូនខ្ញុំទាំង ២ នាក់កើតជម្ងឺគ្រុនចាញ់ ។ ដំបូង កូនប្រុសខ្ញុំក្តៅខ្លួនខ្លាំង ហើយខ្ញុំបានហៅគ្រូពេទ្យនៅក្នុងភូមិត្រពាំងធំឱ្យមកព្យាបាលកូនខ្ញុំនៅផ្ទះ។ ពីរថ្ងៃក្រោយបន្ទាប់ពីគ្រូបពេទ្យបានព្យូរស៊ើរ៉ូម និងឱ្យថ្នាំរួច កូនខ្ញុំនៅតែមិនធូរស្រាលឡើយ ដូច្នេះខ្ញុំត្រូវធ្វើតេស្តឈាម ។ លទ្ធផលចេញមកបង្ហាញថាកូនខ្ញុំមានជម្ងឺគ្រុនចាញ់ ។ ជាអកុសល ជម្ងឺរបស់កូនខ្ញុំឈានដល់ដំណាក់កាលធ្ងន់ធ្ងររួចទៅហើយ ដោយសារគាត់បន្ទោរបង់មកមានលាយឈាម ។ ខ្ញុំបារម្ភណាស់ ។ ខ្ញុំបាននាំគាត់ទៅរកពេទ្យឯកជននៅស្វាយអន្ទរ ហើយគាត់ក៏បានជាសះស្បើយរយៈពេល ៤ ថ្ងៃក្រោយ ។ យើងបានធ្វើតេស្តឈាមម្តងទៀត និងចេញវេជ្ជបញ្ជាថ្នាំ ។ គ្រូពេទ្យបានព្យូរស៊ើរ៉ូម និងចាក់ថ្នាំ ។ ខ្ញុំចំណាយអស់ប្រាក់ប្រហែល ៣៣ ម៉ឺនរៀល ។ ថ្លៃអាហារ និងថ្លៃចំណាយចាំបាច់ផ្សេងទៀតអស់ ១៧ ម៉ឺនរៀល ជាសរុបខ្ញុំចំណាយអស់ ៥០ ម៉ឺនរៀល (១២៥ ដុល្លារអាមេរិក) ។ បន្ទាប់ពីកូនប្រុសខ្ញុំបានជាសះស្បើយ កូនស្រីខ្ញុំកើតជម្ងឺគ្រុនចាញ់ម្តង ។ ជាថ្មីម្តងទៀត ខ្ញុំបានអញ្ជើញលោកគ្រូពេទ្យដដែលមកពីភូមិត្រពាំងធំមកព្យាបាលនាង បន្ទាប់មកនាងក៏បានជាសះស្បើយ ។ លើកនេះខ្ញុំចំណាយអស់ ២៧ ម៉ឺនរៀល (៦៧.៥ ដុល្លារអាមេរិក) សម្រាប់ការព្យាបាលអស់រយៈពេល ១ សប្តាហ៍ ។*

*ខ្ញុំបានចំណាយប្រាក់ដែលប្តីខ្ញុំផ្ញើមកពីថៃទាំងអស់ចំនួន ៨ ពាន់បាត ។ ជាសំណាងល្អដែលគាត់បានផ្ញើប្រាក់មកផ្ទះមុនពេលដែលកូនទាំង ២ ឈឺ បើមិនដូច្នោះទេ ខ្ញុំនឹងទៅខ្ចីប្រាក់គេដើម្បីយកទៅព្យាបាលជម្ងឺកូន ។ (បទសម្ភាសន៍ជាមួយចន្ទ នៅថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ខេត្តព្រៃវែង)។*

ការចំណាយលើថ្លៃព្យាបាលជម្ងឺ ត្រូវបានឲ្យដឹងដោយគ្រួសារដែលបានស្ទង់មតិថាជាចំណាយមួយក្នុងចំណោមចំណាយធំៗចំនួន ៣ នៅក្នុងគ្រួសារ ។ ចំណាយថ្លៃអាហារ តាងឱ្យចំណាយទី ១ និងច្រើនបំផុតនៅក្នុងគ្រួសារ (៨៣ភាគរយ n= ១១០) បន្ទាប់មកគឺចំណាយលើថ្លៃព្យាបាល (៦០ភាគរយ n= ៨០) និងចំណាយសង្គម ដូចជាពិធីការ/ពិធីបុណ្យ (៣៦ភាគរយ n= ៤៨) (សូមមើលឧបសម្ព័ន្ធ ៥) ។ ជាថ្មីម្តងទៀត អ្នកចូលរួមផ្តល់បទសម្ភាសន៍បានបញ្ជាក់សារជាថ្មីថាថ្លៃព្យាបាលជម្ងឺជាចំណាយសំខាន់មួយដែលពួកគាត់ត្រូវចំណាយ ។

ការចំណាយលើសេវាសុខភាព គឺជាចំណាយដ៏ចាំបាច់នៅក្នុងគ្រួសារ ហើយត្រូវចំណាយប្រាក់ច្រើន ។ របកគំហើញពីអ្នកចូលរួមផ្តល់បទសម្ភាសន៍ច្រើនជាង៥៦ភាគរយដែលខ្ចីប្រាក់ដើម្បីចំណាយលើសេវាសុខភាពតែមួយមុខ គឺជាបញ្ហាសំខាន់ ហើយបញ្ហានេះបានបញ្ជាក់ពីកម្រិតខ្ពស់នៃការចំណាយពីហោប៉ៅរបស់គ្រួសារនៅជនបទ ជាពិសេសគ្រួសារក្រីក្រ និងក្រីក្របំផុត ដែលវាធ្វើឱ្យពួកគេកាន់តែក្រជាងមុនទៅទៀត ដោយសារតែអត្រាការប្រាក់សម្រាប់ការប្រើប្រាស់នៅក្នុងការរស់នៅ និងការប្រើប្រាស់មិនមែនសម្រាប់ផលិតកម្មមានកម្រិតខ្ពស់ ។

## គ. ការប្រើប្រាស់សេវាសុខភាព

លទ្ធផលនៅក្នុងការស្ទង់មតិនេះមិនខុសពីការសិក្សាស្រាវជ្រាវមុនៗពាក់ព័ន្ធនឹងការប្រើប្រាស់សេវាថែទាំសុខភាពនោះទេ ។ អ្នកចូលរួមផ្តល់បទសម្ភាសន៍ចំនួន ២ ភាគ ៣ តាមការស្ទង់មតិនេះចូលចិត្តប្រើសេវាសុខភាពរបស់ស្ថាប័នឯកជន ខណៈដែលចំនួន២៨ភាគរយ ចូលចិត្តប្រើសេវាសុខភាពសាធារណៈ នៅពេលដែលពួកគាត់ឬក្រុមគ្រួសារគាត់មានជម្ងឺ ។ ជារឿយៗ ពួកគេធ្វើការរងចាំ និងមើលការវិវឌ្ឍន៍នៃជម្ងឺ ហើយជាចុងក្រោយសម្រេចចិត្តទៅរកការព្យាបាលពីសំណាក់ពេទ្យឯកជនមុននឹងទៅរកការព្យាបាលកម្រិត (កម្រិតខ្ពស់ជាងនេះ) មួយផ្សេងទៀត ។ ការពន្យារពេលព្យាបាលជម្ងឺនេះ បណ្តាលឱ្យការចំណាយព្យាបាលកាន់តែច្រើន ឬធ្វើឱ្យជម្ងឺកាន់តែធ្ងន់ធ្ងរ ។ ដោយអ្នកចូលរួមផ្តល់បទសម្ភាសន៍ខាងក្រោមបានបង្ហាញឱ្យដឹង ៖

*រូបភាពទី១២៖ ការប្រើប្រាស់សេវាព្យាបាលជម្ងឺ*




*នាពេលថ្មីៗនេះ កូនប្រុសខ្ញុំមានជម្ងឺផ្លូវដង្ហើម ។ ដំបូងខ្ញុំយកកូនខ្ញុំទៅរកពេទ្យឯកជននៅក្នុងភូមិ ។ ប៉ុន្តែកូនខ្ញុំមិនបានធូរស្បើយឡើយ ដូច្នេះខ្ញុំក៏បញ្ជូនគាត់ទៅគ្លីនិកឯកជននៅក្រុងពន្លៃ (ប្រហែល៦គីឡូម៉ែត្រពីភូមិ)។ ខ្ញុំចំណាយអស់ប្រាក់ប្រហែល ៦០ ម៉ឺនរៀលទៅលើថ្នាំពេទ្យ ក្នុងពេលព្យាបាលរយៈពេល ២ ខែចុងក្រោយនេះ ។ ខ្ញុំបានខ្ចីប្រាក់ ២០ ម៉ឺនរៀលពីម្តាយខ្ញុំ និងបានយកលុយសន្សំទៅចំណាយលើថ្លៃព្យាបាលនោះ ។ កូនប្រុសខ្ញុំនៅមិនទាន់ជាសះស្បើយពេញលេញនៅឡើយទេ ហើយខ្ញុំត្រូវនាំគាត់ទៅរកពេទ្យម្តងទៀត ។* (បទសម្ភាសន៍ជាមួយថាវី នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៤ នៅខេត្តកំពង់ឆ្នាំង)

ដូចក្នុងរូបភាពទី ១៣ បានចង្អុលបង្ហាញចំនួនអ្នកចូលរួមផ្តល់បទសម្ភាសន៍ រាយការណ៍ថា ពួកគាត់ទៅមណ្ឌលសុខភាពនៅពេលពួកគាត់មានជម្ងឺ មានចំនួនខ្ពស់បំផុតគឺ (៣៨ភាគរយ) បន្ទាប់មកគឺចំនួនអ្នកដែលទិញថ្នាំពីឱសថស្ថាន និងទៅគ្លីនិកឯកជនក្នុងស្រុក (ចំនួន ៣២ភាគរយ) ។ ក៏ប៉ុន្តែ គ្រួសារដែលចូលរួមធ្វើបទសម្ភាសន៍ដែលប្រើសេវាការព្យាបាលនៅតែមានចំនួនតិចនៅឡើយសម្រាប់ជម្រើសទាំងអស់។

*រូបភាពទី១៣៖ អាកប្បកិរិយាក្នុងការស្វែងរកការព្យាបាលជម្ងឺ*




ក្រាហ្វិកនៅខាងស្តាំបង្ហាញពីបញ្ហាប្រឈមចំបងចំនួន ៥ ដែលបានរៀបរាប់ដោយអ្នកចូលរួមផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាថៃទាំសុខភាព ។ ការខ្វះលុយកាក់សម្រាប់ចំណាយលើការព្យាបាលជម្ងឺត្រូវបានរាយការណ៍ថាជាកត្តាប្រឈមខ្លាំងបំផុត (៦១ភាគរយ) ថ្លៃព្យាបាលជម្ងឺ (៥៩ភាគរយ) និង ការខាតពេលមើលអ្នកជម្ងឺនិងថ្លៃសេវា (៥៥ភាគរយ) ។ របកគំហើញពីបញ្ហាប្រឈមគន្លឹះ បានអះអាងជាថ្មីពីការសិក្សាស្រាវជ្រាវមុនៗអំពីកត្តាចំបងៗដែលរារាំងប្រជាជនក្រីក្រមិនអោយទទួលបានសេវាថៃទាំសុខភាព ទទួលបានហិរញ្ញវត្ថុ ត្រូវចំណាយលើសេវា និងការខាតបាត់បង់ផ្នែកសេដ្ឋកិច្ច ។ សូមពិនិត្យមើល (Annear, Wilkinson et al ឆ្នាំ ២០០៦) ចំពោះជម្រើសព្យាបាលជម្ងឺពេលមានសមាជិកគ្រួសារឈឺ អ្នកចូលរួមផ្តល់បទសម្ភាសន៍នៅក្នុងការសិក្សាស្រាវជ្រាវនេះបញ្ជាក់ថាពួកគាត់តែងតែទៅរកសេវាព្យាបាលជម្ងឺពីពេទ្យឯកជនជាជាងទៅមណ្ឌលសុខភាពសាធារណៈ ដែលមានចំនួន៧១ភាគរយបើប្រៀបទៅនឹង២៨ភាគរយ (សូមមើលតារាងលេខ ៧ ខាងក្រោម) ។ ដំណើរការមណ្ឌលសុខភាពសាធារណៈនៅក្នុងតំបន់នៃការសិក្សាស្រាវជ្រាវនេះ នៅតែជាបញ្ហាគួរអោយបារម្ភ ដោយសារមូលហេតុមួយចំនួន ។ មូលហេតុមួយក្នុងមូលហេតុផ្សេងៗ គឺកង្វះធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រដំណើរការរបស់មណ្ឌលសុខភាព ដូចមានចង្អុលបង្ហាញនៅក្នុងបទសម្ភាសន៍ ។ ក្រៅពីចំងាយ[5]ពីផ្ទះ/ភូមិទៅមណ្ឌលសុខភាព ក្រុមការងារ

[5] ចំងាយមិនមែនជាបញ្ហាសំខាន់នៅក្នុងភូមិដែលយើងបានស្រាវជ្រាវទេ ដោយសារចំងាយនៅជិតមណ្ឌលសុខភាព

ស្រាវជ្រាវបានសង្កេតឃើញថា ជាទូទៅ បុគ្គលិកសុខាភិបាលធ្វើការ និងប្រតិបត្តិការមណ្ឌលសុខភាពនៅពេលព្រឹក[6] ។

***តារាងទី ៧៖ ការប្រើប្រាស់មណ្ឌលសុខភាពសាធារណៈ និងគ្លីនិកឯកជន***

| ការប្រើប្រាស់សេវាសុខភាព | ចំនួន | ភាគរយ |
|---|---|---|
| មណ្ឌលសុខភាពសាធារណៈ | 37 | 28 |
| គ្លីនិកឯកជន | 94 | 70.7 |
| ខ្វះទិន្នន័យ | 2 | 1.3 |
| សរុប | 133 | 100 |

ចំពោះការទទួលបានសេវាសុខភាពដោយឥតគិតថ្លៃ ការសិក្សាស្រាវជ្រាវរបស់យើងបានរកឃើញថាអ្នកចូលរួមផ្តល់បទសម្ភាសន៍ចំនួន២៤ភាគរយ (n= ៣២) បានរាយការណ៍ថាពួកគាត់ធ្លាប់ទទួលបានសេវាថែទាំសុខភាពដោយឥតថ្លៃ និងចំនួន៧៦ភាគរយ (n= ១០១) មិនទទួលបានសេវាដោយឥតគិតថ្លៃនោះទេ ។ ចំពោះអ្នកចូលរួមផ្តល់បទសម្ភាសន៍ដែលធ្លាប់ទទួលបានសេវាព្យាបាលជម្ងឺដោយឥតគិតថ្លៃ ពួកគាត់ទទួលបានតាមរយៈកាតមូលនិធិសមធម៌សុខភាព (១៨.៨ភាគរយ) ដែលអង្គការមិនមែនរដ្ឋាភិបាលជាអ្នកចំណាយ (១០ភាគរយ) ហើយចំនួនអ្នកដែលទទួលបានការលើកលែងពីស្ថាប័នផ្តល់សេវាសុខភាពនៅតែមានចំនួនទាប (៣ភាគរយ) ។ នៅក្នុងភូមិដែលយើងបានធ្វើការសិក្សាស្រាវជ្រាវនេះ នៅក្នុងខេត្តកំពង់ឆ្នាំង អង្គការ RHAC កំពុងអនុវត្តកម្មវិធីមូលនិធិសមធម៌សុខភាព ដែលគ្រួសារក្រីក្រនិងក្រីក្របំផុតដែលជាអ្នកកាន់កាតមូលនិធិសមធម៌សុខភាពអាចប្រើប្រាស់សេវាសុខភាពនៅមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែកនៅពេលចាំបាច់ ។ ទីតាំងមូលនិធិសមធម៌សុខភាពជាច្រើនទៀតនឹងរំពឹងថាត្រូវបានពង្រីកបន្ថែមដូចដែលបានលើកឡើងដោយប្រធានមណ្ឌលសុខភាព និងនាយកស្រុកប្រតិបត្តិដែលបានសម្ភាសន៍នៅខេត្តកំពង់ឆ្នាំង និងព្រៃវែង ដែលនេះរំពឹងថាមានការផ្តល់សេវាថែទាំសុខភាពបានកាន់តែទូលាយដល់គ្រួសារក្រីក្របំផុត (I&II) ។ ក៏ប៉ុន្តែ វាមានតម្រូវការអោយមានការលើកកំពស់លើការយល់ដឹងអំពីមូលនិធិសមធម៌សុខ

[6] ក្រុមការងារស្រាវជ្រាវបានធ្វើបទសម្ភាសន៍ជាមួយនឹងប្រធានមណ្ឌលសុខភាពមួយនៅពេលរសៀល ហើយគាត់មកបើកទ្វារចូលទៅក្នុងមណ្ឌលសុខភាព ។ ក្នុងអំឡុងពេលសម្ភាសន៍រយៈពេលជិត ២ ម៉ោង គ្មានអ្នកណាម្នាក់មកមណ្ឌលសុខភាពនោះទេ

ភាព ហើយនិងអំពីរបៀបប្រើប្រាស់មូលនិធិសមធម៌សុខភាពដល់គ្រួសារដែលមានកាត ដើម្បីធានាថាពួកគាត់អាចប្រើប្រាស់សេវាកម្មចាំបាច់បាន ហើយរាល់បញ្ហាប្រឈមត្រូវដោះស្រាយ ។

## ៣.៤ ផលប៉ះពាល់ពីបំណុល និងយន្តការដោះស្រាយបញ្ហារបស់គ្រួសារ

យន្តការដោះស្រាយដែលក្រុមគ្រួសារនៅក្នុងការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាបំណុល និង បញ្ហាសុខភាព គឺជាយន្តការដែលបានប្រើប្រាស់ក្នុងបញ្ហាផ្សេងៗទៀត ។ តាមរយៈការអង្កេត ឃើញថាក្រុមគ្រួសារដែលបានស្ទង់មតិពឹងផ្អែកលើការខ្ចីបំណុលថ្មីពីប្រភពហិរញ្ញវត្ថុក្នុងប្រពន្ធ័ និងក្រៅប្រពន្ធ័ដើម្បីចំណាយទៅលើសេវាសុខភាព និង សងបំណុលព្រមទាំងលក់អង្ករ និង/ឬសត្វពាហនៈ និងចំណាកស្រុកដើម្បីរកចំណូលបន្ថែម ។

ចំណាកស្រុកទៅរកការងារធ្វើទាំងតាមរដូវកាល និង ជាអចិន្ត្រៃយ៍ គឺជាយន្តការដោះស្រាយបំណុលរបស់ក្រុមគ្រួសារនៅក្នុងភូមិដែលបានផ្តល់បទសម្ភាសន៍ ។ គោលដៅចំណាកស្រុកក្នុងប្រទេស រួមមានការងាររោងចក្រនៅភ្នំពេញ ខេត្តកំពង់ឆ្នាំង ការងារសំណង់ និងចំការជាពិសេសនៅក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅក្រចេះ ខេត្តពោធិសាត់ កំពង់ចាម មណ្ឌលគីរី ភ្នំពេញ ឬតំបន់ផ្សេងនៅតាមព្រំដែនខ្មែរថៃ ។ បទសម្ភាសន៍ស៊ីជម្រៅនៅខេត្តព្រៃវែង បង្ហាញពីបាតុភូតនៃការកើនឡើងចំនួនអ្នកចំណាកស្រុកទៅធ្វើការនៅក្នុងផ្នែកសំណង់ រោងចក្រអេឡិចត្រូនិច ចំណីអាហារ និងដែកនៅក្នុងប្រទេសថៃ ។ គ្រួសារខ្លះដែលក្រុមការងារស្រាវជ្រាវបាននិយាយជាមួយបានទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ ខណៈពេលដែលអ្នកខ្លះទៀតប្រើវិធីក្រៅផ្លូវច្បាប់ដើម្បីបានទៅប្រទេសថៃ ។ សេចក្តីដកស្រង់ខាងក្រោមបានបង្ហាញពីយន្តការដែលក្រុមគ្រួសារមើលឃើញថាការចំណាកកស្រុកទៅរកការងារ ជាវិធីដោះស្រាយបំណុលគ្រួសារ។

> *"ខ្ញុំមិនទាន់ខ្ចីបុលនៅឡើយទេ ។ ប៉ុន្តែ ខ្ញុំអាចជាប់បំណុលផ្សេងប្រសិនបើស្ថានភាព (សុខភាព) ឪពុកខ្ញុំមិនល្អប្រសើរនោះ ។ ខ្ញុំនឹងលក់ដីស្រែខ្លះ ប្រសិនបើមិនគ្រប់ ខ្ញុំគ្មានជម្រើសទេ ប៉ុន្តែខ្ញុំនឹងខ្ចីប្រាក់បន្ថែមពីបងប្អូនខ្ញុំ ។ អត្រាការប្រាក់ទាបជាងស្ថាប័នទាំងនោះ (សំដៅលើស្ថាប័នមីក្រូហិរញ្ញវត្ថុ) ហើយ ដោយសារខ្ញុំគ្មានទ្រព្យសម្បត្តិអ្វីផ្សេងទៀតសម្រាប់ដាក់បញ្ចាំ.... ប្រាក់ដែលកូនស្រីខ្ញុំផ្ញើមក ខ្ញុំបានយកទៅបង់ការប្រាក់ ចំណាយលើថ្លៃព្យាបាលឪពុកខ្ញុំ និងជីវភាពប្រចាំថ្ងៃ ជាពិសេសថ្លៃអាហារ ។ ដោយសារតែប្រាក់បញ្ញើរមិនមានអីច្រើននោះទេ ដូចនេះខ្ញុំមិនអាចសងបំណុលអស់នោះទេ"* បទសម្ភាសន៍ជាមួយនឹងពិសី នៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ នៅខេត្តព្រៃវែង។

ក្រៅពីការងាររោងចក្រ និងសំណង់ អ្នកភូមិនៅក្នុងការសិក្សាស្រាវជ្រាវនេះ នៅក្នុងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ពួកគាត់អាចធ្វើការជាពលករនៅចំការដំឡូងនៅក្រុមហ៊ុនភាពីម៉ិច ។ នេះជាឱកាសការងារសម្រាប់អ្នកដែលស្វែងរកការងារតាមរដូវកាល ឬអចិន្ត្រៃយ៍នៅចំការ ។ ប្រាក់ឈ្នួលប្រចាំថ្ងៃបើកបានភ្លាមៗ គឺជាជម្រើសដែលពលករចង់បានបើទោះជាមិនមានការការពារសិទ្ធិការងារ សុខភាព និង/ឬការការពារសុខមាលភាពផ្សេងៗសម្រាប់ពលករក៏ដោយ ។ គ្រួសារជាច្រើនដែលក្រុមការងារស្រាវជ្រាវបានសម្ភាសន៍ជាមួយ គឺធ្លាប់ធ្វើការនៅទីនោះ ឬមានសាច់ញាតិបងប្អូនកំពុងធ្វើការនៅតាមចំការ ។ សេចក្តីដកស្រង់ខាងក្រោមចង្អុលបង្ហាញពីប្រាក់ឈ្នួល និងលក្ខខណ្ឌនៅចំការៈ

> *"នៅក្នុងគ្រួសារខ្ញុំ ឪពុកខ្ញុំ បងស្រី ២ នាក់ ប្អូនប្រុសម្នាក់ និងបងថ្លៃប្រុសម្នាក់សុទ្ធតែធ្វើការនៅចំការដំឡូង ។ មានតែម្តាយខ្ញុំទេដែលនៅផ្ទះ ពេលខ្លះគាត់ទៅលេងឪពុក និងបងប្អូនខ្ញុំនៅចំការដើម្បីយកអាហារក្រៀមទៅឱ្យពួកគាត់... ខ្ញុំក៏ធ្លាប់ទៅធ្វើការនៅចំការកាលពីឆ្នាំមុនដែរ បន្ទាប់ពីខ្ញុំធ្វើស្រែរួច ។ ខ្ញុំរកប្រាក់បាន ២ ម៉ឺនរៀល និងអង្ករ ១ គីឡូក្រាមក្នុងមួយថ្ងៃ ។ គេផ្តល់អង្ករឱ្យជារៀងរាល់ ៥ ថ្ងៃម្តង ប៉ុន្តែគេឱ្យប្រាក់ឈ្នួលរៀងរាល់ ១០ ថ្ងៃ... ខ្ញុំទៅចំការដោយជិះតាឡេថង ។ ខ្ញុំត្រូវចេញពីផ្ទះពីម៉ោង ៤ ភ្លឺ និងមកដល់ចំការនៅម៉ោង ៦ កន្លះ ។ ខ្ញុំដើរពីផ្ទះទៅដល់ផ្លូវធំដើម្បីទៅជិះតាឡេថងជាមួយពលករផ្សេងទៀត ។ ខ្ញុំចំណាយប្រាក់ ៣ ម៉ឺនរៀលរៀងរាល់ខែសម្រាប់មធ្យោបាយធ្វើដំណើរនេះ ។ ម៉ោងធ្វើការគឺចាប់ពីម៉ោង ៧ ដល់ម៉ោង ១១ និងចាប់ផ្តើមឡើងវិញពីម៉ោង ១ ដល់ម៉ោង ៥ ។ ខ្ញុំមកដល់ផ្ទះវិញនៅម៉ោង ៧ ល្ងាច ។ ខ្ញុំញុំាបាយថ្ងៃត្រង់ជាមួយនឹងប្អូនស្រីខ្ញុំដែលស្នាក់នៅផ្ទះខ្ទមនៅក្នុងចំការ ។ សម្រាប់អ្នកផ្សេងដែលមិនមានសាច់ញាតិ ពួកគេបានខ្ចប់បាយពីផ្ទះមក..."*
>
> បទសម្ភាសន៍ធ្វើនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤ នៅខេត្តកំពង់ឆ្នាំង។

លក្ខខ័ណ្ឌការងារបច្ចុប្បន្ននៅចំការដំឡូងធ្វើឱ្យមានការលើកឡើងជាសំណួរ និងក្តីបារម្ភជុំវិញកិច្ចការពារ ។ អាជ្ញាធរមូលដ្ឋានភូមិនិងឃុំនៅកន្លែងដែលយើងចុះស្រាវជ្រាវនៅស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំងបានបង្ហាញពីការបារម្ភយ៉ាងខ្លាំងពីអលទ្ធភាពក្នុងការផ្តល់កិច្ចអន្តរាគមន៍នៅពេលមានជម្លោះការងារ និង/ឬជម្លោះផ្សេងទៀតកើតមកលើពលករដែលមកពីភូមិក្រោមការគ្រប់គ្រងរបស់ពួកគាត់ ។ បញ្ហាដែលកំណត់ដោយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងការងារនៅចំការដំឡូងរួមមានការបង់ប្រាក់ឈ្នួលយឺត ការដាក់ការងារអោយធ្វើច្រើនពេក ឬពលករមានទំនាក់ទំនងស្នេហាហើយបណ្តាលអោយមានផ្ទៃពោះដោយមិនចង់បាន ។ ទោះបីជាស្ថិតក្នុងដែនសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋានក៏ដោយ ក៏ពួកគាត់មិនអាចធ្វើការចុះត្រួតពិនិត្តលក្ខខ័ណ្ឌការងារ ឬចុះទៅទស្សនកិច្ច

នៅចំការដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុនបានឡើយ ហើយនេះធ្វើឱ្យប្រតិបត្តិការនេះមានឯករាជ្យពីការអនុវត្តតាមច្បាប់ ។ ដោយយោងតាមមេឃុំដែលយើងបានសម្ភាសន៍៖

> *"... នៅពេលក្រុមហ៊ុនរើសពលករ ក្រុមហ៊ុនប្រកាសតាមសារព័ត៌មាន ឬតាមការប្រាប់តៗគ្នា ។ ប្រជាជនចេញពីភូមិយើងទៅធ្វើការនៅចំការដោយគ្មានជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានទេ ។ ក្នុងករណីដែលមានតម្រូវការដូចជាធ្វើលិខិតបញ្ជាក់ទីលំនៅ ឬអត្តសញ្ញាណ ទើបយើងដឹងពីការងាររបស់ពួកគាត់... ឬនៅពេលពួកគាត់ជួបបញ្ហា ។ ឧទាហរណ៍ នៅពាក់កណ្តាលឆ្នាំ ២០១២ ពួកគេស្វែងរកការអន្តរាគមន៍ពីយើងពាក់ព័ន្ធការបង់ប្រាក់ឈ្នួលយឺត ។ ប៉ុន្តែយើងមិនអាចជួយបានទេដោយសារចំការស្ថិតនៅស្រុកផ្សេងដែលនៅក្រៅយុត្តាធិការរបស់ពួកយើង..."* បទសម្ភាសន៍ជាមួយមេឃុំ នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៤ នៅខេត្តកំពង់ឆ្នាំង។

វាអាចនិយាយបានទៀតថា ចំការជំទ្បងផ្តល់ការងារដែលជាប្រភពចំណូលរបស់ប្រជាជនរស់នៅជុំវិញចំការ ។ ប៉ុន្តែ បញ្ហាដែលមិនអាចមើលរំលងបាននោះ គឺជម្លោះដែលកើតមានឡើងដោយសារការបាត់បង់ដី និងការមិនអាចប្រើប្រាស់បាននូវធនធានរួម ដែលជាលទ្ធផលនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុនដូចជាក្រុមហ៊ុនភាពីម៉ិចដោយរដ្ឋាភិបាលជាដើម ។ បន្ថែមទៅលើការមិនអាចប្រើប្រាស់បាននូវធនធាន មានការបារម្ភណ៍ជាខ្លាំងអំពីលក្ខខ័ណ្ឌសិទ្ធិការងារ និងផលប៉ះពាល់ដល់សុខភាពពលករ ដែលបច្ចុប្បន្ននេះមិនមានការពិភាក្សា/ការពិចារណាទៅលើលក្ខខ័ណ្ឌការងារនៅចំការកសិកម្មនៅឡើយ ។ ការសិក្សាស្រាវជ្រាវដោយឡែកទៅលើបញ្ហានេះនឹងក្លាយជាជម្រើសដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់ស្វែងយល់អំពីលក្ខខ័ណ្ឌ និងផលប្រយោជន៍លម្អិតដែលផ្តល់ដោយចំការមកប្រជាជនមូលដ្ឋាន ។

ការរីកចំរើនផ្នែកសេដ្ឋកិច្ចនៅកម្រិតគ្រួសារដែលឃើញនេះ អាចអរគុណចំពោះប្រាក់បញ្ញើរពីពលករនៅប្រទេសថៃ ។ យើងឃើញផ្ទះដែលទើបសង់ថ្មីនៅក្នុងភូមិក្នុងខេត្តព្រៃវែង ជាសញ្ញានៃភាពរុងរឿងដែលមិនគួរមើលរំលង ។ ជាទូទៅ ការផ្លាស់ប្តូរនេះត្រូវបានហៅថាជាភាពរុងរឿងផ្នែកសេដ្ឋកិច្ចខណៈដែលបំណុលដែលគ្រួសារជំពាក់នៅមុនពេល និងក្នុងពេលធ្វើការត្រូវបានបិទបាំង ។ ការបណ្តេញចេញពលករខ្មែរទាំងពលករស្របច្បាប់ និងមិនស្របច្បាប់ ចេញពីប្រទេសថៃនាពេលថ្មីៗនេះ ឃើញថាមានផលប៉ះពាល់គួរអោយកត់សំគាល់មកលើសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់គ្រួសារ និងជនដែលពឹងផ្អែកលើប្រាក់បញ្ញើរ ។

**ប្រអប់ទី ៣៖ បំណុលទៅលើសេវាសុខភាព កើនឡើងបីដង**

នៅលើដីស្រែកន្លះហិចតា គ្រួសាររបស់ស៊ីនួនប្រមូលផលបានស្រូវ ១ តោននៅរដូវប្រមូលផលនាពេលថ្មីៗនេះ ។ គ្រួសារនាងសម្រេចចិត្តលក់ស្រូវចំនួន ៥០០ គីឡូក្រាម ដោយសារពួកគាត់ត្រូវការប្រាក់ដើម្បីបំពេញតម្រូវការជាមូលដ្ឋាន ការព្យាបាលជម្ងឺ និងកាតព្វកិច្ចចូលរួមពិធីបុណ្យផ្សេង ។ តម្លៃស្រូវ ១ គីឡូក្រាម ស្មើនឹង ៧៥០ រៀល ដូចនេះពួកគេបានប្រាក់សរុប ៣៧៥,០០០ រៀល ។ គ្រួសារនាងធ្វើស្រែបានតែម្តងប៉ុណ្ណោះក្នុង ១ ឆ្នាំ ដោយសារគ្មានទឹកគ្រប់គ្រាន់នៅរដូវរាំងស្ងួត ។ ស៊ីនួនបាននិយាយថាគ្រួសារនាងមិនមានប្រាក់ជីកអណ្តូងសម្រាប់ធ្វើស្រែប្រាំងនោះទេ ។ ពួកគេប្រើពូជស្រូវក្នុងស្រុក ដូចជាក្រសាំងទាប ។ ឆ្នាំមុន ពួកគាត់ប្រើជីគីមីចំនួន ៣-៤ បាវ ចំនួន ២ ប្រភេទ៖ ម៉ាកអាមេរិក និងហ្វីលីពីន ដោយដាក់ជីចំនួន ៣ ដង ។ ជីគីមីទិញក្នុងតម្លៃ ១៥០,០០០ រៀលក្នុងមួយបាវ ។ ពួកគេជួលមនុស្សឱ្យបាចថ្នាំសម្លាប់សត្វល្អិត ។ ថ្លៃបាចថ្នាំសត្វល្អិតសម្រាប់ស្រែ ១ ហិចតា គឺមានតម្លៃ ៣០,០០០ រៀល (រួមទាំងថ្លៃថ្នាំសត្វល្អិត) ។

> *"កូនស្រីយើងធ្វើការនៅរោងចក្រ ។ នាងផ្ញើប្រាក់មកផ្ទះជាញឹកញាប់បន្ទាប់ពីនាងទុកប្រាក់ខ្លះសម្រាប់ចំណាយផ្ទាល់ខ្លួន ។ ជាធម្មតា ប្រសិនបើនាងមិនឈឺទេ នាងផ្ញើប្រាក់មកប្រហែល ២០, ៣០ ឬ ៥០ ដុល្លារអាមេរិកមកផ្ទះ ។ ប៉ុន្តែបើនាងឈឺ នាងមិនផ្ញើប្រាក់មកផ្ទះទេ ដោយសារនាងត្រូវការចំណាយទិញថ្នាំ និងរបស់ប្រើប្រាស់ ។ ថ្លៃជួលបន្ទប់ក៏ឡើងថ្លៃដែរ ។ នាងចំណាយ ៣០ ដុល្លារក្នុងមួយខែសម្រាប់ជួលផ្ទះ។"*

ស៊ីនួនមានជម្ងឺឈឺក្រពះធ្ងន់ធ្ងរ ដែលធ្វើឱ្យនាងឈឺខ្ទង ។ ថ្មីៗនេះ នាងទៅព្យាបាលជាច្រើនដងនៅក្រុងព្រៃវែង និងភ្នំពេញ ដែលធ្វើឱ្យគ្រួសារនាងជំពាក់បំណុលជាច្រើន ។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០១៤ មក នាងទៅពិនិត្យជម្ងឺអស់ ៣ ដងហើយ ។ ជាដំបូង នាងបានឆ្លុះ X ray ពិនិត្យមើលពីស្ថានភាពក្រពះ នៅគ្លីនិកឈ្មោះ លី ពី នៅក្បែរក្រុង ។ បន្ទាប់ពីឆ្លុះរួច គ្រូពេទ្យបានបញ្ជាក់ថាជម្ងឺរបស់នាងធ្ងន់ធ្ងរមិនអាចព្យាបាលបាន ។ គ្រូពេទ្យបានឱ្យថ្នាំនាងមួយចំនួន និងផ្តាំឱ្យនាងទៅព្យាបាលជម្ងឺនៅភ្នំពេញ ។ នាងចំណាយអស់ប្រាក់ ៣០ ម៉ឺនរៀលសម្រាប់ថ្នាំពេទ្យ (៣ ដង ដោយ ១ ដងៗចំណាយអស់ប្រាក់ ១០ ម៉ឺនរៀល) ។ លើកទី ២ នាងទៅរកពេទ្យ ២ ដងនៅក្រុងស្នេហ៍ ។ នាងចំណាយអស់ប្រាក់ ២០ ម៉ឺនរៀលដើម្បីព្យាបាលនៅទីនោះ ។ នាងទៅរកព្យាបាលជម្ងឺជាលើកទី ៣ នៅមន្ទីរពេទ្យរដ្ឋនៅស្ទឹងមានជ័យ (នាងមិនចាំឈ្មោះទេ) ។ នាងប្រឹក្សាជាមួយគ្រូពេទ្យ ដែលនាងគិតថាគាត់នៅវ័យក្មេង និងទំនងដូចជាគ្មានបទពិសោធន៍ ។ នាងស្នាក់នៅមន្ទីរពេទ្យអស់រយៈ

ពេល ៣ ថ្ងៃ និងចំណាយអស់ប្រាក់ ២០ ម៉ឺនរៀលប៉ុណ្ណោះលើថ្នាំពេទ្យ ។ ស៊ីនួនរអ៊ូថានៅពេលដែលទៅព្យាបាលជម្ងឺនៅកន្លែងថ្មី ឯកសារ និងការធ្វើតេស្តដែលនាងមានពីពេលមុនត្រូវទុកជាមិនបានការ ។ បុគ្គលិកពេទ្យតែងតែស្នើសុំឱ្យនាងធ្វើតេស្តថ្មីលើជម្ងឺដដែល ហើយធ្វើឱ្យនាងចំណាយប្រាក់កាន់តែច្រើន ។ ពេទ្យទាំងនោះនិយាយថាពួកគេមិនជឿលើលទ្ធផលពីមុននោះទេ ។

*"បន្ទាប់ពីទៅព្យាបាលជម្ងឺនៅ ៣ កន្លែងរួចមក ហើយជម្ងឺរបស់ខ្ញុំនៅតែមិនប្រសើរឡើង កូនស្រីខ្ញុំដែលធ្វើការនៅរោងចក្របានប្រាប់ខ្ញុំឱ្យទៅគ្លីនិកឯកជនដែលនាងនិងពលករផ្សេងទៀតធ្លាប់ទៅនៅបែកចាន ។ គ្រូពេទ្យនៅទីនោះបានពិនិត្យសម្លេងអុលត្រានៅត្រង់ក្រពះ និងខាងខ្នង ។ ទោះបីជាខ្ញុំយកលទ្ធផល X ray ថ្មីៗនេះទៅបង្ហាញពេទ្យក្តី ពួកគេនិយាយថា "យើងត្រូវធ្វើវាម្តងទៀតនៅគ្លីនិករបស់យើងដូចនេះយើងអាចជឿជាក់លើលទ្ធផលបាន" ។ ពួកគេចាក់ថ្នាំខ្ញុំ និងដាក់ស៊ីរ៉ូមឱ្យខ្ញុំ ៣ ដងក្នុងមួយថ្ងៃអស់រយៈពេល ៣ ថ្ងៃ ។ ខ្ញុំចំណាយប្រាក់អស់ ១០០ ដុល្លារអាមេរិកដើម្បីព្យាបាល។"*

ស៊ីនួនបានលើកឡើងថាការព្យាបាលនៅគ្លីនិកនៅបែកចានធ្វើឱ្យនាងបានធូរស្បើយ ។ ការព្យាបាលជម្ងឺចំណាយអស់ ១០០ ដុល្លារអាមេរិក ដែលនាងត្រូវខ្ចី ៥០ ដុល្លារអាមេរិក (២០ ម៉ឺនរៀល) ពីម្តាយក្មេកនាង (ដោយគ្មានការប្រាក់) ។ នៅខែមីនា ឆ្នាំ ២០១៤ គ្រួសារនាងបានលក់ម៉ូតូបានប្រាក់ ១០០ ដុល្លារអាមេរិក (ពេលទិញតម្លៃ ២៥០ ដុល្លារអាមេរិក) ដើម្បីយកប្រាក់ទៅសងថ្លៃព្យាបាលជម្ងឺ ។ លើសពីនេះ គ្រួសារនាងជំពាក់ប្រាក់អ្នកឱ្យខ្ចីឯកជនចំនួន ៥០០ ដុល្លារអាមេរិក ពួកគេបានដាក់បញ្ចាំប័ណ្ណកម្មសិទ្ធិដីរស់នៅដើម្បីខ្ចីប្រាក់នេះ ។ អត្រាការប្រាក់ស្មើនឹង ៣ភាគរយក្នុងមួយខែសម្រាប់រយៈពេល ១៨ ខែ ។

*"ប្រាក់កម្ចីនេះ (ពីអ្នកឱ្យខ្ចីឯកជន គឺប្រសើរជាងប្រាក់កម្ចីពីអង្គការ (ស្ថាប័នមីក្រូហិរញ្ញវត្ថុ) ពីព្រោះប្រសិនបើខ្ញុំមិនសងប្រាក់ដើមរៀងរាល់ខែ ខ្ញុំអាចជ្រើសរើសបង់តែការប្រាក់បាន។ អ្នកឱ្យខ្ចី មានការយោគយល់ជាង ពីព្រោះប្រសិនបើខ្ញុំសងការប្រាក់យឺតចំនួន ៣-៤ ថ្ងៃ យើងអាចជូនដំណឹងទៅគេបាន។ ហើយប្រសិនបើយើងសងបំណុលទាំងអស់ យើងអាចយករបស់បញ្ចាំមកវិញក្នុងរយៈពេល ៣-៤ ថ្ងៃ។ ខ្ញុំធ្លាប់ខ្ចីប្រាក់ពីអម្រិត ចំនួន ២០ ម៉ឺនរៀល លក្ខណៈជាក្រុម។ ខ្ញុំធ្លាប់ទិញជីគីមីសម្រាប់ដាក់ស្រែខ្ញុំ។ យើងធានាគ្នាទៅវិញទៅមក ហើយយើងមិនចាំបាច់ដាក់របស់បញ្ចាំទេ។ ខ្ញុំបានសងប្រាក់នោះរួចរាល់អស់ហើយ។"*

កូនស្រីពៅរបស់ខ្ញុំ ធ្វើការនៅរោងចក្រសំលៀកបំពាក់នៅភ្នំពេញអស់រយៈពេល ៣- ៤ ឆ្នាំមក

ហើយ ។ កូនប្រសារប្រុសខ្ញុំក៏ធ្វើការជាកម្មករសំណង់នៅភ្នំពេញ ប៉ុន្តែគាត់ និងប្រពន្ធគាត់រស់នៅបែកគ្នាពីកូនស្រីខ្ញុំ ។ គាត់តែងតែទៅរកការងារបន្ទាប់ពីរដូវធ្វើស្រែរួច ។ ពេលខ្លះប្តីខ្ញុំក៏ធ្វើការសំណង់ដែរ ។ ប៉ុន្តែនាពេលថ្មីៗនេះ គាត់មានសុខភាពមិនសូវល្អ ហើយចាប់តាំងពីខ្ញុំឈឺ គាត់មិនអាចធ្វើការបាន ដោយសារគាត់ត្រូវមើលថែខ្ញុំ ។ យើងចំណាយប្រាក់អស់ជាច្រើនលើថ្លៃព្យាបាលជម្ងឺខ្ញុំ ។ យើងពឹងផ្អែកតែទៅលើប្រាក់បញ្ញើពីកូនស្រីខ្ញុំ និងទិន្នផលស្រូវ។ ខ្ញុំព្យាយាមចិញ្ចឹមជ្រូកដែរ ប៉ុន្តែវាមិនបានផលល្អសោះ ។ ដូចនេះក្តីសង្ឃឹមរបស់ខ្ញុំគឺសងបំណុលដែលយើងជំពាក់ បានពីប្រាក់បញ្ញើរពីកូនស្រីខ្ញុំ។

(បទសម្ភាសន៍ជាមួយស៊ីនួន នៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ នៅខេត្តព្រៃវែង)

**ប្រអប់ទី ៤៖ ចំណាកស្រុកទៅធ្វើការជាដំណោះស្រាយសងបំណុល**

លោកស្រីសុភីរស់នៅជាមួយប្តីរបស់គាត់ និងកូនស្រី ២ នាក់នៅភូមិបន្ទាយស្រែនៅក្នុងខេត្តព្រៃវែង ។ គាត់មានដីស្រែចំនួន ៣ ប្លង់ សរុបប្រហែលជា ២ ហិចតា ។ គាត់ដាំស្រូវ ២ ប្រភេទគឺ ស្រូវរំដួលសម្រាប់លក់ និងក្រសាំងទាបសម្រាប់ហូបក្នុងគ្រួសារ ។ គ្រួសាររបស់គាត់ធ្លាប់មានអង្ករហូបគ្រប់គ្រាន់ពេញមួយឆ្នាំ ដោយសារពួកគេមានដីស្រែធំ ។ លើកលែងតែករណី ៦ឆ្នាំមុនដែលគ្រួសាររបស់គាត់ត្រូវទិញអង្ករ ១០០ គីឡូសម្រាប់ហូបដោយសារតែខ្វះអង្ករ ។

លោកស្រីសុភីបាននិយាយថាគាត់ប្រើជីគីមីអស់ ៨ បាវនៅក្នុងស្រែទាំងអស់របស់គាត់ ។

ប្រភពចំបងនៃចំណូលគ្រួសាររបស់គាត់គឺបានមកពីការដាំដុះស្រូវ និងចិញ្ចឹមសត្វ ។ គាត់ប្រមូលផលបានស្រូវ ៤ តោននៅឆ្នាំ ២០១៣ នៅក្នុងរដូវធ្វើស្រែវស្សា ។ គាត់លក់ស្រូវប្រភេទរំដួលទាំងអស់ក្នុងតម្លៃ ៧ លានរៀល ។ គាត់លក់បាន ២ ដង ក្នុងតម្លៃ ១៣០០ រៀលក្នុងមួយគីឡូ និង ១៣១០ រៀលក្នុងមួយគីឡូ ទៅតាមពេលប្រមូលផល ។ បន្ទាប់ពីប្រមូលផល ប្តីរបស់គាត់តែងតែធ្វើចំណាកស្រុកមកភ្នំពេញ កំពង់ចាម ឬប្រទេសថៃដើម្បីធ្វើការរកចំណូលបន្ថែម ។

លោកស្រីសុភី ខ្ចីប្រាក់ ៥០ ម៉ឺនរៀលពីអម្រិតនៅខែកក្កដា ឆ្នាំ ២០១៣ ដើម្បីសងថ្លៃព្យាបាលមើលជម្ងឺគ្រុនចាញ់របស់កូនគាត់ ។ ថ្លៃព្យាបាលជម្ងឺជាសរុបគឺ ២១៥,០០០ រៀល ហើយគាត់អាចបង់បានតែ ២០០,០០០ រៀលប៉ុណ្ណោះ គាត់នៅជំពាក់គ្រូពេទ្យចំនួន ១៥,០០០ រៀលទៀត ។ ក្រៅពីបង់ថ្លៃព្យាបាលជម្ងឺ ប្រាក់កម្ចីដែលនៅសល់ ត្រូវយកទៅទិញជីគីមី និងចំណាយថ្លៃអាហារប្រចាំថ្ងៃ ។ គ្រួសាររបស់គាត់ត្រូវតែសងបំណុលទៅឱ្យអម្រិតឱ្យអស់នៅខែកក្កដា ឆ្នាំ២០១៤ ពួកគេមិនអាចសងប្រាក់ដើមនៅឡើយទេ បានតែសងការប្រាក់ប្រចាំខែប៉ុណ្ណោះ ។

លើសពីបំណុលដែលមានស្រាប់ គ្រួសាររបស់គាត់មានជំពាក់ប្រាក់កម្ចីចំនួន ២ ថែមទៀត ។ លើកទី ១ គាត់ខ្ចីប្រាក់ចំនួន ៣លានរៀលពីអ្នកឱ្យខ្ចីឯកជននៅស្វាយអន្ទរដើម្បីសងបំណុលប្អូនស្រីគាត់ ។ ប៉ុន្តែចំនួនប្រាក់នេះ អ្នកឱ្យខ្ចីមិនត្រូវការការដាក់បញ្ចាំទេដោយសារគេស្គាល់ក្រុមគ្រួសារគាត់ច្បាស់ ។ បំណុលនេះមានអត្រាការប្រាក់ចំនួន ៣ភាគរយ ។ គាត់បានសងបំណុលនោះរួចអស់ហើយ ដោយសារគ្រួសាររបស់គាត់បានលក់ក្របីចំនួន ៣ ស្មើនឹងប្រាក់ ៨,៩០០,០០០ រៀល ។ ប្រាក់ដែលនៅសល់ពីសងបំណុល គាត់សន្សំទុក ។

ថ្មីៗនេះ លោកស្រីសុភីបានខ្ចីបំណុលចំនួន ១ លានរៀល ដើម្បីរៀបចំខ្លួនចេញទៅរកការងារនៅប្រទេសថៃ ។ គាត់និយាយថាប្តីរបស់គាត់ និងគាត់បានសម្រេចចិត្តទៅធ្វើការជាកម្មករសំណង់នៅប្រទេសថៃ ។ ពួកគាត់មានសាច់ញាតិបងប្អូនកំពុងធ្វើការនៅថៃ ហើយនឹងជួយសម្រួលការធ្វើដំណើរទៅទីនោះ ។ ប្តីប្រពន្ធនេះនឹងបង់ប្រាក់ ២,០០០ បាតសម្រាប់មនុស្សម្នាក់ឱ្យទៅមេខ្យល់ដើម្បីជួយយកពួកគាត់ឱ្យបានទៅប្រទេសថៃ ។ ហើយពួកគាត់នឹងបង់ ២០,០០០បាតទៀតសម្រាប់លិខិតអនុញ្ញាតការងារ ។ គាត់ត្រូវសងបំណុលនេះនៅពេលពួកគាត់ចាប់ផ្តើមធ្វើការ ។ តាមដែលគាត់ដឹង គាត់អាចរកបានប្រាក់ចំនួន ២៥០ បាត ហើយប្តីរបស់គាត់អាចរកប្រាក់បាន ៣០០ បាតក្នុងមួយថ្ងៃ ។

> *"នៅពេលខ្ញុំទៅធ្វើការនៅប្រទេសថៃ ខ្ញុំនឹងទុកដីស្រែរបស់ខ្ញុំឱ្យប្អូនស្រីខ្ញុំមើល ។ ដីស្រែទំហំ កន្លះហិចតា នាងនឹងធ្វើស្រែ និងប្រមូលផលដោយខ្លួនឯង ។ ដីស្រែ២ផ្សេងទៀតនាងនឹងធ្វើស្រែសម្រាប់គ្រួសារខ្ញុំ ហើយខ្ញុំនឹងបង់ថ្លៃចំណាយ និងកម្រៃពលកម្មទាំងអស់ ។ នៅពេលប្រមូលផល យើងនឹងលក់ស្រូវដើម្បីសងចំណាយទាំងនោះ ។"*

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០១៤ កូនរបស់គាត់មានជម្ងឺក្តៅខ្លួន ។ ប៉ុន្តែគាត់មិនបានបញ្ជូនពួកគេទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យទេ គឺគ្រាន់តែទិញថ្នាំពីហាងលក់ថ្នាំក្នុងភូមិ និងហៅគ្រូពេទ្យមកព្យាបាលនៅផ្ទះ ។ កូនស្រីច្បងរបស់គាត់នៅតែមិនស្រួលខ្លួននៅឡើយ ហើយសប្តាហ៍ក្រោយ ប្តីរបស់គាត់ និងគាត់នឹងចាកចេញទៅប្រទេសថៃ ទុកឱ្យកូនស្រីទាំងពីរនៅផ្ទះ ។ កូនស្រីច្បងរបស់គាត់ដែលបានឈប់រៀនថ្នាក់អនុវិទ្យាល័យ នឹងនៅផ្ទះ និងចិញ្ចឹមក្របី ហើយកូនស្រីពៅនៅរៀននៅឡើយ ។

(បទសម្ភាសន៍ធ្វើនៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១៤ នៅខេត្តព្រៃវែង)

**ប្រអប់ទី ៥៖ ស្ថាប័នមីក្រូហិរញ្ញវត្ថុចាត់ការតាមផ្លូវច្បាប់ចំពោះករណីមិនសងប្រាក់**

នៅក្នុងសហគមន៍នេសាទតាមដងទន្លេសាបធ្លាប់មានរឿងក្តីនៅតុលាការ ប្តឹងដោយប្រាសាក់ ដោយសារការមិនសងបំណុល ។

*"នៅឆ្នាំ២០១២ ប្រាសាក់បានដកប្រតិបត្តិការរបស់ខ្លួនពីសហគមន៍នេសាទនៅឃុំរបស់ខ្ញុំ ។ មានគ្រួសារចំនួន១២គ្រួសារដែលខ្ចីប្រាក់ពីប្រាសាក់ ។ នៅពេលបុគ្គលិកមកប្រមូលប្រាក់ដើម និងការប្រាក់ គ្រួសារខ្លះអាចសងបាន ហើយគ្រួសារខ្លះមិនអាចសងបាន ។ នៅពេលមួយ គ្រួសារចំនួន១២គ្រួសារ មានបំណងចង់ធ្វើកូដកម្មស្នើសុំឱ្យប្រាសាក់កុំដាក់សម្ពាធសងប្រាក់ ហើយពួកគេគម្រាមកំហែងមិនសងបំណុល ។ ពួកគេបានកោះហៅជូនដំណឹងដល់ខ្ញុំ និងស្នើឱ្យខ្ញុំបញ្ឈប់ការធ្វើកូដកម្មនោះ ។ ប៉ុន្តែខ្ញុំមានការបារម្ភ ដូចនេះ ខ្ញុំបានប្រាប់គ្រួសារទាំង១២ កុំទាន់អាលបន្ទាន់ និងទុកកិច្ចការនេះឱ្យអាជ្ញាធរជាអ្នកដោះស្រាយ ។*

*ខ្ញុំបានស្នើទៅបុគ្គលិកប្រាសាក់ឱ្យអញ្ជើញមក និងសួរពួកគេអំពីស្ថានការ ។ ខ្ញុំបានសួរពួកគេថាតើអាចពន្យាពេលបង់ការប្រាក់បានទេ ។ ខ្ញុំបានប្រាប់ទៅពួកគេធ្វើការចរចារដោយគ្មានការប្រឈមមុខដាក់គ្នា និងអហឹង្សា ហើយបុគ្គលិកប្រាសាក់បានអនុវត្តតាមការទូន្មានរបស់ខ្ញុំ តាមវិធីរបស់ពួកគេផ្ទាល់ដើម្បីដោះស្រាយបញ្ហានេះ ។ ប៉ុន្តែមិនបានជោគជ័យទេ។ គ្រួសារទាំង ១២ នៅតែប្រកែកមិនព្រមសង ។*

*បន្ទាប់មក បុគ្គលិកប្រាសាក់បានមកពិគ្រោះជាមួយខ្ញុំពីសកម្មភាពដែលអាចធ្វើទៅបាន ។ ខ្ញុំបានផ្តល់ប្រឹក្សាពួកគេឱ្យប្តឹងទៅតុលាការដោយសារធ្លាប់មានករណីដូចគ្នានេះកើតឡើងរួចមកហើយ ។ ខ្ញុំដឹងថា នៅពេលតុលាការសម្រេចលើបញ្ហានេះ វានឹងលំអៀងទៅរកគ្រួសារពាក់ព័ន្ធ ដោយសារតុលាការនឹងសម្រេចសេចក្តីឱ្យសងបំណុលដោយពឹងលើសមត្ថភាពរបស់គ្រួសារក្នុងការរកប្រាក់ចំណូល និងកាលវិភាគសងប្រាក់ក្នុងបរិមាណតិចជាង ។ ប្រាសាក់បានដាក់ពាក្យបណ្តឹងទៅតុលាការប្តឹងគ្រួសារទាំង៦នៅឆ្នាំ២០១៣ ។ ក៏ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន តុលាការមិនទាន់ដំណើរការកាត់ក្តីនៅឡើយទេ ។*

*"តាមការពិត គ្រួសារទាំងនោះដែលជំពាក់ប្រាក់ប្រាសាក់មានការបារម្ភខ្លាំងចំពោះស្ថានភាពរបស់ខ្លួន ។ ខ្ញុំចាំបានថានៅឆ្នាំ ២០១៣ មានម្តងនោះប្រាសាក់បានទៅរកសហគមន៍ ។ គ្រួសារទាំង៦ដែលមិនទាន់សងប្រាក់មានការភិតភ័យ និងបានរត់ពួន ។ ពួកគេខ្លាចថាពួកគេនឹងត្រូវចាប់ខ្លួន ។ តាមគំនិតខ្ញុំ គ្រួសារខ្លះអាចសងបំណុលនេះបាន ប៉ុន្តែពួកគេមិន*

*ចង់សងទេ" ។*

ប្រាសាក់ និងអម្រិតបានដកប្រតិបត្តិការរបស់ខ្លួនពីសហគមន៍នេសាទ ដោយសារពួកគេបានជួបផលលំបាកក្នុងការប្រមូលប្រាក់ដើម និងការប្រាក់មកវិញ ។ ជាធម្មតា ស្ថាប័នមីក្រូហិរញ្ញវត្ថុមានការលំបាកក្នុងការធ្វើប្រតិបត្តិការឱ្យខ្ចីប្រាក់ជាមួយនឹងសហគមន៍នេសាទ ដោយសារតែមានហានិភ័យខ្ពស់ក្នុងការសងប្រាក់មកវិញ ។

នៅក្នុងគ្រួសារមួយ ពួកគេជំពាក់ប្រាក់ប្រាសាក់ចន្លោះពី ១ ទៅ ២ លានរៀល ពួកគេក៏ខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុផ្សេងទៀតដែរ ។ អ្នកនេសាទទាំងនេះមិនមានផ្ទះ ឬដីភូមិទេ គឺពួកគេរស់នៅលើទូកនេសាទ ។ នៅពេលពួកចង់ខ្ចីប្រាក់ មានទម្រង់បែបបទប្រកាសពីទ្រព្យសម្បត្តិរបស់ពួកគេ (ផ្ទះបណ្តែតទឹក ទូក ម៉ាស៊ីន និងឧបករណ៍នេសាទផ្សេងទៀត) ហើយពួកគេត្រូវការមេឃុំឱ្យបញ្ជាក់នៅលើទម្រង់បែបបទនោះអំពីទ្រព្យរបស់ពួកគេ ។

*"ក្នុងនាមជាអាជ្ញាធរមូលដ្ឋាន ខ្ញុំមានការបារម្ភនៅពេលប្រជាជននៅក្នុងឃុំខ្ញុំជាប់ជំពាក់បំណុល ។ ប្រសិនបើពួកគេដឹងពីរបៀបរៀបចំផែនការគ្រួសារ និងប្រើប្រាស់ប្រាក់កម្ចីដើម្បីរកស៊ីឱ្យបានល្អ គ្រួសារពួកគេនឹងមិនជាប់ជំពាក់នៅក្នុងបំណុលនោះទេ ។ ជារឿយៗ ខ្ញុំផ្តល់ប្រឹក្សាដល់គ្រួសារដែលជាប់បំណុលរួចហើយ និងដាក់យកប្រាក់កម្ចីផ្សេងពីស្ថាប័នមីក្រូហិរញ្ញវត្ថុថ្មី ហើយជាថ្មីម្តងទៀតខ្ចីបំណុលមួយផ្សេងទៀត ។ ដោយឡែក ខ្ញុំឈឺក្បាលពីភាពលំបាកនៅពេលដែលពួកគេត្រូវសងប្រាក់ដើម និងការប្រាក់ទៅឱ្យបំណុលដែលពួកគេជំពាក់ទាំងអស់ ។*

*"ក្រុមគ្រួសារទាំងនោះដែលប្រើប្រាស់ប្រាក់កម្ចីក្នុងគោលបំណងផ្សេងៗ មានភាគតិចណាស់ដែលប្រើប្រាក់កម្ចីបានល្អបើប្រៀបពីពេលមុនដែលពួកគេខ្ចីបុល ។ ប្រហែលជាអ្នកខ្ចីចំនួន៥ភាគរយ បានធ្វើឱ្យជីវភាពរបស់ពួកគាត់ប្រសើរឡើង ។ គ្រួសារជាច្រើនខ្ចីបុលជាច្រើន និង លុងកាន់តែជ្រៅដោយសារពួកគេយកបំណុលពីស្ថាប័នមីក្រូហិរញ្ញវត្ថុមួយទៅសងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយទៀត ។"*

(បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ធ្វើនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៤ នៅខេត្តកំពង់ឆ្នាំង)

## ផ្នែកទី ៤៖ ការពិភាក្សា និងសេចក្តីបញ្ចប់

ការសិក្សាស្រាវជ្រាវនេះដកស្រង់ទស្សនៈនានាបានមកពីកសិករខ្នាតតូចនៅក្នុងភូមិចំនួន៦ ក្នុងខេត្តកំពង់ឆ្នាំង និងព្រៃវែង ។ ដោយមានដីស្រែទំហំតូចសម្រាប់ជាមធ្យោបាយចិញ្ចឹមជីវិត កសិករមើលឃើញថា ការចំណាយទៅលើការធ្វើកសិកម្មកាន់តែកើនឡើងច្រើនឡើង ប៉ុន្តែផ្ទុយមកវិញទិន្នផលស្រូវមិនអាចទប់ទល់ទៅនឹងការចំណាយបាននោះទេ ។ របកគំហើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ បង្ហាញថាទាំងតម្លៃនិងបរិមាណជីគីមីដែលប្រើនៅក្នុងស្រែមានការកើនឡើង ។ លើសពីនេះ ចំណាយផ្សេងៗទៀតដូចជាកម្លាំងពលកម្ម និងម៉ាស៊ីនដែលត្រូវការសម្រាប់ធ្វើស្រែមានតម្លៃកាន់តែថ្លៃ ។ អតុល្យភាពរវាងថ្លៃចំណាយធ្វើស្រែ និង ទិន្នផលដែលទទួលបាន ធ្វើអោយកសិករប្រឈមទៅនឹងការខាតបង់នៅគ្រាចុងក្រោយ ដោយសារតែការចំណាយពេលវេលាច្រើន កម្លាំងពលកម្ម និងប្រាក់បណ្តាក់ទុននៅក្នុងការធ្វើកសិកម្ម និង ហានិភ័យកើតមានឡើងប្រសិនបើលក្ខខណ្ឌអាកាសធាតុមិនអំណោយផល (ភ្លៀងធ្លាក់គ្រប់គ្រាន់ ទឹកជំនន់) និងប្រភពទឹកមិនបង្កផលល្អដល់ពួកគាត់ ។

ខណៈពេលដែលរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយជាក់លាក់ លើកកម្ពស់ការនាំចេញស្រូវ និងអង្ករ ឃើញថាគ្មានគោលនយោបាយណាធានាពីតម្លៃស្រូវអប្បបរមា ឬការគ្រប់គ្រងតម្លៃសម្ភារៈធ្វើកសិកម្ម ដូចជាជីគីមីជាដើម ។ នេះជាក្តីបារម្ភដ៏ធំរបស់កសិក ជាពិសេសកសិករនៅជនបទ និងបណ្តាញកសិករ ការសិក្សាស្រាវជ្រាវនេះបង្ហាញថា ប្រសិនបើគ្មានយន្តការច្បាស់លាស់ពីរដ្ឋាភិបាលក្នុងការគ្រប់គ្រងតម្លៃ (តម្លៃជីដាក់ស្រែ ឬជីគីមី) ហើយបើនៅតែទុកឱ្យទីផ្សារជាអ្នកកំណត់តម្លៃដូចទៅនឹងការអនុវត្តនាពេលបច្ចុប្បន្ន នោះកសិករ ជាពិសេសប្រជាជនដែលមានដីស្រែតិចតួចនឹងបាត់បង់ការចិញ្ចឹមជីវិត ដោយសារពួកគាត់គ្មានលទ្ធភាពទិញសម្ភារៈធ្វើកសិកម្មខណៈពេលដែលទទួលបានទិន្នផលស្រូវទាប ហើយគ្មានការឧបត្ថម្ភធនពីរដ្ឋាភិបាលដល់កសិករខ្នាតតូច ។

នៅថ្នាក់ជាតិវិញ កម្ពុជាបានទទួលស្គាល់ថាមានការកើនឡើងយ៉ាងខ្លាំងនូវការផ្ទេរដីកសិកម្ម ទៅជាដីសម្រាប់ដំណាំចំការសម្រាប់លក់ ដើម្បីធ្វើជាកសិ-ពាណិជ្ជកម្ម ។ មកដល់ឆ្នាំ ២០០៣ រដ្ឋាភិបាលខ្មែរបានឯកភាពលើដីសម្បទានចំនួនជាង ២ លានហិចតា (ADHOC ឆ្នាំ ២០១៣) ហើយដីខ្លះមានកិច្ចសន្យារហូតដល់ ៩០ ឆ្នាំ ។ ដីសម្បទានគឺសម្រាប់ដំណាំចំការសម្រាប់លក់សំខាន់ៗ ដូចជាដំឡូងមី កៅស៊ូ ដូងប្រេង អំពៅ ពោត សម្រាប់នាំចេញ ឬសម្បទានដើម្បីកាប់ឈើ ។ ការបោះជំហ៊ានដ៏ខ្លាំងក្លារបស់រដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច បានបណ្តាលឱ្យមានជម្លោះដីធ្លីជាច្រើនកើតឡើងនៅតំបន់ជនបទ និងតំបន់កំពុងអភិវឌ្ឍ ដែលនេះបណ្តាលឱ្យកសិករបាត់បង់ដី និងមិនអាចប្រើប្រាស់ធនធានរួម បង្កើនការចំណាកស្រុក និងការនាំចេញពលករទៅ

បម្រើការងារតាមផ្ទះ និងសំណង់នៅក្រៅប្រទេស ។ រដ្ឋាភិបាលកម្ពុជាបានដាក់សំណើរសេចក្តីព្រាងច្បាប់ ស្តីពី "ការប្រើប្រាស់ និងការគ្រប់គ្រងដី" ដែលជាមូលដ្ឋាន អនុញ្ញាតឱ្យក្រុមហ៊ុនមានសិទ្ធិអំណាច និងការគ្រប់គ្រងទៅលើផលិតផលរបស់កសិករតាមរយៈកិច្ចសន្យាកសិកម្ម ។ ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត និងអនុវត្តនោះ ធ្វើឱ្យកសិករជាច្រើនអាចនឹងបាត់បង់សិទ្ធិកាន់កាប់លើដីស្រែតិចតួចរបស់ពួកគាត់ ហើយពួកគាត់និងក្លាយខ្លួនជាពលករ ហើយជាលទ្ធផលការធ្វើស្រែចំការត្រូវចំណាយកាន់តែច្រើនឡើងៗ ។

ការលើកកម្ពស់គោលនយោបាយនាំចេញស្រូវ និងអង្ករ របស់រដ្ឋាភិបាលលើ គឺជាជំហ៊ានមួយសម្រាប់លើកកំពស់សេរីភាវូបនីយកម្មកសិកម្មទៅកាន់ទីផ្សារពិភពលោក ។ មកដល់ខែធ្នូ ឆ្នាំ ២០១៣ កម្ពុជាបាននាំចេញអង្ករចំនួន ៣៧៨៨៥៦ តោន បើប្រៀបទៅនឹងចំនួន ១០៥២៥៩ តោន ក្នុងឆ្នាំ ២០១០ (សមាគមនាំចេញអង្ករកម្ពុជា ឆ្នាំ ២០១៤) ។ បញ្ហានេះបានធ្វើអោយគោលដៅនាំចេញអង្ករឱ្យបាន ១ លានតោននៅឆ្នាំ ២០១៥ មិនអាចធ្វើទៅបាន ហើយការខំប្រឹងប្រែងបន្ថែមក្នុងការអភិវឌ្ឍវិស័យកសិកម្មត្រូវការជាចាំបាច់ ។ ដោយសារតែមានប្រជាជនប្រហែល៨០ភាគរយពឹងផ្អែកលើការធ្វើស្រែសម្រាប់ទ្រទ្រង់គ្រួសារ ដូចនេះការជម្រុញការនាំចេញអង្ករត្រូវតែគិតគូរអោយបានខ្លាំង និងត្រូវធ្វើអោយមានតុល្យភាពជាមួយនឹងអធិបតេយ្យភាពស្បៀងរបស់ប្រទេស ។ បច្ចុប្បន្ន កសិករខ្នាតតូចរបស់កម្ពុជាមានដីស្រែតិចតួច នេះមានន័យថាសមត្ថភាពរបស់ពួកគាត់ក្នុងការផលិតអង្ករសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

នៅខណៈពេលដែលរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់ការនាំចេញអង្ករយ៉ាងខ្លាំងក្លានោះ ការគាំទ្រលើកទឹកចិត្តដែលមានកំណត់នៅក្នុងគោលនយោបាយ ហាក់ដូចជាឆ្ងាយពីការពិតខ្លាំងណាស់សម្រាប់កសិករខ្នាតតូច ។ នៅពេលដែលកសិករចាប់ផ្តើមផ្លាស់ប្តូរពីគ្រាប់ពូជបុរាណ/ក្នុងស្រុក មកប្រើគ្រាប់ពូជដែលជាតម្រូវរបស់ទីផ្សារអន្តរជាតិ វាធ្វើអោយពួកគាត់ប្រឈមនឹងហានិភ័យផ្សេងទៀត ។ កម្ពុជាមិនផ្តល់នូវការធានានូវតម្លៃអង្ករជាអប្បបរមាដល់អ្នកផលិតស្រូវនោះទេ ។ ដោយផ្អែកលើបទពិសោធន៍របស់កសិករនៅក្នុងការសិក្សាស្រាវជ្រាវនេះ តម្លៃស្រូវមានការធ្លាក់ចុះតិចតួចនៅរដូវកាលប្រមូលផល និងកើនឡើងក្នុងអំឡុងពេលខ្វះអង្ករ (ដូចជាមុនពេលប្រមូលផល) ។ ប្រសិនបើគ្មានការធានាតម្លៃស្រូវទេ កសិករតូចតាចនិងខាតបង់ដោយសារពួកគាត់មិនមានអំណាចក្នុងការតថ្លៃ ហើយគាត់កំពុងស្ថិតនៅក្នុងអន្ទាក់ដែលតម្រូវអោយពួកគាត់ធ្វើការសងនូវតម្លៃសម្ភារៈធ្វើកសិកម្មទាំងអស់ដែលពួកគាត់បានជំពាក់គេ ។

ការកើនឡើងតម្លៃសម្ភារៈធ្វើកសិកម្មសម្រាប់ធ្វើស្រែធ្វើអោយកសិករត្រូវការប្រាក់ជាច្រើននៅក្នុងដៃ ។ របកគំហើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ បង្ហាញថាគ្រួសារនីមួយៗជាទូទៅពឹង

ផ្អែកលើប្រភពប្រាក់ចំនួន ៣ ប្រភេទសម្រាប់ការធ្វើស្រែះ ការផ្ញើប្រាក់ពីពលករចំណាកស្រុកនៅក្នុង និងក្រៅកម្ពុជា ប្រាក់កម្ចី និងការទិញសម្ភារៈធ្វើកសិកម្មដោយជំពាក់។ ជម្រើសទាំង ៣ នេះត្រូវបានប្រើដោយកសិករជាយន្តការដោះស្រាយមួយផ្នែក ឬនៅគ្រាណាមួយនៅក្នុងរដូវធ្វើស្រែ ។ ក៏ប៉ុន្តែ ដោយបានរកឃើញនៅក្នុងការសិក្សានេះ គ្រួសារដែលបានចូលរួមធ្វើសម្ភាសន៍ចំនួន ៧៦ ភាគរយ កំពុងជំពាក់បំណុល ហើយ៥៦ភាគរយទៀតធ្លាប់ជំពាក់បំណុល ដោយសារការព្យាបាលជម្ងឺ ។ នេះជារូបភាពដែលបង្ហាញពីតួនាទីដ៏សំខាន់របស់ប្រាក់សម្រាប់សេដ្ឋកិច្ចនៅជនបទ ។ ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន ប្រាក់/កម្ចីគឺអាចខ្ចីបានក្នុងអត្រាការប្រាក់មួយខ្ពស់ជាង ២៤ភាគរយ-៣៦ភាគរយ ក្នុងមួយឆ្នាំ សម្រាប់ស្ថាប័នផ្តល់កម្ចីក្នុងប្រពន្ធ័ ឬ ៣៦ភាគរយ-៦០ភាគរយ ក្នុងមួយឆ្នាំសម្រាប់អ្នកឱ្យខ្ចីក្រៅប្រពន្ធ័ ។ អត្រាការប្រាក់នេះគឺខ្ពស់ណាស់ដែលវាពិបាកសម្រាប់អ្នកខ្ចីក្នុងការដែលអាចរកប្រាក់ចំណូលអោយបានច្រើនគ្រប់គ្រាន់សម្រាប់សងការប្រាក់ និងរកប្រាក់ចំណេញនៅជនបទ ។

នៅក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៩ របស់កម្ពុជា បានចែងថាអត្រាការប្រាក់មិនត្រូវលើសពី ៥ភាគរយក្នុងមួយឆ្នាំទេ លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគីទាំងពីរ ។ ក្រៅពីក្រមរដ្ឋប្បវេណីនេះ គ្មានលិខិតបទដ្ឋានគតិយុត្តិជាក់លាក់ណាមួយដែលគ្រប់គ្រងអត្រាការប្រាក់ខ្ពស់បំផុតដែលស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវប្រើប្រាស់នៅកម្ពុជានោះទេ ។ មានការអះអាងថា ការប្រកួតប្រជែងទីផ្សារសេរីរវាងស្ថាប័នមីក្រូហិរញ្ញវត្ថុនឹងធ្វើអោយអត្រាការប្រាក់ធ្លាក់ចុះ ។ គួរឱ្យកត់សម្គាល់ អត្រាការប្រាក់មានការធ្លាក់ចុះតិចតួចនៅកម្ពុជា ដោយសារចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុមានការកើនឡើងដូចផ្សិត ប៉ុន្តែអត្រាការប្រាក់នៅតែខ្ពស់ក្នុងចំនួន ២៤ភាគរយ- ៣៦ភាគរយក្នុងមួយឆ្នាំ ។ គួរឱ្យចាប់អារម្មណ៍ អ្វីដែលមិនត្រូវបានគេយកមកពិភាក្សា គឺការទទួលខុសត្រូវដែលត្រូវចែករំលែករវាងអ្នកផ្តល់កម្ចីនៅក្នុងទំនាក់ទំនងខ្ចី-ផ្តល់កម្ចី ។ តាមការពិត គ្រប់ស្ថាប័នមីក្រូហិរញ្ញវត្ថុ មានភ្នាក់ងារវាយតម្លៃពីផែនការអាជីវកម្ម/លទ្ធភាពក្នុងការប្រើប្រាស់ប្រាក់កម្ចីមុនពេលផ្តល់ប្រាក់កម្ចីតាមសំណើទៅឱ្យអ្នកខ្ចី ។ ដូចនេះ នៅពេលប្រាក់កម្ចីមានបញ្ហា នៅក្នុងការអនុវត្តបច្ចុប្បន្ន អ្នកខ្ចីត្រូវមានទំនួលខុសត្រូវសងទាំងប្រាក់ដើម និងការប្រាក់ ។ ការពិត ការទទួលខុសត្រូវក្នុងការសងពាក់កណ្តាលទៀត គួរតែធ្វើឡើងដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ/អ្នកឱ្យខ្ចី ហើយនិងគ្រួសារ/អ្នកខ្ចីក្រីក្រមិនគួរទទួលខុសត្រូវទាំងស្រុងលើប្រាក់កម្ចីដែលមានអត្រាការប្រាក់ខ្ពស់តែម្នាក់ឯងនោះទេ ។

ផ្ទុយមកវិញ អ្វីដែលបានឃើញនាពេលបច្ចុប្បន្ននៅថ្នាក់ឃុំគឺចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនកំពុងប្រកួតប្រជែងគ្នាផ្តល់ប្រាក់កម្ចីដល់គ្រួសារនានាក្នុងអត្រាដូចគ្នា ។ តាមការរកឃើញនៅក្នុងការវាយតម្លៃពីទឹកជំនន់នៅក្រោយឆ្នាំ ២០១១ (CARE ឆ្នាំ២០១២) ចំនួនប្រាក់កម្ចីថ្មីត្រូវយកទៅសងប្រាក់កម្ចីដែលមានស្រាប់ ។ នេះជាការសងប្រាក់វិលជុំដែលរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ ក្នុងករណីដែលគ្រួសារយកប្រាក់កម្ចីពីឯកជនទៅសងស្ថាប័នមីក្រូហិរញ្ញវត្ថុនៅគ្រាបញ្ចប់

ប្រាក់កម្ចី ហើយធ្វើយ៉ាងនេះដដែលម្តងទៀត ។ វដ្តនេះបង្កើតជាលក្ខខណ្ឌដែលធ្វើឱ្យគ្រួសារមិនអាចដកខ្លួនរួចពីបំណុល ជាពិសេសនៅពេលដែលប្រាក់កម្ចីបានយកទៅប្រើសម្រាប់ព្យាបាលជម្ងឺ នេះបើយោងតាមការរាយការណ៍របស់អ្នកចូលរួមធ្វើសម្ភាសន៍ចំនួនជិត៥០ភាគរយនៅក្នុងការសិក្សាស្រាវជ្រាវនេះ។

ចំណាកស្រុករកការងារទំនងជាយន្តការពេញនិយមមួយ និងជាដំណោះស្រាយយ៉ាងសំខាន់នៅក្នុងគ្រួសារនៅជនបទ ។ ប្រាក់ផ្ញើរបានពីពលករដែលធ្វើការនៅក្នុងរោងចក្រ សំណង់ ចំការ ក្នុងនិងក្រៅប្រទេសកម្ពុជា ដើរតួយ៉ាងសំខាន់នៅក្នុងការធ្វើឱ្យសេដ្ឋកិច្ចជនបទរស់រវើក ។ ប្រាក់ផ្ញើ នេះត្រូវបានយកទៅប្រើគ្រប់មុខសម្រាប់ទិញសម្ភារៈធ្វើកសិកម្មនៅក្នុងផលិតកម្មស្រូវ ទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ សងបំណុល ព្យាបាលជម្ងឺ ការអប់រំ និងការប្រើប្រាស់ផ្សេងទៀតសម្រាប់មុខងារគ្រួសារ ។ ទោតាមបញ្ហាដែលបានលើកឡើង មានសញ្ញានៃការបារម្ភយ៉ាងសម្បើមក្នុងបរិបទផ្សេងៗគ្នាដូចជា៖ ក. ការកើនឡើងប្រាក់ឈ្នួលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កម្មករនៅឡើយ ខ. ចំនួនពលករស្របច្បាប់ និងមិនស្របច្បាប់ជាច្រើនបានវិលត្រឡប់មកពីប្រទេសថៃវិញ ដោយសារអស្ថេរភាពនយោបាយនៅក្នុងប្រទេស គ. ពលករចំការកសិកម្មធ្វើការក្រោមលក្ខខណ្ឌដែលមានកិច្ចការពារសិទ្ធិការងារនៅមានកម្រិត ឬគ្មានសោះសម្រាប់ពលករ ។

លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញពីភាគរយខ្ពស់នៃបំណុលដែលគ្រួសារធ្លាប់ឆ្លងកាត់ ។ ច្រើនជាងពាក់កណ្តាលនៃគ្រួសារដែលបានផ្តល់បទសម្ភាសន៍ ជាប់បំណុលដោយសារពួកគាត់ខ្ចីយកមកសងថ្លៃព្យាបាលជម្ងឺ ។ បំណុលដែលខ្ចីមកសម្រាប់ថ្លៃព្យាបាលជម្ងឺ គឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរដោយសារវាជាកត្តាសំខាន់ដែលជំរុញអោយឱ្យគ្រួសារក្រីក្រជាប់នៅក្នុងអន្ទាក់នៃវដ្តនៃភាពក្រីក្រ ។ គ្រួសារភាគច្រើន បានរាយការណ៍ថាពួកគាត់ប្រើប្រាស់សេវាពេទ្យឯកជនដោយសារតែមណ្ឌលសុខភាពសាធារណៈបម្រើសេវាកម្ម និងគុណភាពមិនទាន់ល្អនៅឡើយ ។ ចំពោះគ្រួសារនៅក្នុងការសិក្សាស្រាវជ្រាវនេះ វាទំនងថាគ្មានភាពខុសប្លែកគ្នារវាងពួកគេដែលប្រើប្រាស់សេវាសុខភាពសាធារណៈ ឬឯកជននោះទេ ដោយសារពួកគាត់ត្រូវបង់ប្រាក់ ទោះបីជាសេវាណាមួយក៏ដោយ ។ ប៉ុន្តែ សេវាពេទ្យឯកជន គឺរហ័ស និងទាន់ពេល ប៉ុន្តែមានតម្លៃថ្លៃជាង។

ការរីកដូចផ្សិតនៃស្ថាប័នមីក្រូហិរញ្ញវត្ថុនៅទូទាំងប្រទេសកម្ពុជា មានន័យថាប្រជាជននៅតាមជនបទអាចមានលទ្ធភាពទទួលបានឥណទាន និងប្រាក់កម្ចីបានទូលាយ ។ ក៏ប៉ុន្តែ ការរកឃើញបង្ហាញថា អត្រាការប្រាក់នៅតែខ្ពស់ ក្នុងកម្រិត ២៤ភាគរយ-៣៦ភាគរយក្នុងមួយឆ្នាំ ។ ដោយអត្រាការប្រាក់ខ្ពស់ ចំនួនគ្រួសារដែលយកប្រាក់កម្ចីទៅប្រើសម្រាប់សេវាសុខភាព ត្រូវជាប់នៅក្នុងបំណុលយ៉ាងជ្រៅ និងនៅក្នុងវដ្តនៃភាពក្រីក្រ ដែលពួកគេត្រូវខ្ចីប្រាក់កម្ចីពីស្ថាប័នមីក្រូ

ហិរញ្ញវត្ថុមួយទៅសងស្ថាប័នមួយទៀត ហើយធ្វើដដែលៗដើម្បីសងបំណុល ។ នៅពេលនេះ រដ្ឋាភិបាលកម្ពុជាគួរតែពិចារណាចាត់វិធានការ និងធ្វើបញ្ញាត្តិដើម្បីធានាអោយមានកិច្ចការការពារគ្រប់គ្រាន់ដល់កសិករខ្នាតតូចទាំងទៅលើផ្នែកផលិតកម្មស្រូវរបស់ពួកគេ និងការទទួលបានឥណទានជាមួយនឹងអត្រាការប្រាក់ទាបទៅតាមលទ្ធភាពដែលអាចបង់បាន ។

# ឯកសារយោង

ធនាគារអភិវឌ្ឍន៍អាស៊ី។ (២០១៤) ទស្សនៈវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០១៤)

Akashi, H., et al (២០០៦)" ថ្លៃសេវាកម្មអ្នកប្រើប្រាស់នៅមន្ទីរពេទ្យរដ្ឋក្នុងប្រទេសកម្ពុជា :ការជះឥទ្ធិពលរបស់មន្ទីរពេទ្យចំពោះការបំពេញសេវាកម្ម និងអាកប្បកិរិយារបស់អ្នកផ្តល់សេវាកម្ម..." វិទ្យាសាស្រ្តសង្គមនិងវេជ្ជសាស្រ្ត ៥៨៖ ៥៥៣-៥៦៤ ។

Annear, p., et al. (2000)។ ការសិក្សាអំពីលទ្ធភាពហិរញ្ញវត្ថុក្នុងការទទួលបានសេវាកម្មសុខភាពចំពោះអ្នកក្រីក្រក្នុងប្រទេសកម្ពុជា។ ជំហានទី ១ វិសាលភាព ការធ្វើផែនការ និងការវិភាគទិន្នន័យ។ ទីក្រុង ភ្នំពេញ របាយការណ៍ស្រាវជ្រាវរបស់ក្រសួងសុខាភិបាលកម្ពុជា អង្គការសុខភាពពិភពលោក AusAID សាកលវិទ្យាល័យRMIT ។

ធនាគារ, w ភាពក្រីក្របានធ្លាក់ចុះ ប៉ុន្តែប្រជាជនកម្ពុជាជាច្រើនគឺនៅតែជួបហានិភ័យ (២០១៤)នៃការធ្លាក់ខ្លួនក្នុងភាពក្រីក្រសារជាថ្មី ។

Biddulph, R.ឃើញកាន់តែច្បាស់នូវអ្នកក្រីក្រ ។ របាយការណ៍ស្រាវជ្រាស្តីពីភាពគ្មានដីធ្លី (២០០០) និងការអភិវឌ្ឍ ។ គម្រោងការសិក្សាស្តីអំពីដីធ្លីនៅកម្ពុជា ។Oxfam, ទីក្រុង ភ្នំពេញ, Ofam

Biddulph, R. ភាពក្រីក្រ (២០០៨) និងការវាយតម្លៃទៅលើផលប៉ះពាល់សង្គម និងនៃសប្បទានដីសង្គមកិច្ចក្នុងប្រទេសកម្ពុជា ការវាយតម្លៃលើភាពគ្មានដីធ្លី, ប្រទេសកម្ពុជា, Oxfam Great Britain ។

សមាគមន៍ការនាំចេញអង្ករកម្ពុជា " (២០១៤) របាយការណ៍ស្តីអំពី ស្ថានភាពនៃការនាំចេញអង្ករកម្ពុជា ក្នុងរយៈពេល១២ខែ ប្រចាំឆ្នាំ២០១៣ " ទាញយកនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៤ ដកស្រង់ពីគេហទំព័រ http://www.riceassociation.com/#market

CARE ធ្លាក់ខ្លួនជាប់បំណុល (២០១២): ផលប៉ះពាល់នៃទឹកជំនន់ឆ្នាំ២០១១ក្នុងប្រទេសកម្ពុជាលើបំណុលគ្រួសារ។ ការស្ទង់មតិលើ គ្រួសារក្រីក្រ នៅក្នុងខេត្តចំនួនបីដែលងាយរងផលប៉ះពាល់, លទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ : CARE, សេវាកម្មឧបត្ថម្ភកាតូលិច, Oxfam និង Pact ។

Chan, S. (២០១១) ពូជស្រូវសំខាន់ៗទាំង១០ប្រភេទ ។

CMA (២០១៤)" សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា៖ សមាជិក ។" ទាញយកនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៤ ពីគេហទំព័រ៖ http://cma-network.org/drupal/Members.

ទីស្តីការគណៈរដ្ឋមន្ត្រី (2010) ឯកសារគោលនយោបាយណ៍ស្តីអំពីការលើកកម្ពស់ផលិតផលស្រូវ និងការនាំចេញអង្ករ។

ក្រុមហ៊ុនប្រឹក្សា និងផ្តល់យោបល់ដំរី (២០១១) ។ SKY ២០០៨ ការសិក្សាជាមូលដ្ឋាន ។ ទីក្រុងភ្នំពេញ ក្រុមហ៊ុនប្រឹក្សា និងផ្តល់យោបល់ដំរី។

Huy, R., et al. (២០០៩)" ថ្លៃចំណាយព្យាបាលជម្ងឺគ្រុនឈាមនិងជម្ងឺគ្រុនឈាមក្នុងក្រុមគ្រួសារដែលនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា ។ ការសិក្សាគ្រប់គ្រងករណីតាមសហគមន៍ដែលជាគោលដៅ ។"MBC សុខភាពសារធារណៈ: ៩: ១៥៥ ។

Jacob, B. និង N.Price" ។ (២០០៤) ផលប៉ះពាល់នៃអនុវត្តថ្លៃសេវាអ្នកប្រើប្រាស់នៅមន្ទីពេទ្យស្រុកក្នុងប្រទេសកម្ពុជា" ។ ផែនការ និងគោលនយោបាយសុខភាព ១៩: ៣១០–៣២១ .

Julienbeaute និង Sirendvong" ។ (២០១០) បន្ទុកចំណាយលើជម្ងឺគ្រុនឈាមក្នុងប្រទេសកម្ពុជា" ។ "MBC សុខភាពសាធារណៈ: ១០:៥២១ ។

Kassie, A. (២០០០). ឥណទាន និងភាពគ្មានដីធ្លី : ផលប៉ះពាល់នៃតំណើរការឥណទានទៅលើភាពគ្មានដីធ្លី ក្នុងស្រុក ជើងព្រៃ និងស្រុកបាត់ដំបង កម្ពុជា ភ្នំពេញ និងមជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ ។

Kenjiro, Y. (២០០៥) "ហេតុអ្វីបានជាជម្ងឺបង្កឲ្យមានការខូចខាតសេដ្ឋកិច្ចធ្ងន់ធ្ងរជាងការបរាជ័យចំពោះផលដំណាំ" ការអភិវឌ្ឍននិងការផ្លាស់ប្តូរ ៣៦:៧៥៩ .

Khun, S. L. Manderson " ។ (២០០៧) ការស្វែរកសុខភាពនិង ការទទួលបានការគាំពារកុមារដែលសង្ស័យថាមានជម្ងឺគ្រុនឈាម ក្នុងប្រទេសកម្ពុជា: ការសិក្សាពីនរវង្សវិទ្យា "MBC សុខភាពសាធារណៈ: ៧:២៦២ ។

Khun, S. L. Manderson" ។ (២០០៨)ភាពក្រីក្រ ថ្លៃសេវាអ្នកប្រើប្រាស់និងលទ្ធភាពបង់ប្រាក់សម្រាប់ការថែរក្សាសុខភាពចំពោះកុមារដែលសង្ស័យថាមានផ្ទុកជម្ងឺគ្រុនឈាមនៅក្នុងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា" អត្ថបទបោះពុម្ពផ្សាយស្តីអំពីសមភាពសុខភាព ៧:១០ ។

Leive, A. និង K. Xuការដោះស្រាយ ចំពោះការចំណាយប្រាក់ចេញពីហោប៉ៅ នៃការ (២០០៨) បង់ប្រាក់សម្រាប់សុខភាព៖ ភស្តុតាងជាក់ស្តែងពីប្រទេសអាហ្វ្រិចចំនួន១៥ ។ ព្រឹត្តិប័ត្ររបស់អង្គការសុខភាពពិភពលោក ៨៦:៨៤៩ ។

Matsuoka, S., et al. (2010). " ឧបសគ្គដែលមានលើការប្រើប្រាស់ សេវាកម្ម តំហែទាំសុខភាពមាតាក្នុងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ។" គោលនយោបាយណ៍សុខភាព៩៥២៥៥::២៦៣ ។

MoH (១៩៩៦គម្រោងការជាតិស្តីអំពីមូលនិធិសម្រាប់វិស័យសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា ( ។

MoHរបាយការណ៍ស្តីអំពីមូលនិធិសម្រាប់វិស័យសុខភាពប្រចាំឆ្នាំ (២០០៩) , ក្រសួងសុខាភិបាល ។

MoH ២០១២របាយការណ៍ស្តីអំពីមូលនិធិសម្រាប់វិស័យសុខភាពប្រចាំឆ្នាំ (២០១២), ក្រសួងសុខាភិបាល ។

NBC (២០០៩ប្រកាសស្តីអំពីសេរីភាពក្នុងការកំណត់អត្រាការប្រាក់ ។ ភ្នំពេញ កម្ពុជា ធន .(ាគារជាតិនៃកម្ពុជា ។

NIS គួរលេខភ្លាមៗ ២០០៨ជំរឿនទូទៅនៃប្រជាជនប្រទេសកម្ពុជា ឆ្នាំ (២០០៩)នៃលទ្ធផលជំរឿនចុងក្រោយ ។

NIS, N. (២០០០ជំរឿនសុខភាព ( និងប្រជាសាស្ត្រកម្ពុជា ។

RDB (2014)." ប្រវិត្តនៃធនាគារអភិវឌ្ឍន៍ជនបទ" ទាញយកនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៤ ពី http://hdr.undp.org/en/countries/profiles/KHM .

Sauerborn, R., et al. (1996). " យុទ្ធសាស្ត្ររបស់គ្រួសារក្នុងការដោះស្រាយ ជាមួយថ្លៃចំណាយព្យាបាលជម្ងឺ" វិទ្យាសាស្ត្រសង្គម និងវេជ្ជសាស្ត្រ ៤៣៖ ២៩១។

UNDP (២០០៤)។ មីក្រូហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា។ UNDP។

UNDP (២០១៣)។ "ព័ត៌មានពីប្រទេសកម្ពុជា។" ទាញយកនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៤ពី http://hdr.undp.org/en/countries/profiles/khm ។

UNDP(២០១៤)។ "ប្រទេសកម្ពុជា។" ទាញយកនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ពី http://www.kh.undp.org/content/cambodia/en/home.html ។

VanDamme, W., et al (២០០៤)។" ការចំណាយព្យាបាលចេញពីហោប៉ៅឯកជន និងបំណុល ក្នុងគ្រួសារក្រីក្រ៖ ភស្តុតាងពីប្រទេសកម្ពុជា។"

VanDamme, W., et al. (២០០៣)។ " ការចំណាយលើការថែទាំសុខភាពធ្ងន់ធ្ងរ។" The Lancet ៣៦២៖ ៩៩៦-៩៩៧

WAC (២០០៤)។ ការជាប់បំណុល។ ភ្នំពេញ កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ (WAC) និង Oxfam Great Britain។

## ចង្កោមឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ I៖ កម្រងសំណួរសម្រាប់ការវាយតម្លៃឆាប់រហ័ស

ឧបសម្ព័ន្ធ II៖ សំណួរដឹកមុខសម្រាប់ការសម្ភាសន៍គ្រួសារ

សំណួរដឹកមុខសម្រាប់ការសម្ភាសន៍គ្រួសារ

សំណួរដឹកមុខសម្រាប់បុគ្គលិកមណ្ឌលសុខភាព

សំណួរដឹកមុខសម្រាប់ការិយាល័យកសិកម្ម

សំណួរដឹកមុខសម្រាប់ស្ថាប័នមីក្រូហិរញ្ញវត្ថុ/ធនាគារ

ឧបសម្ព័ន្ធ III៖ តារាងសម្ភាសន៍ភាគីពាក់ព័ន្ធ

ឧបសម្ព័ន្ធ IV៖ ឯកសារព្រមព្រៀង

ឧបសម្ព័ន្ធ V៖ ក្រាហ្វិកបន្ថែម តារាង ករណីសិក្សា

ឧបសម្ព័ន្ធ VI៖ លក្ខខណ្ឌការងារ